## សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
## និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

**សារណាបញ្ចប់ការសិក្សា**

# ការប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ
# សម្រាប់ក្រុមហ៊ុនសេវាកម្ម

ស្រាវជ្រាវពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០


តាក់តែងឡើងដោយ

និស្សិតឈ្មោះ ខែ សុមនា

ទេព សិរីអាទិត្យា

សាស្ត្រាចារ្យណែនាំ

លោក ស សុភាព


ថ្នាក់បរិញ្ញាបត្រ គណនេយ្យ

ជំនាន់ទី ១៥

ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេរសារណា ២០២០

# អារម្ភកថា

ក្រោយពីបានសិក្សាអស់រយៈពេលបួនឆ្នាំ នៃថ្នាក់បរិញ្ញាបត្រគណនេយ្យនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច យើងខ្ញុំ មានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំង ដោយមានឱកាសក្នុងការសរសេរសារណាបញ្ចប់ការសិក្សា ក្រោមប្រធានបទ"**ការប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំសម្រាប់ក្រុមហ៊ុនសេវាកម្ម**"។ ការសរសេររបាយការណ៍សារណានេះ ពិតជាបានផ្តល់នូវបទពិសោធន៍ដ៏មានសារៈសំខាន់បំផុត និងចំណេះដឹងបន្ថែមទៅលើនីតិវិធី និងដំណើរការនៃការប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំសម្រាប់ក្រុមហ៊ុនសេវាកម្មផងដែរ។ លើសពីនេះទៅទៀត រាល់ព័ត៌មានដែលទទួលបានទាំងនេះសុទ្ធសឹងតែជាព័ត៌មានដែលចាំបាច់ សម្រាប់យកមកធ្វើការសិក្សាស្រាវជ្រាវ។

ជាការពិតណាស់ ការសម្រេចចិត្តជ្រើសរើសយកប្រធានបទនេះមកធ្វើការសិក្សាស្រាវជ្រាវគឺ ដោយសារតែប្រធានបទនេះ ពិតជាមានសារៈសំខាន់សម្រាប់និសិត្សដែលចង់យល់ដឹងបន្ថែមពីច្បាប់ពន្ធដារ និងដំណើរការនៃការរៀបចំការប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ នៅក្នុងប្រទេសកម្ពុជា។ ទន្ទឹមនឹងនេះផងដែរ ចំណេះដឹងដែលបានមកពីការសរសេររបាយការណ៍នេះ នឹងជួយអោយយើងខ្ញុំអាចយកទៅអនុវត្តការងារនាពេលអនាគតបានយ៉ាងត្រឹមត្រូវទៅតាមអនុក្រឹត្យ និងច្បាប់។

ជាចុងបញ្ចប់ យើងខ្ញុំ ស្វាគមន៍រាល់មតិយោបល់ផ្សេងៗ ដើម្បីអោយខ្លឹមសាររឹតតែល្អប្រសើរជាងនេះ។ យើងខ្ញុំក៏សង្ឃឹមផងដែរថា សារណាមួយនេះ អាចចូលរួមជាចំណែកសម្រាប់ការសិក្សាស្រាវជ្រាវដល់និស្សិតជំនាន់ក្រោយ ដែលមានបំណងចង់សិក្សាស្វែងយល់បន្ថែមអំពីប្រធានបទមួយនេះ។

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំ ខៃ សុមនា និង ទេព សិរីអាទិត្យា ជានិស្សិតបរិញ្ញាបត្រគណនេយ្យ ឆ្នាំទី៤ ជំនាន់ទី១៥ ក្រុម A4C2 នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច បានធ្វើការស្រាវជ្រាវសរសេររបាយការណ៍ សារណាបញ្ចប់ការសិក្សាលើប្រធានបទ "**ការប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំសម្រាប់ក្រុមហ៊ុនសេវាកម្ម**"។ យើងខ្ញុំ សូមធ្វើការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងពោរពេញទៅដោយសេចក្តីគោរពដល់បុគ្គលសំខាន់ៗដូចខាងក្រោមៈ

លោកឪពុក អ្នកម្តាយ ដែលជាអ្នកមានគុណយ៉ាងធំធេង គ្មានអ្វីប្រៀបពុំបានឡើយ។ លោកទាំងពីរខិតខំចិញ្ចឹមបីបាច់ថែរក្សា ផ្គត់ផ្គង់តម្រូវការរបស់កូនសព្វគ្រប់បែបយ៉ាង ទាំងក្នុងការសិក្សា និងតម្រូការផ្សេងៗ អប់រំ ទូន្មានប្រៀនប្រដៅប្រកបដោយសេចក្តីស្រឡាញ់ និងភាពកក់ក្តៅ ។ លោកទាំងពីរប្រឹងអស់ពីកំលាំងកាយចិត្ត ធ្វើយ៉ាងណាអោយកូនរៀនបានខ្ពង់ខ្ពស់ និងមានអនាគតភ្លឺថ្លា ដោយមិនខ្លាចនឿយហត់។

លោកឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការង លោកព្រឹទ្ធបុរស លោកព្រឹទ្ធបុរសរង សាស្រ្តាចារ្យព្រមទាំងបុគ្គលិក និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត ស្រាវជ្រាវ និងខិតខំរកនូវអ្វីដែលថ្មី ដើម្បីធ្វើអោយការសិក្សារបស់និស្សិត កាន់តែល្អប្រសើរឡើង បានផ្តល់ឱកាសដ៏មានតម្លៃ ក្នុងការធ្វើការស្រាវជ្រាវ និងចងក្រងសារណាបញ្ចប់ការសិក្សានេះឡើងមក និងបានយកចិត្តទុកដាក់ ជួយសម្រួលដល់ដំណើរការសរសេររបាយការណ៍សារណានេះឱ្យទទួលបានជោគជ័យផងដែរ។

លោកសាស្រ្តាចារ្យ ស សុភាព ដែលបានចំណាយពេលវេលាដ៏មានតម្លៃរបស់លោកគ្រូ ដឹកនាំដំណើរការសរសេរសារណាមួយនេះឡើងមក ទោះបីជាលោកគ្រូមានភាពមមាញឹកក៏ដោយ។ លោកគ្រូ បានបង្ហាត់បង្រៀន ណែនាំ ចែករំលែកនូវចំណេះដឹង បទពិសោធន៍ ដំបូន្មានទាំងក្នុងការស្រាវជ្រាវសរសេរសារណា និងបទពិសោធន៍ផ្ទាល់ខ្លួន កែតម្រូវចំណុចខ្វះខាត ថែមទាំងជម្រុញលើកទឹកចិត្តដើម្បីជាគន្លឹះក្នុងការដើរទៅរកភាពជោគជ័យ ភាពកើនឡើងនូវចំណេះដឹងដ៏មានតម្លៃ និងភាពល្អប្រសើរនូវការសម្រេចបានសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រគណនេយ្យមួយនេះ ឱ្យទទួលបានលទ្ធផលជាទីគាប់ចិត្ត។

សរុបសេចក្តីមក យើងខ្ញុំ សូមលំឱនកាយគោរព និងប្រសិទ្ធិពរជ័យចំពោះបុគ្គលសំខាន់ៗខាងលើ ឱ្យជួបតែសំណាងល្អ ទទួលជោគជ័យទាំងក្នុងជីវិត និងការងារ និងជួបតែពុទ្ធិពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា


តារាងសំគាល់អក្សរកាត់ ......iv

បញ្ជីតារាង ...... v

បញ្ជីឧបសម្ព័ន្ធ ......vi


## សេចក្តីផ្តើម


១ លំនាំបញ្ហា ......១

២. ចំណោទបញ្ហានៃការស្រាវជាវ ...... ២

៣. គោលបំណងនៃការស្រាវជ្រាវ ...... ២

៤.ទំហំ និងដែនកំណត់នៃការស្រាវជាវ ...... ៣

៥.វិធីសាស្រ្តនៃការស្រាវជ្រាវ...... ៣

៦. សារៈសំខាន់នៃការស្រាវជ្រាវ...... ៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ......៤


## ជំពូកទី១

## មូលដ្ឋានគ្រឹះនៃពន្ធក្នុងព្រះរាជាណាចក្រកម្ពុជា


១.១. និយមន័យ......៥

១.២. គោលបំណងនៃការប្រមូលពន្ធ......៥

១.៣. ប្រភេទពន្ធ......៥

១.៤. របបកំណត់ពន្ធ ......៦

១.៥. ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ...... ៧

១.៦. សិទ្ធិ និង កាតព្វកិច្ចរបស់អ្នកជាប់ពន្ធ ......៨

១.៦.១. សិទ្ធិរបស់អ្នកជាប់ពន្ធ ...... ៨

១.៦.២. កាតព្វកិច្ចរបស់អ្នកជាប់ពន្ធ...... ៨

១.៧. កាលបរិច្ឆេទនៃការដាក់លិខិតប្រកាសពន្ធ និង បង់ប្រាក់ពន្ធ......៩

១.៨. ការតវ៉ារបស់អ្នកជាប់ពន្ធ ......៩

១.៩.សវនកម្មពន្ធដារ...... ១១

១.៩.១. ប្រភេទនៃសវនកម្មពន្ធដារ...... ១១

១.៩.២. ការជ្រើសរើសសហគ្រាសធ្វើសវនកម្ម ..................... ១២
១.១០. ទោសទណ្ឌសារពើពន្ធ ..................... ១២
១.១០.១. អំពើរាំងស្ទះការអនុវត្តបទបញ្ញត្តិពន្ធដារ ..................... ១២
១.១០.២. អំពើគេចវេសពន្ធ ..................... ១៣
១.១១ ពន្ធបន្ថែម និង ការប្រាក់ ..................... ១៣
១.១២.ប្រភេទពន្ធសំខាន់ៗមួយចំនួន ..................... ១៤
១.១២.១ ពន្ធប៉ាតង់ ..................... ១៤
១.១២.២ អាករលើតម្លៃបន្ថែម (អតប) ..................... ១៦
១.១២.៣. អាករស្នាក់នៅ ..................... ២០
១.១២.៤. ពន្ធកាត់ទុក ..................... ២១
១.១២.៥. ពន្ធលើប្រាក់បៀវត្ស ..................... ២៣
១.១២.៦. អាករបំភ្លឺសាធារណៈ ..................... ២៦
១.១២.៧. អាករពិសេសលើទំនិញ និងសេវា ..................... ២៧
១.១២.៨. ពន្ធអប្បបរមា ..................... ២៨
១.១២.៩. ប្រាក់រំដោះពន្ធលើប្រាក់ចំណូល ..................... ២៨
១.១២.១០.ពន្ធលើប្រាក់ចំណូល ..................... ២៩

## ជំពូកទី២

## ការរីករាលដាលនៃវិស័យសេវាកម្ម

២.១.ប្រវត្តិត្រួសៗនៃបដិវត្តសង្គមមនុស្ស ..................... ៤១
២.២.មូលហេតុនៃការរីករាលដាលនៃវិស័យសេវាកម្ម ..................... ៤២
២.៣.វិស័យសេវាកម្ម ..................... ៤៣

## ជំពូកទី៣

## ការប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំរបស់ក្រុមហ៊ុនសេវាកម្ម

៣.១.លិខិតប្រកាសពន្ធ ..................... ៤៥
៣.២ ដំណើរការនៃការប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំសម្រាប់ក្រុមហ៊ុនសេវាកម្ម ..................... ៦១
៣.៣. របៀបគណនាពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ..................... ៦៣

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

១ សេចក្តីសន្និដ្ឋាន ......................................................................................................៧៩
២ ការផ្តល់អនុសាសន៍ .................................................................................................... ៨១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# តារាងសំគាល់អក្សរកាត់

| អក្សរកាត់ | ពាក្យពេញ |
|---|---|
| ចសព | ច្បាប់សារពើពន្ធ |
| ប្រក | ប្រកាស |
| ពបច | ពន្ធលើប្រាក់ចំណូល |
| អពដ | អគ្គនាយកដ្ឋានពន្ធដារ |
| អតប | អាករលើតម្លៃបន្ថែម |
| ស.វ | សតវត្សន៍ |
| ផ.ស.ស | ផលិតផលក្នុងស្រុកសរុប |
| ការិយ. | ការិយបរិច្ឆេទ |

# បញ្ជីតារាង

តារាងទី១៖ ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ......................................................៧
តារាងទី២៖ អត្រាពន្ធកាត់ទុកទូទាត់ទៅអោយនិវាសនជន ...................................................... ២១
តារាងទី៣៖ តារាងភាគនៃប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ ...................................................... ២៥
តារាងទី៤៖ អត្រាពន្ធកំណើនតាមថ្នាក់...................................................................................... ៣១
តារាងទី៥៖ ទ្រព្យសកម្មក្នុងតារាងតុល្យការ(I).............................................................................៤៦
តារាងទី៦៖ មូលនិធី/ទុនម្ចាស់ទ្រព្យ និងបំណុលនៃតារាងតុល្យការ(II) ..........................................៤៨
តារាងទី៧៖ ចំណូលប្រតិបត្តិការ និងថ្លៃដើមនៃប្រតិបត្តិការ........................................................៤៩
តារាងទី៨៖ ចំណូលផ្សេងៗ ..........................................................................................................៥០
តារាងទី៩៖ ចំណាយប្រតិបត្តិការ..................................................................................................៥១
តារាងទី១០៖ គណនាប្រាក់ចំណេញក្រោយបង់ពន្ធ ..................................................................... ៥២
តារាងទី១១៖ គណនាពន្ធលើប្រាក់ចំណូល......................................................................................៥៤
តារាងទី១២៖ គណនាវិភាគទានសប្បុរសធម៌ ............................................................................. ៥៧
តារាងទី១៣៖ គណនាចំណាយការប្រាក់..........................................................................................៥៨
តារាងទី១៤៖ តារាងតាមដានលទ្ធផលសារពើពន្ធខាតយោងទៅមុខ..............................................៥៩
តារាងទី១៥៖ បូកសរុបកូដនីមួយៗទាំង១២ខែ.............................................................................. ៦២
រូបភាពទី១៖ សូចនាករម៉ាក្រូសេដ្ឋកិច្ច ........................................................................................ ៤៣

# បញ្ជីឧបសម្ព័ន្ធ

១. លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ

២. ប្រកាសស្តីពីពន្ធលើប្រាក់ចំណូល លេខ០៩៨ សហវ.ប្រក

៣. ប្រកាសស្តីពីពន្ធលើប្រាក់ចំណេញដែលសម្រេចដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ ១០៥៩ សហវ.ប្រក.ពដ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៣ (ផ្នែក១.៦ នៃជំពូកទី១ និងផ្នែក៥.២ នៃជំពូកទី៥)។

# សេចក្តីផ្តើម

## ១ លំនាំបញ្ហា

នៅពេលមនុស្សចាប់ផ្តើមចេះរស់នៅប្រមូលផ្តុំគ្នាជារដ្ឋតូចៗ ពួកគេ ចាប់ផ្តើមបង្កើតច្បាប់ផ្សេងៗ ដើម្បីគ្រប់គ្រងរដ្ឋរបស់ខ្លួនឱ្យមានសណ្តាប់ធ្នាប់ល្អ មិនមានភាពចលាចល មានយុត្តិធម៌ និងនាំមកនូវសុវត្ថិភាពក្នុងប្រទេសជាតិ។ កាលណាប្រទេសជាតិមួយ មានច្បាប់ទំលាប់ល្អត្រឹមត្រូវ ប្រទេសជាតិនោះ រមែងតែងទទួលបាននូវភាពជោគជ័យ ក្នុងការអភិវឌ្ឍទៅដល់គោលដៅ និងសម្រេចបាននូវផលប្រយោជន៍ជារួម។ ដើម្បីទ្រទ្រង់ប្រទេសជាតិមួយអោយមានការអភិវឌ្ឍ និងដំណើរការទៅល្អ រដ្ឋនោះត្រូវតែមានប្រភពចំណូល រឹងមាំក្នុងការទ្រទ្រង់ចំណាយផ្សេងៗ ទៅលើប្រទេសជាតិរបស់ខ្លួន។ តម្រូវការនូវប្រភពចំណូលនេះហើយ ទើបធ្វើអោយមានការលេចឡើងនូវច្បាប់ពន្ធ ដាក់ចេញឱ្យអនុវត្តឡើងលើប្រជាជន ព្រោះប្រជាជន អាចចូលរួមចំណែកអភិវឌ្ឍប្រទេសជាតិតាមរយៈការបង់ពន្ធ។ ពន្ធ មានដើមកំណើតតាំងពីយូរលង់ណាស់មកហើយ តាំងតែពីសម័យបុរាណកាលមកម្ល៉េះ និងជាប្រភពចំណូលជាតិយ៉ាងសំខាន់បំផុតរបស់រដ្ឋ ក្នុងការអភិវឌ្ឍប្រទេសជាតិអោយមានភាពចុំរុងចំរើន និងរីកចម្រើនជាងមុន។

ពេលវេលាចេះតែកន្លងផុតទៅ ហើយការអនុវត្តពន្ធនេះ ក៏ចាប់កើតមានពីរដ្ឋមួយទៅរដ្ឋមួយផ្សេងទៀត និងមានការបង្កើតថែមថ្មីៗ ព្រមទាំងបង្កើនប្រសិទ្ធភាពនៃប្រព័ន្ធប្រមូលពន្ធ ទៅតាមសម័យកាលស្របនឹងភាពជឿនលឿននៃសង្គមមនុស្សជាតិ។ ជាក់ស្តែងប្រសិនបើធ្វើការក្រឡេកទៅមើលតថៈភាពសង្គមមនុស្សវិញភាពរីវត្តទៅមុខ មានជាបន្តបន្ទាប់ស្របទៅតាមបច្ចេកវិទ្យា។ សង្គមសម័យក្រោយបដិវត្តឧស្សាហកម្មដែលយើងរស់នៅសព្វថ្ងៃនេះ ជាសង្គមដែលមនុស្សចាប់ផ្តើមផ្តោតសំខាន់ទៅលើជំនាញ ព័ត៌មាន និងសេវាកម្មជៀសជាងទៅលើទំនិញ ហើយឱ្យតម្លៃទៅលើ ចំណេះដឹង ការអប់រំ និងជំនាញ។ ជាក់ស្តែងប្រទេសកម្ពុជា ជាប្រទេសមួយដែលកំពុងស្ថិតនៅក្នុងការអភិវឌ្ឍគ្រប់វិស័យ ស្របទៅតាមភាពជឿនលឿនរបស់ពិភពលោក។ តួយ៉ាងសង្គមនេះគឺជា មានភាពជឿនលឿនខាងបច្ចេកវិទ្យា និងការកកើតឡើងនៃក្រុមហ៊ុនសេវាកម្មជាច្រើនដែលប្រើប្រាស់នូវចំណេះដឹង ជំនាញ និងបទពិសោធន៍ នៅក្នុងការធ្វើអាជីវកម្ម និង បម្រើតម្រូវការអតិថិជន។ គ្រប់សហគ្រាសធ្វើអាជីវកម្ម ផ្គត់ផ្គង់ទំនិញ ឬសេវា ពិតប្រាកដណាស់មានកាតព្វកិច្ចបង់ពន្ធផ្សេងៗ ទៅតាមប្រភេទអាជីវកម្មរបស់ខ្លួន ដែលក្នុងនោះផងដែរ ពន្ធម្យ៉ាងក្នុងចំណោមពន្ធជាច្រើនដែលអ្នកធ្វើជំនួញអាជីវកម្មតែងមានភាពមមាញឹកក្នុងការដាក់លិខិតប្រកាសសារពើពន្ធជារៀងរាល់ឆ្នាំ ដោយខកខានពុំបាននោះ គឺ **ពន្ធលើប្រាក់ចំណូល**។ ក្រុមហ៊ុនសេវាកម្មដូចនឹងក្រុមហ៊ុនដទៃទៀតផងដែរ មានការជាប់ពន្ធផ្សេងៗ ដែលក្នុងនោះពន្ធលើប្រាក់ចំណូល ជាប្រធានបទដែលលើកយកមកបកស្រាយនៅក្នុងសារណាបញ្ចប់ការសិក្សានេះ។

ការផ្គត់ផ្គង់សេវា មិនមានទម្រង់ដូចការផ្គត់ផ្គង់ទំនិញឡើយ ហេតុដូច្នេះហើយទើបសារណាបញ្ចប់ការសិក្សានេះស្រាវជ្រាវទៅលើប្រធានបទ "**ការប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំសម្រាប់ក្រុមហ៊ុនសេវាកម្ម**"។

តាមរយៈការរៀបរាប់ក្នុងកថាខណ្ឌខាងលើ បានបង្ហាញអោយឃើញថា ពន្ធ គឺជាកាតព្វកិច្ចដែលត្រូវតែបង់ និងខានពុំបានឡើយ ហើយពន្ធលើប្រាក់ចំណូលនេះ ជាប្រភេទពន្ធដែលទទួលបាននូវការចាប់អារម្មណ៍ជាខ្លាំងពីសំណាក់អ្នកជាប់ពន្ធ និងតម្រូវអោយអ្នកជាប់ពន្ធ ធ្វើការដាក់លិខិតប្រកាសសារពើពន្ធជារៀងរាល់ការិយបរិច្ឆេទមុនកាលកំណត់។ ការផ្គត់ផ្គង់សេវា និងការផ្គត់ផ្គង់ទំនិញ ឬផលិតផល ជាការបម្រើអតិថិជនដូចគ្នា ក៏ប៉ុន្តែរូបភាពនៃការផ្គត់ផ្គង់មានភាពផ្សេងពីគ្នា។ ការស្វែងយល់អំពីការប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំសម្រាប់ក្រុមហ៊ុនសេវាកម្ម ឱ្យបានត្រឹមត្រូវ ពិតជាមានសារៈសំខាន់ណាស់ ព្រោះជាកាតព្វកិច្ចរបស់អ្នកជាប់ពន្ធគ្រប់រូប ដែលជាម្ចាស់អាជីវកម្មទៅលើផ្នែកសេវាកម្ម។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ក្រុមហ៊ុនសេវាកម្ម មានភាពរីកដុះដាលយ៉ាងខ្លាំង ស្របតាមបច្ចេកវិទ្យាជឿនលឿន និងតម្រូវការនៃសង្គមមនុស្សនៅក្នុងសម័យក្រោយបដិវត្តឧស្សាហកម្មមួយនេះ។ ក្រុមហ៊ុនដែលធ្វើការផ្គត់ផ្គង់សេវា មានកាតព្វកិច្ចប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ និងដាក់លិខិតប្រកាសនៅរដ្ឋបាលសារពើពន្ធ មិនអោយលើសពីថ្ងៃទី៣១ ខែមិនា នៃឆ្នាំបន្ទាប់ពីឆ្នាំដែលត្រូវបង់ពន្ធនោះទេ។ បើទោះបីជាមានការពន្យល់អំពីប្រភេទពន្ធនេះ និងរបៀបនៃការធ្វើការប្រកាសពន្ធនេះពីអគ្គនាយកដ្ឋានពន្ធដារក្តី ក៏ឃើញថានូវភាពលំបាក និងភាពខ្វះចន្លោះរបស់អ្នកជាប់ពន្ធលើកាតព្វកិច្ចមួយនេះ នៅតែកើតមាន។

ហេតុដូច្នេះហើយទើបមានសំណួរផ្សេងៗបានចោទឡើងថា៖

១. តើធាតុសំខាន់ៗនៅក្នុងលិខិតប្រកាសពន្ធលើប្រាក់ចំណូល មាន អត្ថន័យ យ៉ាងដូចម្តេច?

២.តើការប្រកាសពន្ធលើប្រាក់ចំណូលសម្រាប់ក្រុមហ៊ុនសេវាកម្ម មានដំណើរការយ៉ាងដូចម្តេច?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ប្រធានបទនៃការស្រាវជ្រាវមួយនេះ គឺផ្តោតសំខាន់លើការប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំសម្រាប់ក្រុមហ៊ុនសេវាកម្ម។ គោលបំណងនៃការសិក្សាស្រាវជ្រាវនេះ មានចំណុចសំខាន់ៗ ដូចខាងក្រោម៖

- ស្វែងយល់ឱ្យកាន់តែច្បាស់ពីធាតុសំខាន់ៗនៅក្នុងលិខិតប្រកាសពន្ធលើប្រាក់ចំណូល។
- សិក្សាអោយកាន់តែស៊ីជម្រៅលើការប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំសម្រាប់ក្រុមហ៊ុនសេវាកម្ម។

## ៤.ទំហំ និងដែនកំណត់នៃការស្រាវជាវ

ដោយសារតែ ពន្ធលើប្រាក់ចំណូល គឺជាពន្ធដែលមានលក្ខណៈអនុវត្តផ្សេងៗគ្នា អាស្រ័យលើប្រភេទ និង ទំហំ របស់សហគ្រាស និងចំណាត់ថ្នាក់នៃអ្នកជាប់ពន្ធ ហេតុនេះហើយទាមទាររយៈពេលច្រើនក្នុងការស្រាវជ្រាវ និងចងក្រងជាសារណាឡើង។ អាស្រ័យហេតុផលខាងលើ នៅក្នុងសារណាបញ្ចប់ការសិក្សានេះ យើងខ្ញុំសិក្សាតែលើលក្ខណៈទូទៅនៃពន្ធ និងរបៀបនៃការប្រកាសពន្ធលើប្រាក់ចំណូល ដែលកំណត់យកតែការអនុវត្តទៅលើក្រុមហ៊ុនសេវាកម្ម ចំពោះអ្នកជាប់ពន្ធមធ្យមលើអត្រាពន្ធ២០%តែប៉ុណ្ណោះ។

## ៥.វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីជាយានក្នុងការប្រមូលទិន្នន័យទាំងអស់នេះ មកចងក្រងជារបាយការណ៍សារណាសម្រាប់ថ្នាក់បញ្ចប់បរិញ្ញាបត្រគណនេយ្យនេះឡើង យើងខ្ញុំបានធ្វើការស្រាវជ្រាវតាមវិធីសាស្ត្របែបគុណវិស័យ ដោយផ្អែកទៅលើទិន្នន័យបន្ទាប់បន្សំ ដែលជាប្រភេទទិន្នន័យដែលមានប្រភពចេញមកពី ៖

- ការចង្អុលបង្ហាញណែនាំពីសាស្ត្រាចារណែនាំ។
- ការសិក្សាស្រាវជ្រាវឯកសារ ដូចជាច្បាប់ អនុក្រឹត្យ ក្រម ប្រកាស សេចក្តីជូនដំណឹង សារាចរណ៍ និង ឯកសារចងក្រងរបស់សាស្ត្រាចារ្យ។
- ព័ត៌មានដែលទទួលបានមកពីគេហទំព័ររបស់ អគ្គនាយកដ្ឋានពន្ធដារ និងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។
- ទិន្នន័យដែលស្វែងរកតាមប្រព័ន្ធអ៊ីនធើណែត។
- របាយការណ៍កម្មសិក្សា និងសារណាបញ្ចប់ការសិក្សារបស់សិស្សច្បងដែលទាក់ទងជុំវិញបញ្ហានេះ។
- ការអានឯកសារទាក់ទិនផ្សេងៗ ដើម្បីទទួលបាននូវព័ត៌មានផ្សេងៗ។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ មានលក្ខណៈស្មុគស្មាញបន្តិច ដូច្នេះការសិក្សាស្រាវជ្រាវលើប្រធានបទនេះនឹងអាចជួយសម្រួលនូវភាពលំបាក និងឆ្លើយនឹងសំណួរទាក់ទងនឹងពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ដែលផ្តោតលើក្រុមហ៊ុនសេវាកម្ម។ លើសពីនេះទៅទៀត សារៈសំខាន់ក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទនេះ មានដូចជា៖

- ចំពោះយើងខ្ញុំ៖ បានផ្តល់ចំណេះដឹងកាន់តែស៊ីជម្រៅលើពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ និងការប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំផ្តោតសំខាន់ទៅលើក្រុមហ៊ុនសេវាកម្ម។ ប្រធានបទនេះបានជួយបង្កើននូវសមត្ថភាពនៅក្នុងការស្រាវជ្រាវ ការប្រមូលឯកសារ ទិន្នន័យផ្សេងៗ ដើម្បីចងក្រងឡើង

នូវឯកសារសារណានេះឡើងមក។ ការស្រាវជ្រាវនេះ បានជួយក្នុងការសិក្សា វិភាគលើទិន្នន័យដែលទទួលបាន និងចេះរៀបចំឯកសារអោយមានសណ្តាប់ធ្នាប់ និងមានរបៀបរៀបរយ ជាពិសេសមានការទទួលខុសត្រូវខ្ពស់លើកិច្ចការរបស់ខ្លួន។

- ចំពោះសាធារណៈជន៖ ការស្រាវជាវលើប្រធានបទសារណាមួយនេះ ផ្តល់ចំណេះដឹងអោយកាន់តែស៊ីជម្រៅអំពីពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ដំណើរការនៃការរៀបចំនូវលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ និងព័ត៌មានលើច្បាប់ពន្ធដែលសាធារណៈជន ជាពិសេសអ្នកជាប់ពន្ធដែលឋិតនៅក្នុងទំហំ និងដែនកំណត់នៃការស្រាវជ្រាវនេះ ដឹងអោយបានច្បាស់ ជៀសវាងនូវការខាតបង់ផ្សេងៗ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវនេះ រចនាសម្ព័ន្ធត្រូវបានបែងចែកជា ប្រាំមួយជំពូកសំខាន់ៗដូចខាងក្រោម៖

- សេចក្តីផ្តើម៖ សិក្សាអំពីមូលដ្ឋាននៃការស្រាវជ្រាវ។ ចំណុចនេះបកស្រាយអំពី លំនាំបញ្ហា ចំណោទបញ្ហា គោលបំណងនៃការសិក្សាស្រាវជ្រាវ ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវ និង រចនាសម្ព័ន្ធនៃការស្រាវជ្រាវ។
- ជំពូកទី១៖ ស្វែងយល់អំពី មូលដ្ឋានគ្រឹះនៃពន្ធក្នុងព្រះរាជាណាចក្រកម្ពុជា ដូចជា និយមន័យពន្ធ គោលបំណងនៃការប្រមូលពន្ធ ប្រភេទពន្ធ របបកំណត់ពន្ធ សិទ្ធ និងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស កាលបរិច្ឆេទនៃការដាក់លិខិតប្រកាសពន្ធ និងបង់ប្រាក់ពន្ធ សវនកម្មពន្ធ ការតវ៉ារបស់អ្នកជាប់ពន្ធ និងការបង្ហាញពីចំណុចសំខាន់ៗរបស់ប្រភេទពន្ធមួយចំនួនដោយសង្ខេបទៅលើ មុខសញ្ញានៃការជាប់ពន្ធ ការលើកលែងពន្ធ អត្រាពន្ធ មូលដ្ឋានគិតពន្ធ និងការគណនាប្រាក់។
- ជំពូកទី២៖ បង្ហាញអំពីការរីកដាលនៃវិស័យសេវាកម្ម។ នៅក្នុងជំពូកនេះផងដែរ នឹងធ្វើការសិក្សាអំពីប្រវត្តិត្រួសៗនៃបដិវត្តសង្គមមនុស្ស មូលហេតុនៃការរីករាលដាលនៃ វិស័យសេវាកម្ម និងវិស័យសេវា-កម្ម។
- ជំពូកទី៣៖ បង្ហាញអំពីលិខិតប្រកាសពន្ធលើប្រាក់ចំណូល ដំណើរការនៃការប្រកាសពន្ធលើប្រាក់ចំណូលរបស់ក្រុមហ៊ុនសេវាកម្ម និងរបៀបគណនាពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ។
- សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍៖ ធ្វើការវាយតម្លៃទៅលើដំណើរការនៃការប្រកាសពន្ធ និងផ្តល់យោបល់ផ្ទាល់របស់យើងខ្ញុំជុំវិញបញ្ហានេះ។

# ជំពូកទី១

# មូលដ្ឋានគ្រឹះនៃពន្ធក្នុងព្រះរាជាណាចក្រកម្ពុជា

## ១.១. និយមន័យ

ពន្ធ គឺជាការបង់ទៅអោយរដ្ឋ (ជាសាច់ប្រាក់ ឬ វត្ថុ) ជាដាច់ខាត ដែលកំណត់ទៅលើរូបវន្តបុគ្គល ឬ នីតិបុគ្គលដោយរដ្ឋាភិបាល។ [1]

## ១.២. គោលបំណងនៃការប្រមូលពន្ធ

ពន្ធបង្កើតឡើងដើម្បី

- បង្កើនចំណូលហិរញ្ញវត្ថុសម្រាប់ចំណាយរបស់រដ្ឋាភិបាល
- ទិសដៅសុខុមាលភាពសង្គម និងសេដ្ឋកិច្ច
- ជម្រុញឱ្យមានកំណើនសេដ្ឋកិច្ច
- កាត់បន្ថយនូវការប្រើប្រាស់លើផលិតផលមិនល្អមួយចំនួនដែលប៉ះពាល់ដល់សុខភាព
- ធានាសមភាពរបស់ប្រជាជន។

## ១.៣. ប្រភេទពន្ធ

នៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រព័ន្ធពន្ធដារអនុវត្តយកពន្ធតាមវិធីសាស្ត្រពីរ គឺ វិធីសាស្ត្រផ្ទាល់ និងវិធីសាស្ត្រប្រយោល ឬពន្ធផ្ទាល់ និងពន្ធប្រយោល។[2]

- **ពន្ធផ្ទាល់**

ពន្ធផ្ទាល់ គឺជាពន្ធដែលកំណត់ទៅលើរូបវន្តបុគ្គល សាជីវកម្ម ឬសហគ្រាស ដែលមានកាតព្វកិច្ចពន្ធដារ ហើយបង់ពន្ធដោយពួកគេផ្ទាល់ទៅអោយរដ្ឋាភិបាល។

ខាងក្រោមនេះគឺជាពន្ធផ្ទាល់

- ពន្ធលើប្រាក់ចំណូល
- ពន្ធអប្បបរមា
- ពន្ធលើប្រាក់បៀវត្ស
- ពន្ធលើដីធ្លីមិនប្រើប្រាស់

---

[1] Charles E. McLure, "*Taxation*," Britannica, https://www.britannica.com/topic/taxation (ចូលទស្សនាថ្ងៃទី២៤ សីហា ២០២០)

[2] ដកស្រង់ចេញពីឯកសារបង្រៀនរបស់សាស្ត្រាចារ្យ ឆាយ ជាហេង (ចូលទស្សនាថ្ងៃទី២០ សីហា ២០២០)

- ពន្ធលើឈ្នួលផ្ទះ និងដី
- ពន្ធប្រថាប់ត្រា
- ពន្ធលើមធ្យោបាយដឹកជញ្ជូន
- ពន្ធប៉ាតង់
- ពន្ធតែមប្រ៊ី

• **ពន្ធប្រយោល**

ពន្ធប្រយោល សំដៅដល់ពន្ធទាំងឡាយណាដែលបានអនុវត្តលើទំនិញ ឬសេវា និងត្រូវបានបង់ដោយអ្នកប្រើប្រាស់ទំនិញ ឬសេវាទាំងនោះ តាមរយៈអ្នកជាប់ពន្ធ។

ខាងក្រោមនេះគឺជាពន្ធប្រយោល

- អាករពិសេសលើទំនិញ និង សេវាមួយចំនួន
- អាករលើតម្លៃ
- អាករបំភ្លឺសាធារណៈ
- អាករស្នាក់នៅ
- ពន្ធកាត់ទុក

## ១.៤. របបកំណត់ពន្ធ

ប្រព័ន្ធពន្ធដារកម្ពុជា មុនឆ្នាំ២០១៥ មានរបបពន្ធ ២ របប គឺ៖

• របបពិត (ស្វ័យប្រកាស)
• របបម៉ៅការ

ប៉ុន្តែក្រោយឆ្នាំ២០១៥ រដ្ឋាភិបាលកម្ពុជាអនុវត្តកំណែទម្រង់សារពើពន្ធថ្មីដែលមានរបបកំណត់ពន្ធតែមួយ ដែលរបបនោះ គឺ **របបពិត (ស្វ័យប្រកាស)**។

## ១.៥. ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស[3]

ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសចែកចេញជា៣ប្រភេទគឺៈ

**តារាងទី១ៈ ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស**

| | |
|---|---|
| **អ្នកជាប់ពន្ធតូច** | ក.មានផលរបរប្រចាំឆ្នាំចាប់ពី២៥០លានរៀល ដល់ ៧០០លានរៀល។<br>ខ.មានផលរបរក្នុងរយៈពេល៣ខែជាប់គ្នានាពេលណាមួយដែលបញ្ចប់ក្នុងឆ្នាំប្រតិទិនចរន្តចាប់ពី៦០លានរៀលឡើងទៅ។<br>គ.រំពឹងថាមានផលរបរក្នុងរយៈពេល៣ខែជាប់គ្នាខាងមុខចាប់ពី៦០លានរៀលឡើង។<br>ឃ.ចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ ឬស្ទង់ថ្លៃក្នុងការផ្គត់ផ្គង់ទំនិញ ឬសេវាដែលប្រើប្រាស់ថវិការដ្ឋ រួមទាំងភាស៊ី។ |
| **អ្នកជាប់ពន្ធមធ្យម** | ក.មានផលរបរប្រចាំឆ្នាំ លើសពី៧០០លានរៀល ដល់ ៤០០០លានរៀល<br>ខ.សហគ្រាសដែលបានចុះបញ្ជីជានីតិបុគ្គល<br>គ.ស្ថាប័នរដ្ឋថ្នាក់ក្រោមជាតិ អង្គការ ឬសមាគមគ្រប់ប្រភេទ រួមទាំងអង្គការមិនមែនរដ្ឋាភិបាល<br>ឃ.ស្ថាប័នរដ្ឋ បេសកកម្មទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា។ |
| **អ្នកជាប់ពន្ធធំ** | ក. មានផលរបរប្រចាំឆ្នាំ លើសពី ៤០០០លានរៀល<br>ខ. គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIPs)<br>គ. សាខាក្រុមហ៊ុនបរទេស<br>ឃ.ស្ថាប័នរាជរដ្ឋាភិបាល ស្ថានទូត និងកុងស៊ុល អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិរបស់រដ្ឋាភិបាលនានា។ |

[3] ប្រកាសស្តីពីការសម្រួលចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស, លេខ០២៥សហវ.ប្រក.អពដ,២៤ មករា ២០១៨

# ១.៦. សិទ្ធិ និង ភាតព្វកិច្ចរបស់អ្នកជាប់ពន្ធ[4]

## ១.៦.១. សិទ្ធិរបស់អ្នកជាប់ពន្ធ

- ទទួលបានការរក្សាទុកជាការសម្ងាត់នូវរាល់ព័ត៌មានដែលអ្នកជាប់ពន្ធបានផ្តល់ជូនរដ្ឋបាលសារពើពន្ធ
- ទទួលបានការផ្តល់សេវាប្រកបដោយវិជ្ជាជីវៈ និងការជួយពន្យល់ណែនាំឱ្យបានយល់អំពីកិច្ចដំណើរការនៃប្រព័ន្ធពន្ធដារ នីតិវិធីសារពើពន្ធ និងការអនុវត្តកាតព្វកិច្ចសារពើពន្ធចំពោះកិច្ចការសារពើពន្ធ
- ទទួលបានការពន្យល់រាល់សេចក្តីសម្រេចរបស់រដ្ឋបាលសារពើពន្ធ
- ប្តឹងតវ៉ាចំពោះរាល់សេចក្តីសម្រេចរបស់រដ្ឋបាលសារពើពន្ធ
- បង់ពន្ធមិនឱ្យលើសពីបទប្បញ្ញត្តិស្តីពីពន្ធដារកំណត់
- មានការទទួលស្គាល់តំណាងស្របច្បាប់របស់អ្នកជាប់ពន្ធតាមការជ្រើសរើសដើម្បីផ្តល់យោបល់អំពីកិច្ចការសារពើពន្ធ
- ទទួលបានការអនុវត្តដោយមានតម្លាភាព និងមិនលម្អៀងពីសំណាក់រដ្ឋបាលសារពើពន្ធ
- ទទួលបានការទទួលស្គាល់អំពីភាពស្មោះត្រង់ក្នុងការអនុវត្តកាតព្វកិច្ចសារពើពន្ធ

## ១.៦.២. ភាតព្វកិច្ចរបស់អ្នកជាប់ពន្ធ

- ចុះឈ្មោះក្នុងបញ្ជីរបស់រដ្ឋបាលសារពើពន្ធ
- ដាក់លិខិតប្រកាសសារពើពន្ធ និង ផ្តល់ព័ត៌មានតាមការតម្រូវនៃបទប្បញ្ញត្តិស្តីពីពន្ធដារ
- បង់ពន្ធតាមកាលបរិច្ឆេទកំណត់
- កាន់កាប់ ថែរក្សា និង ត្រូវបង្ហាញបញ្ជី លិខិតយុត្តិការ និងឯកសារផ្សេងៗដល់រដ្ឋបាលសារពើពន្ធ
- បង្ហាញខ្លួនចំពោះរដ្ឋបាលសារពើពន្ធតាមកាលបរិច្ឆេទ ដែលមានចុះនៅក្នុងលិខិតជូនដំណឹងរបស់រដ្ឋបាលសារពើពន្ធ
- បង់ប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងការប្រាក់ផ្សេងៗ ដែលរដ្ឋបាលសារពើពន្ធបានកំណត់ទៅតាមកាលបរិច្ឆេទ ដូចមានចែងនៅក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ ឬដែលរដ្ឋបាលសារពើពន្ធបានជូនដំណឹងជាលាយលក្ខណ៍អក្សរ
- ត្រូវមានភាពស្មោះត្រង់ក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធ
- ត្រូវមានកិច្ចសហប្រតិបត្តិការជាមួយរដ្ឋបាលសារពើពន្ធក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធ

[4] នាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, "សិទ្ធនិងកាតព្វកិច្ចអ្នកជាប់ពន្ធ", ២០១០

## ១.៧. កាលបរិច្ឆេទនៃការដាក់លិខិតប្រកាសពន្ធ និង បង់ប្រាក់ពន្ធ[5]

អ្នកជាប់ពន្ធគ្រប់រូប មានកាតព្វកិច្ចដាក់លិខិតប្រកាសពន្ធ និងបង់ប្រាក់ពន្ធ ទៅតាមកាលកំណត់របស់រដ្ឋបាលសារពើពន្ធ។

- ប្រភេទពន្ធ-អាករមួយចំនួនខាងក្រោមនេះ ត្រូវដាក់លិខិតប្រកាសពន្ធ និងបង់ប្រាក់ពន្ធប្រចាំខែ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ពីខែដែលត្រូវជាប់ពន្ធ៖
  - ពន្ធកាត់ទុកគ្រប់ប្រភេទ
  - ពន្ធលើប្រាក់បៀវត្ស
  - អាករលើតម្លៃបន្ថែម
  - អាករពិសេសលើទំនិញ និង សេវាមួយចំនួន
  - អាករបំភ្លឺសាធារណៈ
  - អាករលើការស្នាក់នៅ
  - ប្រាក់រំដោះពន្ធលើប្រាក់ចំណូល
- ចំពោះពន្ធលើប្រាក់ចំណូល ត្រូវដាក់លិខិតប្រកាសពន្ធ និងបង់ប្រាក់ពន្ធ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣១ ខែមីនា នៃឆ្នាំបន្ទាប់ពីឆ្នាំដែលត្រូវជាប់ពន្ធ។
- ចំពោះពន្ធប៉ាតង់ ត្រូវដាក់លិខិតប្រកាសពន្ធ និងបង់ប្រាក់ពន្ធ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣១ ខែមីនា នៃឆ្នាំនីមួយៗ។

## ១.៨. ការតវ៉ារបស់អ្នកជាប់ពន្ធ

➢ អ្នកជាប់ពន្ធអាចជំទាស់នឹងសេចក្តីសម្រេចផ្សេងៗ ឬអំពើខុសឆ្គងណាមួយរបស់រដ្ឋបាលសារពើពន្ធ ដោយដាក់ពាក្យបណ្តឹងតវ៉ា តាមលំដាប់ថ្នាក់ដូចខាងក្រោម៖
  - ដំបូងដោះស្រាយជាមួយមន្ត្រីពន្ធដារទទួលបន្ទុកកិច្ចការនោះ
  - បន្ទាប់មក ប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ និ អង្គភាពគ្រប់គ្រង
  - បន្ទាប់មក អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ
  - បន្ទាប់មក គណៈកម្មាធិការសម្រុះសម្រួលសារពើពន្ធ
  - បន្ទាប់មក តុលាការ។

[5] ប្រកាសស្តីពីការកែសម្រួលកាលបរិច្ឆេទដាក់លិខិតប្រកាសពន្ធប្រចាំខែ, លេខ១៥៣៩សហវ/ប្រ.ក,២៣ ធ្នូ ២០១៦

- ការជំទាស់ត្រូវមានលក្ខណៈដូចខាងក្រោមៈ
  - សរសេរជាលាយលក្ខណ៍អក្សរ និងពណ៌នាលម្អិតអំពីហេតុផលដែលអ្នកជាប់ពន្ធយល់ថាសេចក្ដីសម្រេចរបស់រដ្ឋបាលសារពើពន្ធមិនទាន់សមស្រប
  - ត្រូវដាក់មករដ្ឋបាលសារពើពន្ធឱ្យបានទាន់ពេលកំណត់ និងតាមអាជ្ញាយុកាលដែលមានចែងក្នុងច្បាប់ស្ដីពីសារពើពន្ធ
  - មានសេចក្ដីប្រកាសថា រាល់ព័ត៌មានដែលមានក្នុងការជំទាស់ និងឯកសារអះអាងទាំងអស់ពិតជាត្រឹមត្រូវប្រាកដមែន
  - ត្រូវចុះហត្ថលេខា និងត្រា ព្រមទាំងកាលបរិច្ឆេទឱ្យបានត្រឹមត្រូវ

រដ្ឋបាលសារពើពន្ធ នឹងពិនិត្យសេចក្ដីសម្រេចដំបូងជាថ្មី ដោយផ្អែកលើព័ត៌មាន និងឯកសារអះអាងដែលបានផ្ដល់ក្នុងលិខិតជំទាស់ និងផ្ដល់នូវសេចក្ដីសម្រេចថ្មីជាលាយលក្ខណ៍អក្សរ

- ខ្លឹមសារបណ្ដឹងតវ៉ាខាងរដ្ឋបាលរបស់អ្នកជាប់ពន្ធ មានដូចខាងក្រោមៈ

ការតវ៉ាខាងរដ្ឋបាលអាចនឹងទទួលយកបាន បើសិនជាក្នុងពាក្យតវ៉ានោះមានខ្លឹមសារដូចខាងក្រោមៈ

- លេខអត្តសញ្ញាណកម្មរបស់អ្នកជាប់ពន្ធដែលធ្វើពាក្យតវ៉ា បើសិនជាមាន
- សេចក្ដីយោងទៅរកការកំណត់សេចក្ដីសម្រេច ឬលទ្ធផលដែលជាកម្មវត្ថុនៃពាក្យតវ៉ា
- ដើមហេតុ ឬអំពើដែលជាកម្មវត្ថុនៃពាក្យតវ៉ា
- ហេតុផលនៃការតវ៉ា
- កាលបរិច្ឆេទ និងហត្ថលេខារបស់អ្នកជាប់ពន្ធ និងហត្ថលេខារបស់តំណាងមានការអនុញ្ញាតរបស់អ្នកជាប់ពន្ធបើសិនមានភាពចាំបាច់។

**<u>បញ្ជាក់៖</u>** ការប្ដឹងតវ៉ានូវរាល់សេចក្ដីសម្រេចរបស់សារពើពន្ធមិនធ្វើអោយបុគ្គលជាប់ពន្ធនោះរួចផុតពីកាតព្វកិច្ចត្រូវបង់ប្រាក់ពន្ធ ពន្ធន្ថែម ការប្រាក់ ឬទោសទណ្ឌផ្សេងៗឡាយ។

## ១.៩.សវនកម្មពន្ធដារ[6]

នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៩ ក្រសួងសេដ្ឋកិច្ច និង ហរិញ្ញវត្ថុ បានចេញសេចក្ដីប្រកាស លេខ២៧០ ស្ដីពី សវនកម្មពន្ធ ដើម្បីអោយដំណើរការនៃការធ្វើសវនកម្មពន្ធ មានការយល់ដឹងបានច្បាស់ជាងមុន ព្រមទាំងធ្វើឱ្យប្រសើរឡើងនូវការបង់ពន្ធ ប្រមូលពន្ធ និងធ្វើឱ្យមជ្ឈដ្ឋានក្នុងការធ្វើអាជីវកម្មប្រកួតប្រជែង មានលក្ខណៈស្មើភាព និងស្មោះត្រង់។

សវនកម្មពន្ធដារ សំដៅដល់ការពិនិត្យបញ្ជាក់លើបញ្ជិកាគណនេយ្យ របាយការណ៍ហិរញ្ញវត្ថុ និង ឯកសារផ្សេងៗដែលពាក់ព័ន្ធនឹងអាជីវកម្មរបស់អ្នកជាប់ពន្ធ ដើម្បីបញ្ជាក់ថាការគណនា ការប្រកាស និងការបង់ប្រាក់ពន្ធ បានត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិស្ដីពីពន្ធដារ។ សវនកម្មពន្ធដារ គឺជាវិធានការដ៏សំខាន់ក្នុងការគ្រប់គ្រង និងប្រមូលពន្ធអោយមានតម្លាភាព និងប្រសិទ្ធភាព ដើម្បីធានាសមធម៌ក្នុងការបង់ពន្ធ។

រដ្ឋបាលសារពើពន្ធ នឹងចាប់អនុវត្តសវនកម្មពន្ធនេះ បន្ទាប់ពីបានធ្វើការជូនដំណឹងដល់អ្នកជាប់ពន្ធក្រោយរយៈពេល១០ថ្ងៃនៃថ្ងៃធ្វើការ ហើយអ្នកជាប់ពន្ធត្រូវប្រគល់នូវឯកសារដែលសវនករពន្ធទាមទារ កុំអោយលើសពី៧ថ្ងៃ។ ករណីពិសេស រដ្ឋបាលសារពើពន្ធ អាចចាប់អនុវត្តសវនកម្មពន្ធដោយមិនមានការជូនដំណឹងជាមុន។ អ្នកជាប់ពន្ធអាចស្នើសុំពន្យារពេលប្រគល់ឯកសារដែលបានស្នើសុំដោយរដ្ឋបាលសារពើពន្ធដើម្បីធ្វើសវនកម្មពន្ធបាន បើសិនជាមានហេតុផលសមរម្យ អាចទទួលយកបាន ប៉ុន្តែមិនត្រូវអោយលើសពីរយៈពេល៣០ថ្ងៃឡើយ។ បើសិនជាអ្នកជាប់ពន្ធ ពុំមានឯកសារប្រគល់អោយទេ នោះនឹងត្រូវប្រឈមមុននឹងពិន័យផ្សេងៗ។

### ១.៩.១. ប្រភេទនៃសវនកម្មពន្ធដារ

យោងតាមប្រកាសលេខ ២៧០ ដែលបានចេញនៅក្នុងថ្ងៃទី១៣ ខែមិនា ឆ្នាំ២០១៩ គេអាចចែកប្រភេទនៃសវនកម្មពន្ធដារ ជា២គឺៈ

- សវនកម្មលើលិខិតស្នាមៈ ធ្វើឡើងនៅទីកន្លែងរដ្ឋបាលសារពើពន្ធ ដោយពិនិត្យវិនិច្ឆ័យលើលិខិតប្រកាសសារពើពន្ធដែលមានភាពមិនប្រក្រតី ឬភាពមិនស៊ីសង្វាក់គ្នាលើលិខិតប្រកាស។
- សវនកម្មពន្ធដល់ទីកន្លែងៈ ជាការចុះធ្វើសវនកម្មដល់ទីតាំងប្រកបអាជីវកម្មរបស់សហគ្រាស ដែលជាកម្មវត្ថុនៃការធ្វើសវនកម្ម ដើម្បីពិនិត្យស្ថានភាពអាជីវកម្មជាក់ស្ដែង បញ្ជិកាគណនេយ្យ លិខិតយុត្តិការ និងឯកសារផ្សេងៗ។ ប្រភេទនេះចែកចេញជា២ គឺៈ

[6] ប្រកាសលេខ ២៧០ សហវ.ប្រក ចុះថ្ងៃទី ១៣ ខែមិនា ឆ្នាំ២០១៩ ស្ដីពីនីតិវិធី នៃការធ្វើសវនកម្មពន្ធដារ ក្នុងគោលបំណងធ្វើឲ្យប្រសើរឡើង និងកំណត់នូវនីតិវិធីនៃការធ្វើសវនកម្មពន្ធដារ

- សវនកម្មមានកម្រិត(Limited Audit) គឺជាការធ្វើសវនកម្មរយៈពេលខ្លី និង ភ្លាមៗទៅលើប្រភេទពន្ធអាករមួយចំនួន វៀរលែងតែពន្ធលើប្រាក់ចំណូល។ សវនកម្មនេះ អាចធ្វើឡើងចំពោះតែរយៈពេលជាប់ពន្ធក្នុងឆ្នាំ (N) និងឆ្នាំជាប់ពន្ធមុនឆ្នាំជាប់ពន្ធចរន្ត(N-1)។
- សវនកម្មពេញលេញ(Comprehensive Audit) គឺជាការចុះធ្វើសវនកម្មទៅលើពន្ធអាករគ្រប់ប្រភេទ។ សវនកម្មនេះធ្វើឡើងក្នុងរង្វង់ ៣ ឆ្នាំជាប់ពន្ធថយក្រោយ (N-3) និង មិនតម្រូវអោយធ្វើគ្រប់ឆ្នាំជាប់ពន្ធ ឬ រយៈពេលជាប់ពន្ធនោះទេ គឺធ្វើឡើងតែឆ្នាំជាប់ពន្ធណា ដែលមានហានិភ័យខ្ពស់ប៉ុណ្ណោះ វៀរលែងតែករណីៈ
  - មានការស្នើសុំពីអ្នកជាប់ពន្ធ
  - មានខាតយោង ឬ ឥណទានយោងពីឆ្នាំជាប់ពន្ធ
  - មានភស្តុតាងថាសហគ្រាសបានគេចវេសពន្ធ

### ១.៩.២. ការជ្រើសរើសសហគ្រាសធ្វើសវនកម្ម

ការជ្រើសរើសសហគ្រាសធ្វើសវនកម្មផ្អែកលើលក្ខខណ្ឌវិនិច្ឆ័យៈ

- ការវិភាគហានិភ័យ
- លទ្ធផលបានមកពីការផ្ទៀងផ្ទាត់ផ្លូវផ្គងព័ត៌មាន
- ព័ត៌មានទទួលបានពីតតិយជន
- ព័ត៌មានអំពីប្រភេទពន្ធ ឬ វិស័យជាក់លាក់ណាមួយ
- ព័ត៌មានរបស់អ្នកជាប់ពន្ធណាមួយ
- ទីតាំងរបស់សហគ្រាស។ល។

## ១.១០. ទោសទណ្ឌសារពើពន្ធ[7]

### ១.១០.១. អំពើរាំងស្ទះការអនុវត្តបទបញ្ញត្តិពន្ធដារ

អំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ រួមមាន:

- មិនបានរក្សាបញ្ជិការគណនេយ្យ និងឯកសារផ្សេងទៀត ឬមិនបានចេញវិក្កយបត្រលើកិច្ចការជំនួញ
- មិនអនុញ្ញាតអោយរដ្ឋបាលសារពើពន្ធធ្វើការពិនិត្យបញ្ជីកាគណនេយ្យ ឬឯកសារផ្សេងៗ
- មិនបានចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ
- មិនបានជូនដំណឹងទៅរដ្ឋបាលសារពើពន្ធអំពីការផ្លាស់ប្តូរក្នុងការចុះបញ្ជី

[7] ច្បាប់ស្តីពីសារពើពន្ធឆ្នាំ១៩៩៧, មាត្រា១២៨

- កសាង ឬផ្តល់នូវកំណត់ត្រា ឯកសារ របាយការណ៍ ឬព័ត៌មានក្លែងបន្លំផ្សេងៗ
- លាក់ទុក ឬបំផ្លាញចោលដោយចេតនានូវបញ្ជីគណនេយ្យ កំណត់ត្រា ឯកសារ របាយការណ៍ ឬព័ត៌មានផ្សេងៗទៀត
- ព្យាយាមធ្វើឱ្យរាំងស្ទះដល់ការកំណត់ពន្ធ និងការប្រមូលពន្ធ
- មិនបានដាក់លិខិតប្រកាសសារពើពន្ធដែលគ្មានការប្រាក់ ពន្ធត្រូវបង់ក្នុងរយៈពេល៣០ថ្ងៃ ក្រោយកាលបរិច្ឆេទដែលច្បាប់បានកំណត់
- ជួយជ្រោមជ្រែងដោយចេតនាដល់អំពើទាំងឡាយខាងលើ

### ១.១០.២. អំពើគេចវេសពន្ធ

អំពើគេចវេសពន្ធរួមមាន៖

- ល្មើសដោយចេតនា ដឹងជាមុន គិតទុកជាមុន ក្នុងគោលបំណងដើម្បីបន្ថយ ឬបំបាត់ប្រាក់ពន្ធ ដែលបទប្បញ្ញត្តិស្តីពីពន្ធដារតម្រូវអោយបង់
- ធ្វេសប្រហែសធ្ងន់ធ្ងរពីរលើក ដាច់ដោយឡែកពីគ្នារយៈពេល៣ឆ្នាំនៃឆ្នាំប្រតិទិន
- ធ្វេសប្រហែសធ្ងន់ធ្ងរបីលើក ឬ ច្រើនលើក ដាច់ដោយឡែកពីគ្នារយៈពេលណាមួយ

## ១.១១ ពន្ធបន្ថែម និង ការប្រាក់[8]

- ពន្ធបន្ថែម ១០% និង ការប្រាក់ ១.៥% ក្នុង១ខែ អនុវត្តទៅលើ
  - ការធ្វេសប្រហែសដោយប្រកាស និង បង់ប្រាក់ពន្ធខ្វះតិចជាង១០%
  - បង់ពន្ធយឺត
- ពន្ធបន្ថែម ២៥% និង ការប្រាក់ ១.៥% ក្នុង១ខែ អនុវត្តទៅលើ
  - ការធ្វេសប្រហែសធ្ងន់ធ្ងរដោយប្រកាស និង បង់ប្រាក់ពន្ធខ្វះច្រើនជាង១០%
- ពន្ធបន្ថែម ៤០% និង ការប្រាក់ ១.៥% ក្នុង១ខែ អនុវត្តទៅលើ
  - ក្នុងករណីដែលអ្នកជាប់ពន្ធ ឬ ភ្នាក់ងារកាត់ទុក មានកាតព្វកិច្ចដាក់លិខិតប្រកាសសារពើពន្ធ ប៉ុន្តែមិនបានធ្វើលិខិតប្រកាស មិនបានរក្សាទុកឱ្យបានត្រឹមត្រូវនូវបញ្ជិកាគណនេយ្យឬឯកសារផ្សេងៗទៀតតាមការតម្រូវ ឬមិនបានផ្តល់ពត៌មានចាំបាច់ជូនរដ្ឋបាលសារពើពន្ធ ដើម្បីកំណត់ពន្ធឱ្យបាន

[8] ប្រកាសលេខ ២៧០ សហវ.ប្រក ចុះថ្ងៃទី ១៣ ខែមិនា ឆ្នាំ២០១៩ ស្តីពីនីតិវិធី នៃការធ្វើសវនកម្មពន្ធដារ ក្នុងគោលបំណងធ្វើឲ្យប្រសើរឡើង និងកំណត់នូវនីតិវិធីនៃការធ្វើសវនកម្មពន្ធដារ

ត្រឹមត្រូវ ការកំណត់ពន្ធរបស់អ្នកជាប់ពន្ធ ឬ ភ្នាក់ងារកាត់ទុក គឺជាការកំណត់ពន្ធជាឯកតោភាគី ដែលរដ្ឋបាលសារពើពន្ធបានធ្វើ និង បានប្រគល់ឲ្យបុគ្គលនោះ។

## ១.១២. ប្រភេទពន្ធសំខាន់ៗមួយចំនួន

### ១.១២.១ពន្ធប៉ាតង់[9]

**ក. និយមន័យ**

ពន្ធប៉ាតង់ គឺជាប្រភេទពន្ធប្រចាំឆ្នាំដែលអ្នកជាប់ពន្ធមានកាតព្វកិច្ចបង់ទៅតាមសកម្មភាពអាជីវកម្ម និង កម្រិតផលរបររបស់ខ្លួន។ អ្នកជាប់ពន្ធដែលមានសកម្មភាពអាជីវកម្មច្រើន ត្រូវបង់ពន្ធប៉ាតង់ផ្សេងគ្នាទៅតាមសកម្មភាពអាជីវកម្មនីមួយៗ។

**ខ. បែបបទនៃការបង់ពន្ធ**

- អ្នកជាប់ពន្ធដែលមានសកម្មភាពអាជីវកម្មច្រើនត្រូវបង់ពន្ធប៉ាតង់ផ្សេងគ្នាទៅតាមសកម្មភាពអាជីវកម្មនីមួយៗ
- សកម្មភាពឧបសម្ព័ន្ធនានានៃសកម្មភាពអាជីវកម្ម ត្រូវបានចាត់ទុកថាជាសកម្មភាពតែមួយ
- អ្នកជាប់ពន្ធដែលមានសាខា ឃ្លាំង រោងចក្រ រោងជាង សម្រាប់សកម្មភាពអាជីវកម្មតែមួយនៅក្នុងរាជធានី-ខេត្តតែមួយ ត្រូវបង់ប៉ាតង់តែមួយ
- អ្នកជាប់ពន្ធដែលមានសកម្មភាពអាជីវកម្មនៅក្នុងរាជធានី-ខេត្តផ្សេងគ្នា ត្រូវបង់ពន្ធប៉ាតង់ទៅតាមរាជធានី-ខេត្តដែលអាជីវកម្មនោះស្ថិតនៅ
- អ្នកជាប់ពន្ធធំដែលមានសាខា ឃ្លាំង រោងចក្រ រោងជាង សម្រាប់សកម្មភាពអាជីវកម្មតែមួយដែលស្ថិតនៅតាមរាជធានី-ខេត្តផ្សេងគ្នា ត្រូវបង់ពន្ធប៉ាតង់ចំនួន ៣ ០០០ ០០០ រៀល ទៅតាមរាជធានី-ខេត្ត ដែលអាជីវកម្មនោះស្ថិតនៅ។

**គ. កម្រិតប្រាក់ពន្ធប៉ាតង់ត្រូវបង់**[10]

ប្រាក់ពន្ធប៉ាតង់ ត្រូវបានកំណត់តាមចំណាត់ថ្នាក់នៃអ្នកជាប់ពន្ធ៖

- អ្នកជាប់ពន្ធតូច ត្រូវបង់ពន្ធប៉ាតង់ប្រចាំឆ្នាំចំនួន ៤០០ ០០០ រៀល
- អ្នកជាប់ពន្ធមធ្យម ត្រូវបង់ពន្ធប៉ាតង់ប្រចាំឆ្នាំចំនួន ១ ២០០ ០០០ រៀល
- អ្នកជាប់ពន្ធធំដែលមានផលរបរដូចខាងក្រោម៖

[9] ប្រកាសស្តីពីវិធាន និង នីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់, លេខ ១៨២១ សហវ. ប្រក, ២៥ ធ្នូ ២០១៥

[10] សេចក្តីជូនដំណឹងស្តីពីការដាក់លិខិតប្រកាស និង បង់ពន្ធប៉ាតង់ ប្រចាំឆ្នាំ២០១៨, លេខ ៣៦២១ អពដ, ១៦ មីនា ២០១៨

- ៤ ០០០លានរៀល ដល់ ១០ ០០០លានរៀល ត្រូវបង់ពន្ធប៉ាតង់ប្រចាំឆ្នាំ ចំនួន ៣ ០០០ ០០០ រៀល
- លើសពី ១០ ០០០ លានរៀល ត្រូវបង់ពន្ធប៉ាតង់ប្រចាំឆ្នាំ ចំនួន ៥ ០០០ ០០០រៀល

**ឃ. កាលបរិច្ឆេទបង់ពន្ធ**

ពន្ធប៉ាតង់ ត្រូវបង់នៅរដ្ឋបាលសារពើពន្ធដែលអ្នកជាប់ពន្ធមានទីកន្លែងប្រកបអាជីវកម្មពិតប្រាកដ ក្នុងអំឡុងពេលចាប់ពីថ្ងៃទី១ ខែមករា ដល់ ថ្ងៃទី៣១ ខែមីនា ជារៀងរាល់ឆ្នាំ។

ចំពោះអាជីវកម្មថ្មី ត្រូវបង់នៅពេលចាប់ផ្តើមអាជីវកម្ម៖

- បង់ពន្ធប៉ាតង់ពេញ១ឆ្នាំ ប្រសិនបើចាប់ផ្តើមប្រកបអាជីវកម្មក្នុង៦ខែ ដើមឆ្នាំ
- បង់ពន្ធប៉ាតង់ពាក់កណ្តាល ប្រសិនបើចាប់ផ្តើមប្រកបអាជីវកម្មក្នុង៦ខែ ចុងឆ្នាំ

**ខ. ប័ណ្ណប៉ាតង់**

ប័ណ្ណប៉ាតង់ មានតម្លៃតែចំពោះអ្នកជាប់ពន្ធដែលមានឈ្មោះក្នុងប័ណ្ណប៉ាតង់ប៉ុណ្ណោះ។ ចំពោះអាជីវកម្មដែលបានបង់ពន្ធប៉ាតង់ហើយ ត្រូវបង់ពន្ធប៉ាតង់ថ្មីម្តងទៀត ប្រសិនបើ ផ្លាស់ប្តូរទីកន្លែងទៅរាជធានី-ខេត្តផ្សេង ឬ ផ្លាស់ប្តូរមុខរបរអាជីវកម្មថ្មី។

ការចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ ឬ ស្នង់ថ្លៃ ក្នុងការផ្គត់ផ្គង់ទំនិញ ឬ សេវា ត្រូវមានប័ណ្ណប៉ាតង់ដែលមានសកម្មភាពស្របនឹងកម្មវត្ថុទាំងនោះ។ អ្នកជាប់ពន្ធ ត្រូវដាក់តាំងបង្ហាញប័ណ្ណប៉ាតង់ដែលមាន សុពលភាព នៅតាមទីតាំងប្រកបអាជីវកម្មរបស់ខ្លួន។

**ច. ការផ្លាស់ប្តូរម្ចាស់អាជីវកម្ម**

ចំពោះអាជីវកម្មដែលបានបង់ពន្ធប៉ាតង់ហើយ ត្រូវបង់ពន្ធប៉ាតង់ជាថ្មីទៀត ប្រសិនបើមានការផ្លាស់ប្តូរម្ចាស់ តែលើកលែងមិនបាច់ពន្ធប៉ាតង់ជាថ្មីទៀតទេ ប្រសិនមានគ្រប់លក្ខណៈពីរខាក្រោមនេះ៖

- មិនផ្លាស់ប្តូរសកម្មភាពអាជីវកម្ម
- ម្ចាស់ថ្មីជាឪពុក ម្តាយ ប្តី ប្រពន្ធ កូន ឬ អ្នកស្នងស្របច្បាប់របស់ម្ចាស់អាជីវកម្មចាស់។

### **១.១២.២ អាករលើតម្លៃបន្ថែម (អតប)**[11]

អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដែលធ្វើការផ្គត់ផ្គង់ជាប់អាករ ត្រូវមានកាតព្វកិច្ចចុះបញ្ជីអ.ត.ប និងប្រមូលអាករលើតម្លៃបន្ថែមលើការផ្គត់ផ្គង់ទំនិញឬសេវាឱ្យអតិថិជន។ ទំនិញ សំដៅដល់ទ្រព្យរូបី ក្រៅពី ដីធ្លី និងប្រាក់កាស រីឯសេវា សំដៅដល់ការផ្តល់អ្វីមួយដែលមានតម្លៃ ក្រៅពីទំនិញ ដីធ្លី និងប្រាក់កាស។

**ក. និយមន័យ**

អាករពិសេសលើតម្លៃបន្ថែម គឺជាប្រភេទពន្ធប្រយោលដែលគិតលើតម្លៃបន្ថែម (លក់ដកទិញ) របស់ទំនិញ ឬសេវាដែលបានឆ្លងកាត់តាមដំណាក់នីមួយៗ នៃការផ្គត់ផ្គង់ទំនិញ និងសេវា។ អតបជួយសម្រួលដល់អ្នកប្រកបអាជីវកម្ម មិនអោយបង់ពន្ធត្រួតគ្នា នៅលើចង្វាក់ផលិតកម្មនីមួយៗ ឬដំណាក់កាលអាជីវកម្ម។ អតប មិនមែនជាបន្ទុករបស់សហគ្រាសដែលប្រកបអាជីវកម្មទេ។

- **ពេលផ្គត់ផ្គង់ទំនិញ ឬសេវា គឺជាពេលដែល**
  - អ្នកផ្គត់ផ្គង់ត្រូវចេញវិក្កយបត្រ ឬបានចេញវិក្កយបត្រ ប្រសិនបើវិក្កយបត្រត្រូវបានចេញមុនពេលត្រូវចេញ។ អ្នកផ្គត់ផ្គង់ ត្រូវចេញវិក្កយបត្រអតប យ៉ាងយឺត៧ថ្ងៃក្រោយការបញ្ជូនទំនិញ ឬការបំពេញសេវា ឬការទូទាត់ប្រាក់ ក្នុងករណីដែលការទូទាត់ត្រូវបានធ្វើឡើងមុនការបញ្ជូនទំនិញ ឬការបំពេញសេវា
  - ក្នុងករណីដកប្រើប្រាស់ខ្លួនឯង ពេលផ្គត់ផ្គង់ គឺជាពេលដែលទំនិញ ត្រូវបានយកមកប្រើប្រាស់ដំបូង
  - ក្នុងករណីជាអំណោយ ពេលផ្គត់ផ្គង់ គឺជាពេលដែលទំនិញត្រូវបានប្រគល់អោយ ឬ ពេលដែលសេវាផ្គត់ផ្គង់ត្រូវបានបំពេញរួចរាល់។
  - ការនាំចូលទំនិញ ពេលផ្គត់ផ្គង់ គឺជាពេលដែលអ្នកនាំចូលដាក់លិខិតប្រកាស ហើយពន្ធគយ និងអាករនាំចូលនានា ត្រូវបានបង់។
  - គឺជាកាលបរិច្ឆេទមុនគេ ក្នុងចំណោមកាលបរិច្ឆេទដែលការទូទាត់ត្រូវដល់កំណត់និងកាលបរិច្ឆេទដែលបានទទួលការទូទាត់ ក្នុងករណីដែល៖
    - ភតិសន្យាហិរញ្ញវត្ថុ
    - ទំនិញ ត្រូវបានផ្គត់ផ្គង់ក្រោមកិច្ចសន្យាជួល
    - ទំនិញ ឬសេវាត្រូវបានផ្គត់ផ្គង់ក្រោមកិច្ចសន្យាដែលចែងអំពីការទូទាត់ច្រើនលើក ឬជាប់ជាបន្ត

[11] អនុក្រឹត្យស្តីពីអាករលើតម្លៃបន្ថែម,លេខ ១១៤ អនក្រ.បក, ២៤ ធ្នូ ១៩៩៩

**ខ. ការផ្គត់ផ្គង់ជាប់អាករ**

ការផ្គត់ផ្គង់ជាប់អាករសំដៅដល់:

- ការផ្គត់ផ្គង់ទំនិញ ឬសេវាដោយបុគ្គលជាប់អាករនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ការដកយកទំនិញមកប្រើប្រាស់ផ្ទាល់ខ្លួនដោយបុគ្គលជាប់អាករ
- ការផ្តល់ជាអំណោយ ឬការផ្គត់ផ្គង់ក្រោមតម្លៃពិត នូវទំនិញ ឬសេវាដោយបុគ្គលជាប់អាករ
- ការនាំចូលទំនិញមកក្នុងតំបន់ត្រួតពិនិត្យគយនៃព្រះរាជាណាចក្រកម្ពុជា

**គ. ការផ្គត់ផ្គង់មិនជាប់អាករ**[12]

ការផ្គត់ផ្គង់មិនជាប់អាករមានដូចតទៅ៖

- សេវាប្រៃសណីយ៍សាធារណៈ
- សេវារបស់មន្ទីរពេទ្យនិងគ្លីនិក សេវាខាងវេជ្ជសាស្ត្រនិងទន្តសាស្ត្រ និងការលក់ទំនិញបន្ទាប់បន្សំខាងវេជ្ជសាស្ត្រ និងទន្តសាស្ត្រដែលទាក់ទិននឹងការបំពេញសេវាទាំងនេះ
- សេវាដឹកជញ្ជូនអ្នកដំណើរដោយប្រព័ន្ធដឹកជញ្ជូនសាធារណៈដែលជាកម្មសិទ្ធិទាំងស្រុងរបស់រដ្ឋ
- សេវាធានារ៉ាប់រង
- សេវាជាមូលដ្ឋានខាងហិរញ្ញវត្ថុដែលត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ការនាំចូលសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនដែលរួចពន្ធគយ ក្នុងកម្រិតតំលៃដែលត្រូវកំណត់ដោយប្រកាសរបស់ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សកម្មភាពមិនស្វែងរកចំណេញដើម្បីបំរើផលប្រយោជន៍សាធារណៈ ដែលបានទទួលស្គាល់ដោយរដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ការនាំចូល និងការទិញទំនិញសម្រាប់ ឬដោយបេសកកម្មទូតនិងកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារ សហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា សម្រាប់យកមកប្រើនៅក្នុងការបំពេញមុខងារជាផ្លូវការរបស់ខ្លួន
- សេវាសិក្សាអប់រំ
- ផលិតផលកសិកម្មមិនទាន់កែច្នៃ (ដាំដុះក្នុងស្រុក)
- ថាមពលអគ្គិសនី ទឹកស្អាត
- សេវាប្រមូល ឬសម្អាតកាកសំណល់រឹង-រាវ

[12] ប្រកាសស្តីពីការណែនាំអនុវត្តអាករលើតម្លៃបន្ថែមចំពោះការផ្គត់ផ្គង់មិនជាប់អាករ, លេខ៥៥៩ សហវ/ប្រក, ២៥ ឧសភា ២០១៧

- អាហារជាមូលដ្ឋានសម្រាប់ការរស់នៅប្រចាំថ្ងៃ
- ការផ្គត់ផ្គង់ជីកសិកម្ម ពូជដំណាំ បសុឧសថ ចំណីសត្វ ពូជសត្វ គ្រឿងយន្ត និង ឧបករណ៍កសិកម្ម (ជាបន្ទុករបស់រដ្ឋ)។

**ឃ. អាករលើធាតុចូល និង អាករលើធាតុចេញ**

❖ **អាករលើធាតុចូល**

ទំនិញ ឬសេវា ទិញ សម្រាប់អាជីវកម្ម ហៅថា**ធាតុចូល** ហើយអាករបង់លើការទិញទំនិញ និងសេវា ហៅថា **អាករលើធាតុចូល**។

➢ **អាករលើធាតុចូលដែលស្នើសុំជាឥណទានបាន**

- លក្ខខណ្ឌក្នុងការស្នើសុំ ឥណទានអតប
  - ទំនិញ និងសេវា ត្រូវទិញដើម្បីធ្វើការលក់ជាប់អាករ ឬសម្រាប់ប្រើប្រាស់ដើម្បីធ្វើការផ្គត់ផ្គង់ជាប់អតប
  - ប្រតិវេទន៍គយសម្រាប់ការនាំចូលដែលបានបញ្ជាក់ត្រឹមត្រូវ
  - វិក្កយបត្រអាករសម្រាប់ការទិញក្នុងស្រុក ពីអ្នកផ្គត់ផ្គង់ចុះបញ្ជីអតប
  - ពាក្យស្នើសុំត្រូវធ្វើឡើងតាមទម្រង់កំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ
  - ត្រូវមានឯកសារភស្តុតាងត្រឹមត្រូវច្បាស់លាស់ បញ្ជាក់ថាបានបង់អតប ពិតមែន
- ឥណទានអាករ ត្រូវបានអនុញ្ញាតជាឥណទានអាករលើធាតុចូលសម្រាប់អតបបង់លើ ៖
  - រាល់ការផ្គត់ផ្គង់ដែលបានទទួលក្នុងខែ
  - រាល់ការនាំចូលទំនិញដោយបុគ្គលជាប់អាករនៅក្នុងខែ
- ឥណទានអតប អនុញ្ញាតបាន លុះត្រាតែការផ្គត់ផ្គង់ ឬទំនិញនាំចូលជាប់អតបនោះទាក់ទិននឹងសកម្មភាពអាជីវកម្មជាប់អតប។

➢ **អាករលើធាតុចូលដែលស្នើសុំជាឥណទានមិនបាន**

- អតបបង់លើការទិញ ឬនាំចូលរថយន្ត លើកលែងតែបុគ្គលជាប់អតបប្រកបអាជីវកម្មលក់ ឬជួលរថយន្ត។ ពាក្យ រថយន្ត សំដៅដល់រថយន្តសម្រាប់តែដឹកមនុស្សដែលមានកន្លែងអង្គុយមិនលើសពី ១០។

- អតប បង់លើចំណាយទទួលភ្ញៀវ ការកំសាន្ត ឬការសម្រាកលំហែ លើកលែងតែបុគ្គលជាប់អតប មានអាជីវកម្មជាអ្នកផ្គត់ផ្គង់ការទទួលភ្ញៀវ ការកំសាន្ត ឬការសម្រាកលំហែ។ ពាក្យ ទទួលភ្ញៀវ មានន័យថា ការផ្គត់ផ្គង់អាហារ ភេសជ្ជៈ ថ្នាំជក់ កន្លែងស្នាក់អាស្រ័យ ឬបដិសណ្ឋារកិច្ចណាមួយ។
- អតប បង់លើការទិញ ឬនាំចូលផលិតផលតេលសិលាមួយចំនួន លើកលែងតែបុគ្គលជាប់អតប ប្រកបអាជីវកម្មជាអ្នកផ្គត់ផ្គង់ផលិតផលតេលសិលាទាំងនោះ។ ផលិតផលតេលសិលា សំដៅដល់ ប្រេងសាំងធម្មតា ប្រេងសាំងស៊ុបពែ ប្រេងម៉ាស៊ូត និងប្រេងរំអិល។
- អតប បង់លើសេវាទូរស័ព្ទចល័ត។

❖ **អាករលើធាតុចេញ**

ទំនិញ ឬសេវាផ្គត់ផ្គង់អោយអតិថិជន ហៅថាធាតុចេញ ហើយអាករដែលប្រមូលលើការផ្គត់ផ្គង់ទំនិញ ឬ សេវា ហៅថា**អាករលើធាតុចេញ**។

**ខ. អត្រាពន្ធ និង មូលដ្ឋានគណនាប្រាក់ពន្ធ**

- **អត្រាអាករលើតម្លៃបន្ថែមមាន:**
  - ១០% សម្រាប់ការនាំចូលឬការផ្គត់ផ្គង់ទំនិញឬសេវាក្នុងព្រះរាជាណាចក្រកម្ពុជា
  - 0% សម្រាប់ការនាំចេញ
- **មូលដ្ឋានគិតអាករ**
  - ការផ្គត់ផ្គង់ទំនិញ ឬសេវា ត្រូវគិតលើថ្លៃទិញ ឬសេវា ដែលអ្នកផ្គត់ផ្គង់គិតពីអតិថិជន
  - ការផ្តល់ជាអំណោយ ឬលក់ក្រោមតម្លៃពិត ត្រូវគិតលើតម្លៃទីផ្សារ
  - ទំនិញនាំចូល = CIF + ពន្ធគយ + អាករពិសេស (ប្រសិនបើមាន)
- **ការគណនាប្រាក់អាករត្រូវបង់៖**
  - ប្រាក់អាករត្រូវបង់ = អាករលើធាតុចេញ - អាករលើធាតុចូល

អ្នកជាប់ពន្ធដែលធ្វើការផ្គត់ផ្គង់ជាប់អាករនូវទំនិញឬសេវា ត្រូវទទួលខុសត្រូវក្នុងការបង់ប្រាក់អាករជូនរដ្ឋបាលសារ ពើពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ពីខែដែលមាន ការផ្គត់ផ្គង់។

### ១.១២.៣. អាករស្នាក់នៅ

**ក. និយមន័យ**

អាករស្នាក់នៅ អនុវត្តទៅលើភ្ញៀវស្នាក់នៅក្នុងកន្លែងជាប់អាករ ហើយអាករនេះប្រមូលដោយម្ចាស់ ឬ អ្នកតំណាងសណ្ឋាគារ។ កន្លែងស្នាក់នៅជាប់អាករ មានដូចជា៖

- សណ្ឋាគារស្វីត
- សណ្ឋាគារ
- សណ្ឋាគារអាផាតមិន
- សណ្ឋាគាររីសត
- ម៉ូតែល
- ឡូដ
- បឹងកាឡូ
- ផ្ទះសំណាក់
- កន្លែងបោះជំរុំទេសចរណ៍...។

**ខ. អត្រាអាករ**[13]

អាករលើការស្នាក់ត្រូវបានកំណត់តាមអត្រា ២% លើការស្នាក់នៅក្នុងកន្លែងស្នាក់នៅជាប់អាករ ក្នុងព្រះរាជាណាចក្រកម្ពុជា។

**គ. ការគណនាអាករ**

- មូលដ្ឋានគិតអាករ = ថ្លៃបន្ទប់ + ពន្ធអាករ + បន្ទុកផ្សេងៗ (service charge)
- អាករស្នាក់នៅ = មូលដ្ឋានអាករ x ២%

[13] ប្រកាសស្តីពីការអនុវត្តអាករលើការស្នាក់នៅ, លេខ៣៨០សហវ/ពដ, ១៤ កក្កដា ២០០៥

### ១.១២.៤. ពន្ធកាត់ទុក[14]

**ក. និយមន័យ**

ពន្ធកាត់ទុក គឺជាពន្ធដែលត្រូវបានកាត់ទុកដោយអ្នកជាប់ពន្ធនិវាសនជនលើការទូទាត់មួយចំនួនដែលធ្វើឡើងជាសាច់ប្រាក់ ឬជាវត្ថុអោយទៅអ្នកជាប់ពន្ធនិវាសនជន និង អនិវាសនជន។

**ខ. អត្រាពន្ធ**

- **ពន្ធកាត់ទុកលើការទូទាត់ទៅអោយនិវាសនជន**

ពន្ធកាត់ទុកលើការទូទាត់ទៅអោយនិវាសនជន ប្រើប្រាស់អត្រាដូចក្នុងតារាងខាងក្រោម៖

**តារាងទី២៖ អត្រាពន្ធកាត់ទុកទូទាត់ទៅអោយនិវាសនជន**

| អត្រាពន្ធ | កម្មវត្ថុ |
|---|---|
| ១៥% | • ការបំពេញសេវានានា<br>• ការប្រាក់<br>• សួយសារពីទ្រព្យសកម្មអរូបី និង សួយសារ ភាគកម្ម ក្នុងធនធានរ៉ែ។ |
| ១០% | • ការជួលចលនទ្រព្យ ឬ អចលនទ្រព្យ |
| ៦% | • ការប្រាក់ដែលធនាគារ ឬ ស្ថាប័នសញ្ជ័យធនក្នុងស្រុកបង់អោយទៅអ្នកជាប់ពន្ធនិវាសនជនដែលមានគណនីបញ្ញើមានការកំណត់ (FixedAccount Deposit)។ |
| ៤% | • ការប្រាក់ដែលធនាគារ ឬ ស្ថាប័នសញ្ជ័យធនក្នុងស្រុកបង់អោយទៅអ្នកជាប់ពន្ធនិវាសនជនដែលមានប្រាក់បញ្ញើនៅក្នុងគណនីសន្សំគ្មានកាលកំណត់ (Saving Account Deposit)។ |

- **ពន្ធកាត់ទុកលើការទូទាត់ទៅអោយអនិវាសនជន**[15]

អត្រាពន្ធកាត់ទុកទូទាត់ទៅអោយអនិវាសនជន គឺ១៤% ចំពោះការទូទាត់ប្រាក់ចំណូលប្រភពកម្ពុជាតាមមាត្រាទី៣៣ថ្មី លើកលែងតែជានាវ៉ាប់រ៉ងបន្តចំពោះហានិភ័យនៅក្នុងកម្ពុជា។

[14] អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, "សៀវភៅណែនាំស្តីពីពន្ធកាត់ទុកលើនិវាសនជននិងអនិវាសនជន", ២០១៣

[15] ប្រកាសស្តីពិការកែសម្រួលការណែនាំអនុវត្តពន្ធកាត់ទុកលើការបែងចែកភាគលាភ, លេខ៣៧២ សហវ. ប្រក, ០៥ មេសា ២០១៩

**គ. ការលើកលែងការកាត់ទុកប្រាក់ពន្ធ**[16]

១. ការបើកប្រាក់ ឬការទូទាត់ជាសាច់ប្រាក់ ឬជាវត្ថុ ត្រូវបានអនុញ្ញាតអោយលើកលែងកពន្ធកាត់ទុក ចំពោះករណីដូចជា៖

- ការប្រាក់ដែលបង់ទៅអោយធនាគារក្នុងស្រុក និងស្ថាប័នសញ្ច័យធនក្នុងស្រុក
- ការបើក ឬទូទាត់អោយរាជរដ្ឋាភិបាល ឬស្ថាប័ននៃរាជរដ្ឋាភិបាល នូវសួយសារ ឬប្រាក់ឈ្នួលលើចលនទ្រព្យ ឬអចលនទ្រព្យរួមទាំង ឡូត៍នេសាទ ព្រៃគុប កំពង់ដរ ភាស៊ីផ្សារ...។
- ការបើក ឬទូទាត់ប្រាក់ចំណូលដែលជាប់ពន្ធលើប្រាក់បៀវត្ស ឬពន្ធលើអត្ថប្រយោជន៍បន្ថែម
- ការបើក ឬទូទាត់នូវការប្រាក់ ដោយរាជរដ្ឋាភិបាល ឬស្ថាប័នរាជរដ្ឋាភិបាលទៅអោយបុគ្គលអនិវាសនជន ចំពោះប្រាក់ខ្ចីដែលរាជរដ្ឋាភិបាល ឬរដ្ឋមន្រ្តីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានទទួលស្គាល់ និងយល់ព្រម។
- ការទូទាត់ចំពោះការផ្គត់ផ្គង់សេវាណាមួយក្រោម ៥០,០០០រៀល
- ប្រាក់ចំណូលរបស់អង្គការណាមួយដែល ៖
  - ត្រូវបានរៀបចំឡើង និងដំណើរការ សម្រាប់គោលដៅសុទ្ធសាធខាងសាសនា សប្បុរសធម៌ វិទ្យាសាស្ត្រ អក្សរសាស្ត្រ ឬអប់រំ។
  - គ្មានចំណែកណាមួយនៃទ្រព្យ ឬប្រាក់ចំណូល ត្រូវបានប្រើប្រាស់ជាផលប្រយោជន៍ ឯកជន។
- ប្រាក់ចំណូលរបស់អង្គការពលករ ឬសភាពាណិជ្ជកម្ម ឧស្សាហកម្ម ឬកសិកម្ម ក្នុងករណីដែលប្រាក់ចំណូល របស់អង្គការទាំងនោះមិនត្រូវបានប្រើប្រាស់ជាផលប្រយោជន៍ឯកជនរបស់អ្នកចូលហ៊ុន ឬរូបវន្តបុគ្គល។

២.ការទូទាត់ជាសាច់ប្រាក់ ឬជាវត្ថុក្នុងចំណោមអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវបានលើកលែងពីពន្ធកាត់ទុក ចំពោះករណីដូចខាងក្រោម៖

- ប្រាក់ចំណូលពីការបំពេញសេវានានា រួមទាំងការគ្រប់គ្រង ឬការពិគ្រោះយោបល់ ឬសេវាប្រហាក់ប្រហែល
- ប្រាក់ចំណូលពីការផ្គត់ផ្គង់៖
  - កញ្ចប់សូហ្វវែរដែលអនុញ្ញាតឲ្យប្រើប្រាស់ដោយភ្ជាប់លក្ខខណ្ឌ
  - សូហ្វវែរសម្រាប់ប្រើប្រាស់ដោយអង្គភាពមានការកំណត់

[16] ប្រកាសស្ដីពីពន្ធលើប្រាក់ចំណូល, លេខ០៩៨ សហវ ប្រ.ក, ២៩ មករា ២០២០

- សូហ្វវែរដែលអាចទាញយកមកប្រើប្រាស់
- សូហ្វវែរដែលភ្ជាប់ជាមួយកុំព្យូទ័រ

- ប្រាក់ចំណូលពីការជួលចលនទ្រព្យ ឬអចលនទ្រព្យ

សម្រាប់ករណីដូចមានចែងក្នុងផ្នែកទី២នេះ ការទូទាត់ណាមួយដែលត្រូវបានអនុញ្ញាតឲ្យលើកលែងពន្ធកាត់ទុកលុះណាតែចំនួនទឹកប្រាក់នោះត្រូវបានកត់ត្រាកនុងវិក្កយបត្រ ដែលបានចេញយ៉ាងត្រឹមត្រូវដោយភាគីអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសម្ខាងទៀត។

**ខ. ការគណនាទឹកប្រាក់ពន្ធកាត់ទុក**

ចំនួនទឹកប្រាក់ពន្ធកាត់ទុក ត្រូវគណនាលើចំនួនទឹកប្រាក់ដែលត្រូវទូទាត់អោយបុគ្គលណាមួយ នៅមុនពេលកាត់ទុកប្រាក់ពន្ធ។

**១.១២.៥. ពន្ធលើប្រាក់បៀវត្ស**[17]

**ក. និយមន័យ**

ពន្ធលើប្រាក់បៀវត្ស គឺជាការកំណត់លើប្រាក់បៀវត្សដែលបានទទួលក្នុងក្របខណ្ឌនៃការបំពេញសកម្មភាពបម្រើការងារដែលទទួលបានប្រចាំខែ។ ប្រភពចំណូលបៀវត្សទាំងអស់មាន ដូចជា បៀវត្ស ប្រាក់បំណាច់ ប្រាក់ម៉ោងបន្ថែម លាភការ បុព្វលាភ ប្រាក់ប៉ះប៉ូវនានា និងអត្ថប្រយោជន៍បន្ថែមជាប់ពន្ធក្នុងអត្រា ២០% ដែលបានទូទាត់ឲ្យដល់និយោជិត ឬដែលបានទូទាត់ដើម្បីប្រយោជន៍ផ្ទាល់ ឬប្រយោលដល់និយោជិតចំពោះការបំពេញសកម្មភាពបម្រើការងារ។

ដើម្បីកំណត់ថាជានិយោជិតហើយត្រូវជាប់ពន្ធលើប្រាក់បៀវត្ស ត្រូវមានស្ថានភាពបម្រើការងារស្របតាមលក្ខខណ្ឌ២ ក្នុងចំណោមលក្ខខណ្ឌដូចខាងក្រោម៖

- មិនមានហានិភ័យនៃការទទួលប្រាក់ទូទាត់
- មិនអាចកំណត់ពេលវេលា ទីកន្លែងសម្រាប់បំពេញការងារ
- មិនចំណាយដើមទុនច្រើន ដើម្បីទិញឧបករណ៍សម្រាប់បំពេញការងារ
- មិនបំពេញសកម្មភាពឱ្យបុគ្គលច្រើននាក់ក្នុងពេលតែមួយ

**សម្រាប់គោលដៅនៃបទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់បៀវត្ស**

**១. និវាសនជន៖** ត្រូវមានលក្ខណៈវិនិច្ឆ័យចាប់ពី១ឡើងទៅនូវចំណុចខាងក្រោម៖

- មាននិវាសនដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជា

[17] ប្រកាសស្តីពីពន្ធលើប្រាក់បៀវត្ស, លេខ ១១៧៣ សហវ/ ពដ/ប្រក, ៣១ ធ្នូ ២០០៣

- មានកន្លែងស្នាក់នៅជាគោលដើមនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- មានវត្តមាននៅក្នុងកម្ពុជាលើសពី ១៨២ថ្ងៃ នៅក្នុងរយៈពេល១២ខែ ណាមួយដែលបានបញ្ចប់ក្នុងឆ្នាំសារពើពន្ធចរន្ត។

និវាសនជន ត្រូវជាប់ពន្ធលើប្រាក់បៀវត្សប្រភពកម្ពុជា និងប្រាក់បៀវត្សប្រភពបរទេស។

**២. អនិវាសនជន៖** បុគ្គលណាមួយដែលមិនមែនជានិវាសជន និងទទួលប្រាក់បៀវត្សប្រភពកម្ពុជា។

**ខ. ប្រាក់បៀវត្សលើកលែងពន្ធ**

- **ប្រាក់បៀវត្សរបស់មន្ត្រីការទូត និងមន្ត្រីបរទេសដទៃទៀត៖**

បដិការរវាងរដ្ឋាភិបាលដែលពាក់ព័ន្ធ និងត្រូវបានកំណត់ដូចតទៅ៖

- ប្រាក់បៀវត្សដែលមន្ត្រី និងនិយោជិតនៃបេសកម្មទូត ឬកុងស៊ុលរបស់រាជរដ្ឋាភិបាលបរទេសណាមួយ ដែលកាន់លិខិតឆ្លងដែនការទូត ឬផ្លូវការរបស់ប្រទេសនោះបានទទួលក្នុងក្របខ័ណ្ឌនៃការបំពេញមុខងារជាផ្លូវការនៅកម្ពុជា។
- ប្រាក់បៀវត្សដែលតំណាងមន្ត្រី និងនិយោជិតបរទេសរបស់អង្គការអន្តរជាតិនិងរបស់ទីភ្នាក់ងារខាងសហប្រតិបត្តិការបច្ចេកទេស នៃរដ្ឋាភិបាលដ៏ទៃទៀតបានទទួលក្នុងក្របខណ្ឌនៃការបំពេញមុខងារជាផ្លូវការនៅក្នុងកម្ពុជា។

- **ប្រាក់ចំណូលលើកលែងពន្ធរបស់និយោជិត៖**

- ប្រាក់សំណងដោយពិតប្រាកដ នូវចំណាយខាងវិជ្ជាជីវៈ ដែលបានចាយដោយនិយោជិតតាមសេចក្តីបង្គាប់ និងសម្រាប់ជាប្រយោជន៍នៃនិយោជក ហើយដែលបានបំពេញលក្ខ័ខណ្ឌ៣៖
  - បានចាយក្នុងប្រយោជន៍ផ្ទាល់ និងដាច់ខាតរបស់សហគ្រាស
  - មិនបង្ហាញលក្ខណៈហួសប្រមាណ ឬស្តុកស្តម្ភហួសហេតុ
  - បានបង្ហាញជាភស្តុតាងដោយវិក្កយបត្រាយលំអិត និងបានទូទាត់ស្រេច ហើយដែលបានធ្វើក្នុងនាមអ្នកទទួលប្រាក់សំណងនូវចំណាយពិតប្រាកដ
- ប្រាក់បំណាច់នៃការបញ្ឈប់លែងឱ្យធ្វើការ ក្នុងកម្រិតដែលបានបញ្ញត្តិក្នុងច្បាប់ការងារ
- លាភការបន្ថែមមានលក្ខណៈខាងសង្គមកិច្ច ក្នុងករណីដែលបានបញ្ញត្តិក្នុងច្បាប់ការងារ
- ការផ្គត់ផ្គង់ឱ្យដោយឥតយកថ្លៃ ឬយកថ្លៃទាបជាងថ្លៃដើមនូវឯកសណ្ឋាន ឬបរិក្ខារសម្រាប់វិជ្ជាជីវៈពិសេស

- ប្រាក់បំណាច់ម៉ៅការសម្រាប់ចំណាយបេសកកម្ម និងការធ្វើដំណើរ។ ប្រាក់បំណាច់នេះមិនត្រូវត្រួតគ្នាជាមួយប្រាក់ចំណូលពិតប្រាកដនូវចំណាយដូចមានចែងខាងលើឡើយ។

**គ. ប្រាក់បៀវត្សជាប់ពន្ធប្រចាំខែរបស់និយោជិតនិវាសនជន**

- ប្រាក់បៀវត្សដែលទទួលបានពីប្រភពកម្ពុជា
- ប្រាក់បៀវត្សដែលបានទទួលពីប្រភពបរទេស
- ប្រាក់បុរេប្រទាន ប្រាក់ខ្ចី ឬប្រាក់រំដោះដែលនិយោជកបានបើកឲ្យនិយោជិត។ ប្រាក់បុរេប្រទាន ប្រាក់ខ្ចី ឬប្រាក់រំដោះត្រូវបូកបន្ថែមលើប្រាក់ទាំងនោះបានបើកហើយត្រូវកាត់បន្ថយពីប្រាក់បៀវត្សក្នុងខែដែលនិយោជិតបានសងវិញ។

**ឃ. អត្រា និង មូលដ្ឋានគិតពន្ធ**

អនុលោមតាមមាត្រា៤៧ថ្មី (បី) នៃច្បាប់ស្តីសារពើពន្ធ និយោជិតនិវាសនជនត្រូវជាប់ពន្ធលើប្រាក់បៀវត្សប្រចាំខែ និងត្រូវបានកាត់ទុកដោយនិយោជកតាមអត្រាកំណើនតាមថ្នាក់ដូចមានចែងក្នុងតារាងខាងក្រោមៈ[18]

**តារាងទី៣៖ តារាងភាគនៃប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ**

| ល.រ | ភាគនៃប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ | អត្រាពន្ធ | លម្អៀងលើសប្រាក់ពន្ធតាមថ្នាក់ |
|---|---|---|---|
| ១ | ពី ០រៀល ដល់ ១ ៣០០ ០០០រៀល | ០% | ០រៀល |
| ២ | ពី ១ ៣០០ ០០១រៀល ដល់ ២ ០០០ ០០០រៀល | ៥% | ៦៥ ០០០រៀល |
| ៣ | ពី ២ ០០០ ០០១រៀល ដល់ ៨ ៥០០ ០០០រៀល | ១០% | ១៦៥ ០០០រៀល |
| ៤ | ពី ៨ ៥០០ ០០១រៀល ដល់ ១២ ៥០០ ០០០រៀល | ១៥% | ៥៩០ ០០០រៀល |
| ៥ | លើសពី ១២ ៥០០ ០០០រៀល | ២០% | ១ ២១៥ ០០០រៀល |

- មូលដ្ឋានគិតពន្ធ= ប្រាក់បៀវត្ស - ទាយជ្ជទាន
- ប្រាក់ពន្ធ= ( មូលដ្ឋានគិតពន្ធ x អត្រា ) - លម្អៀងលើសប្រាក់ពន្ធក្នុងថ្នាក់

[18] អនុក្រឹត្យស្តីពី តារាងភាគនៃប្រាក់បៀវត្សជាប់ពន្ធប្រចាំខែថ្មី, លេខ ០៩ អនក្រ.បក, ១៣ កុម្ភៈ ២០២០

### ១.១២.៦. អាករបំភ្លឺសាធារណៈ[19]

#### ក. មុខសញ្ញាជាប់អាករ

ផលិតផលជាប់អាករ សម្តៅដល់ សុរាមេរ័យ និងបារី។ សុរាមេរ័យ សម្តៅដល់ស្រាបៀរ ស្រាទំពាំងបាយជូរ ស្រាវ៉េមុត ភេសជ្ជៈមេរ័យផ្សេងៗទៀត អាល់កុលអេទីលិក...។ ចំណែកឯបារី សម្តៅដល់ ផលិតផលសម្រាប់ជក់គ្រប់ប្រភេទដែលផលិតឡើងពីថ្នាំជក់។

#### ខ. ការលើកលែងមុខសញ្ញាជាប់ពន្ធ

មុខសញ្ញាលើកលែងអាករបំភ្លឺសាធារណៈមានដូចជាស្រាស ទឹកត្នោតជូរ ថ្នាំជក់(ជាវត្ថុធាតុដើម)។

#### គ. អត្រាអាករ

អត្រាអាករបំភ្លឺសាធារណៈគឺ ៣%។

#### ឃ. មូលដ្ឋានគិតអាករ

មូលដ្ឋានអាករបំភ្លឺសាធារណៈត្រូវបានកំណត់ដូចខាងក្រោម ៖

- **ចំពោះអ្នកផលិតនិងអ្នកនាំចូល៖** មូលដ្ឋានគិតជាអាករ គឺជាថ្លៃផ្គត់ផ្គង់ដែលត្រូវបានកត់ត្រាលើវិក្កយបត្ររួមមញ្ចូលទាំងពន្ធអាករនានា វៀរលែងតែអាករលើតំលៃបន្ថែម និងអាករសម្រាប់បំភ្លឺសារធារណៈខ្លួនឯង។
  - មូលដ្ឋានគិតអាករ = ថ្លៃផ្គត់ផ្គង់ជាប់អាករ + អាករផ្សេងៗ
  - អាករបំភ្លឺសាធារណៈ = មូលដ្ឋានគិតអាករ x ៣%
- **ចំពោះអ្នកផ្គត់ផ្គង់បន្ត៖** មូលដ្ឋានគិតអាករ ស្មើនឹង២០ភាគរយនៃថ្លៃផ្គត់ផ្គង់ដែលត្រូវបានកត់ត្រាលើវិក្កយត្ររួមបញ្ចូលទាំងពន្ធអាករនានាវៀរលែងតែអាករលើតម្លៃបន្ថែម និងអាករសម្រាប់បំភ្លឺសាធារណៈខ្លួនឯង។
  - មូលដ្ឋានគិតអាករ = (ថ្លៃផ្គត់ផ្គង់ជាប់អាករ + អាករផ្សេងៗ) x ២០%
  - អាករបំភ្លឺសាធារណៈ = មូលដ្ឋានគិតអាករ x ៣%

[19] ប្រកាសស្តីពីការកំណត់មូលដ្ឋានគិតអាករសម្រាប់បំភ្លឺសាធារណៈ, លេខ៩៧៦សហវ/ប្រក, ០៩ តុលា២០១៧

### ១.១២.៧. អាករពិសេសលើទំនិញ និងសេវា

អាករពិសេសទៅលើទំនិញនិងសេវាត្រូវបានប្រមូលទៅលើ៖

- ទំនិញ ដែលធ្វើអោយប៉ះពាល់ទៅលើសុខភាពដែលរដ្ឋាភិបាលមិនលើកទឹកចិត្តក្នុងការប្រើប្រាស់
- ទំនិញ ឬសេវាដែលមិនចាំបាច់ក្នុងជីវភាពរស់នៅរបស់ប្រជាជនសាមញ្ញ
- ប្រភេទទំនិញ ឬសេវាមានលក្ខណៈប្រណិត

**ក. មុខសញ្ញាជាប់អាករ**

- **អាករពិសេសលើទំនិញផលិតក្នុងស្រុក**
  - ស្រា និងភេសជ្ជៈគ្រប់ប្រភេទ
  - ស្រាបៀរគ្រប់ប្រភេទ
  - បារី បារីស៊ីហ្គាគ្រប់ប្រភេទ
- **អាករពិសេសលើសេវា**
  - សេវាដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាសក្នុង និងក្រៅស្រុក
  - សេវាទូរគមនាគមន៏ក្នុង និងក្រៅប្រទេស
  - សេវាលំហែកំសាន្ត

**ខ. អត្រាពន្ធ**

- **អាករពិសេសលើទំនិញផលិតផលក្នុងស្រុក**
  - ៣៥% លើស្រា
  - ៣០%លើស្រាបៀរគ្រប់ប្រភេទ
  - ២០% លើបារី បារីស៊ីហ្គាគ្រប់ប្រភេទ
  - ១០% លើភេសជ្ជៈគ្រប់ប្រភេទ
- **អាករពិសេសលើសេវា**
  - ១០% សម្រាប់ថ្លៃលក់សំបុត្រលើសេវាដឹជញ្ជូនអ្នកដំណើរតាមផ្លូវអាកាសក្នុងនិងក្រៅស្រុក
  - ១០% សម្រាប់សេវាលំហែកសាន្ត
  - ៣% សម្រាប់សេវាទូរគមនាគមន៏ក្នុងស្រុក និងក្រៅស្រុក

**គ. មូលដ្ឋានគិតអាករ**[20]

- **អាករពិសេសលើទំនិញផលិតផលក្នុងស្រុក**
  - មូលដ្ឋានសម្រាប់គិតអាករពិសេស = (ថ្លៃកត់ត្រាក្នុងវិក័យបត្រឱ្យទៅអតិថិជន - អតប - អាករពិសេសខ្លួនឯង) x៩០%
  - អាករពិសេសលើទំនិញ = មូលដ្ឋានគិតអាករពិសេសលើទំនិញ x អត្រាអាករ
- **អាករពិសេសលើសេវា**
  - មូលដ្ឋានគិតអាករពិសេសលើសេវា = ថ្លៃផ្គត់ផ្គង់របស់អ្នកជាប់ពន្ធកត់ត្រាក្នុងវិក្កយបត្រឱ្យទៅអតិថិជន - អតប - អាករបំភ្លឺសាធារណៈ - អាករពិសេសខ្លួនឯង
  - អាករពិសេសលើសេវា = មូលដ្ឋានគិតអាករពិសេសលើសេវា x អត្រាអាករ

**១.១២.៨. ពន្ធអប្បបរមា**

**ក. និយមន័យ**

ពន្ធអប្បបរមា គឺជាប្រភេទពន្ធដែលត្រូវបង់នៅពេលទូទាត់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ។ វា គឺជាប្រភេទពន្ធដាច់ដោយឡែកពីពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ។

**ខ. អត្រាអាករ និង ការគណនាអាករ**

ពន្ធនេះត្រូវបង់ដោយអ្នកជាប់ពន្ធ តាមរបបស្វ័យប្រកាស លើកលែងតែគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ តាមអត្រា ១ភាគរយ លើផលរបរប្រចាំឆ្នាំរួមបញ្ចូលទាំងពន្ធអាករនានាវៀរលែងតែអាករលើតម្លៃបន្ថែម។

**១.១២.៩. ប្រាក់រំដោះពន្ធលើប្រាក់ចំណូល**[21]

សហគ្រាសដែលជាប់ពន្ធលើប្រាក់ចំណូលយោងតាមរបបពិតជាក់ស្តែង(របបស្វ័យប្រកាស)នៃការយកពន្ធ ត្រូវមានកាតព្វកិច្ចបង់ប្រាក់រំដោះប្រចាំខែសម្រាប់ពន្ធលើប្រាក់ចំណូល តាមអត្រា១% នៃផលរបរគិតរួមបញ្ចូលទាំងពន្ធអាករគ្រប់ប្រភេទទាំងអស់ លើកលែងតែពន្ធលើតម្លៃបន្ថែមនិង ប្រាក់រំដោះលើប្រាក់ចំណូលខ្លួនឯងផ្ទាល់ ដែលសម្រេចបានក្នុងខែមុន។ ប្រាក់រំដោះពន្ធលើប្រាក់ចំណូលនេះ ត្រូវបានយកមកកាត់កងពីពន្ធលើប្រាក់ចំណូលនៅពេលធ្វើការទូទាត់ប្រចាំឆ្នាំ។

[20] សេចក្តីជូនដំណឹងស្តីពីការកែសម្រួលមូលដ្ឋានគិតអាករពិសេសលើមុខទំនិញមួយចំនួន ដែលផលិតក្នុងស្រុកក្រៅពីបារីនិងស្រា, លេខ០០៥សហវ, ១៩ មករា ២០១៥

[21] ប្រកាសស្តីពីការប្រើប្រាស់ទម្រង់លិខិតប្រកាសបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ, លេខ៥០៦,សហវ ពដ, ២៤ កក្កដា ២០០២

ក្នុងកថាខណ្ឌទី២ នៃមាត្រា៣៨ នៃច្បាប់ស្តីពីសារពើពន្ធ ក្នុងករណីដែលសហគ្រាសមានបំណុលពន្ធលើប្រាក់ចំណូលតិចជាងប្រាក់រំដោះដែលបានបង់ប្រចាំឆ្នាំ ចំនួនលំអៀងនឹងត្រូវបានអនុញ្ញាតឱ្យយោងទៅប្រើប្រាស់ជាឥណទានសម្រាប់កាត់កងនឹងប្រាក់រំដោះត្រូវបង់ក្នុងឆ្នាំខាងមុខ ឬស្នើសុំបង្វិលសងវិញប្រសិនបើសហគ្រាសបញ្ឈប់សកម្មភាពអាជីវកម្ម។ ការស្នើសុំយោងជាឥណទាន ឬស្នើសុំបង្វិលសង ត្រូវធ្វើឡើងតាមរយៈលិខិតប្រកាសបង់ប្រាក់រំដោះប្រចាំខែ។

**ក. អត្រាពន្ធ**

ប្រាក់រំដោះពន្ធលើប្រាក់ចំណូលត្រូវគិតតាមអត្រា ១%

**ខ. មូលដ្ឋានគិតពន្ធ**

មូលដ្ឋានគិតពន្ធ = ( ផលរបរសម្រេចបានក្នុងខែមុន - អតប ) x ១%

**គ. ការព្យួរទុកប្រាក់រំដោះពន្ធលើប្រាក់ចំណូល**[22]

សហគ្រាសដាំដុះ ផលិត និងផ្គត់ផ្គង់ក្នុងស្រុក ឬនាំចេញផលិតផលកសិកម្មមួយចំនួន ដូចជា ស្រូវ អង្ករ ពោត សណ្តែក ម្រេច គ្រាប់ស្វាយចន្ទី ដំឡូងមី និង កៅស៊ូ ត្រូវបានអនុគ្រោះព្យួរទុកជាបណ្តោះអាសន្ននូវការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូលប្រចាំខែ រយៈពេល៥ឆ្នាំ គិតចាប់ពីខែមករា ឆ្នាំ ២០១៩ តរៀងទៅ។

**១.១២.១០. ពន្ធលើប្រាក់ចំណូល**[23]

ប្រាក់ចំណូលជាប់ពន្ធ គឺជាប្រាក់ចំណូលដែលបានមកពីលទ្ធផលទាំងអស់នៃប្រតិបត្តិការគ្រប់ប្រភេទ។

- **<u>វិធានគណនេយ្យ៖</u>**
  - ចំពោះអ្នកជាប់ពន្ធតូច គឺប្រើប្រាស់វិធានគណនេយ្យសាមញ្ញ ពោលគឺគ្រាន់តែមានតារាងទិញ តារាងលក់ និង តារាងស្តុក និងរបាយការណ៍លទ្ធផលតែប៉ុណ្ណោះ រួចស្រង់ចូលទៅក្នុងតារាងប្រកាសពន្ធលើប្រាក់ចំណូល។ ចំណែកឯអ្នកជាប់ពន្ធមធ្យម និងធំ គឺប្រើប្រាស់វិធានគណនេយ្យស្តង់ដារអន្តរជាតិនៃកម្ពុជា។
  - ប្រាក់ចំណូល គឺត្រូវគិតបញ្ចូលនៅក្នុងឆ្នាំដែលចំណូលនោះបានកើតឡើង ទោះបីប្រាក់ចំណូលនោះបានទូទាត់ ឬ មិនទាន់ទូទាត់ក្តី។
- **<u>ការកែតម្រូវក្រៅគណនេយ្យ៖</u>**លទ្ធផលពិតគណនេយ្យគឺត្រូវតែជាកម្មវត្ថុនៃការកែតម្រូវក្រៅគណនេយ្យដែលមានការបញ្ចូលមកវិញ និងកាត់ចេញផ្សេងៗ។

[22] ប្រកាសស្តីពីការព្យួរទុកការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូលរបស់សហគ្រាសប្រកបអាជីវកម្មក្នុងវិស័យកសិកម្ម, លេខ១០០/សហវ/ ប្រក, ២៩ មករា ២០១៩

[23] ប្រកាសស្តីពីពន្ធលើប្រាក់ចំណូល, លេខ០៩៨ សហវ ប្រ.ក, ២៩ មករា ២០២០

**ក. និយមន័យ**

ពន្ធលើប្រាក់ចំណូល ត្រូវបានកំណត់ទៅលើអ្នកជាប់ពន្ធនិវាសនជន ចំពោះប្រាក់ចំណូលប្រភពកម្ពុជា និង ប្រាក់ចំណូលប្រភពបរទេស។ សម្រាប់អ្នកជាប់ពន្ធអនិវាសនជន ពន្ធលើប្រាក់ចំណូលកំណត់តែលើប្រាក់ចំណូលប្រភពកម្ពុជាប៉ុណ្ណោះ។

- តាមមាត្រា ៣៣ថ្មី និង ៣៤ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃចសព ដោយមិនមានការកម្រិតត្រឹមតែប្រាក់ចំណូលដូចខាងក្រោមនេះ ប្រាក់ចំណូលប្រភពកម្ពុជាមាន៖
  - ការប្រាក់ដែលបង់ដោយសហគ្រាសនិវាសនជន ឬក្រុមអាជីវកម្មនិវាសនជន ឬស្ថាប័នរបស់ រដ្ឋាភិបាល នៃកម្ពុជា។
  - ភាគលាភដែលបានបែងចែកដោយសហគ្រាសនិវាសនជន
  - ប្រាក់ចំណូលពីសេវាកម្មដែលបានបំពេញនៅក្នុងកម្ពុជា
  - ប្រាក់ចំណូលពីការគ្រប់គ្រង និង សេវាបច្ចេកទេសដែលបានទូទាត់ដោយបុគ្គលនិវាសនជន
  - ប្រាក់ចំណូលដែលបានមកពីចលនទ្រព្យ ឬ អចលនទ្រព្យក្នុងករណីដែលទ្រព្យនោះស្ថិតនៅក្នុងកម្ពុជា
  - ប្រាក់សួយសារដែលបានមកពីការប្រើប្រាស់ ឬ សិទ្ធិប្រើប្រាស់ទ្រព្យសកម្មអរូបី ដែលបានទូទាត់ដោយបុគ្គលនិវាសនជន ឬបុគ្គលអនិវាសនជនតាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍ដែលតាំងនៅក្នុងកម្ពុជា
  - ផលចំណេញពីការលក់អចលនទ្រព្យ ដែលស្ថិតនៅក្នុងកម្ពុជា ឬ ផលចំណេញពីការផ្ទេរប្រយោជន៍ណាមួយនៃអចលនទ្រព្យដែលស្ថិតនៅក្នុងកម្ពុជា
  - បុព្វលាភធានារ៉ាប់រង ឬ ធានារ៉ាប់រងបន្តចំពោះហានិភ័យនៅក្នុងកម្ពុជា
  - ផលចំណេញពីការលក់ចលនទ្រព្យ ដែលជាចំណែកនៃទ្រព្យអាជីវកម្មរបស់គ្រឹះស្ថានអចិន្ត្រៃយ៍របស់អ្នកជាប់ពន្ធអនិវាសនជននៅក្នុងកម្ពុជា
  - ប្រាក់ចំណូលពីសកម្មភាពអាជីវកម្មរបស់បុគ្គលអនិវាសនជន តាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងកម្ពុជា
  - អ្នកជាប់ពន្ធនិវាសនជននៅកម្ពុជា និង អ្នកជាប់ពន្ធអនិវាសនជន អាចមានប្រាក់ចំណូលប្រភពកម្ពុជាផ្សេងទៀតពីការប្រកបអាជីវកម្មនៅក្នុងកម្ពុជា។

- ស្របតាមមាត្រា៣៤ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃចសព ប្រាក់ចំណូលណាមួយ ដែលមិនត្រូវបានកំណត់ថាជាប្រាក់ចំណូលប្រភពកម្ពុជាដូចមានចែងក្នុងមាត្រា៣៣ថ្មី ត្រូវបានចាត់ទុកជាប្រាក់ចំណូលប្រភពបរទេស។

**ខ. អត្រាពន្ធ**

អត្រាពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ៖

១- ២០ភាគរយ ចំពោះប្រាក់ចំណូលជាប់ពន្ធដែលសម្រេចបានដោយនីតិបុគ្គល

២- ៣០ភាគរយ ចំពោះប្រាក់ចំណូលជាប់ពន្ធ ដែលសម្រេចបានក្រោមកិច្ចសន្យាបែងចែកផលិតផលប្រេងកាត និងឧស្ម័ន ធម្មជាតិ ឬសម្រេចបានពីការធ្វើអាជីវកម្មលើធនធានធម្មជាតិរួមទាំង ព្រៃឈើ រ៉ែ មាស ឬត្បូងថ្មមានតម្លៃនានា

៣- ០ភាគរយ ចំពោះប្រាក់ចំណូលរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលស្ថិតនៅក្នុងរយៈពេលលើកលែងពន្ធ

៤- តាមតារាងអត្រាពន្ធកំណើនតាមថ្នាក់ខាងក្រោមចំពោះប្រាក់ចំណូលជាប់ពន្ធដែលសម្រេចបានដោយរូបវន្តបុគ្គល សហគ្រាសឯកបុគ្គល និងសមាជិកម្នាក់ៗរបស់ក្រុមហ៊ុនសហកម្មសិទ្ធិដែលមិនត្រូវបានចាត់ទុកជានីតិបុគ្គល៖

**តារាងទី៤៖ អត្រាពន្ធកំណើនតាមថ្នាក់**

| **ភាគនៃប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ** | | | | **អត្រាពន្ធ** |
|---|---|---|---|---|
| ពី | 0 ៛ | ដល់ | ១៦.000.000 ៛ | 0% |
| ពី | ១៦.000.00១ ៛ | ដល់ | ២៤.000.000 ៛ | ៥% |
| ពី | ២៤.000.00១ ៛ | ដល់ | ១0២.000.000 ៛ | ១0% |
| ពី | ១0២.000.00១ ៛ | ដល់ | ១៥0.000.000 ៛ | ១៥% |
| លើសពី ១៥0.000.000 ៛ | | | | ២0% |

**គ. ប្រាក់ចំណូលមិនជាប់ពន្ធលើប្រាក់ចំណូល**

ប្រាក់ចំណូលដែលមិនជាប់ពន្ធលើប្រាក់ចំណូលមានដូចជាៈ

- ប្រាក់ចំណូលដែលជាប់ពន្ធលើប្រាក់បៀវត្ស ឬ ជាប់ពន្ធលើអត្ថប្រយោជន៍បន្ថែម។
- ប្រាក់ចំណូល ដែលជាថ្លៃឈ្នួលផ្ទះ និង ដី របស់បុគ្គលដែលមិនស្ថិតក្នុងរបបស្វ័យប្រកាស។ ប៉ុន្តែបើជាបុគ្គលជាប់ពន្ធតាមរបបស្វ័យប្រកាស ប្រាក់ចំណូលនេះជាចំណូលជាប់ពន្ធ។
- ប្រាក់ចំណូល ដែលបានមកពីការលក់ផលិតផលកសិកម្ម ដែលបុគ្គលមិនមែនជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ផលិតបានដោយខ្លួនឯង ទោះបីជាផលិតផលនោះមិនទាន់កែច្នៃ ឬ កែច្នៃហើយក៏ដោយ ទៅតាមទម្លាប់នៃការងារកសិកម្ម។ ប្រតិបត្តិការតាម មធ្យោបាយឧស្សាហកម្មផ្សេងៗ រួមមានៈ ការកែច្នៃ ការរក្សាគុណភាព និង ការវេចខ្ចប់ មិនត្រូវចាត់ចូលជាទំលាប់នៃការងារកសិកម្មឡើយ។
- ប្រាក់ចំណូលរបស់រាជរដ្ឋាភិបាល ឬ ស្ថាប័នរាជរដ្ឋាភិបាល លើកលែងតែស្ថាប័នណាដែលធ្វើអាជីវកម្មរកចំណូលដូចជាសហគ្រាសសាធារណៈជាដើម។
- ប្រាក់ចំណូលរបស់អង្គការណាមួយដែលៈ
- ត្រូវបានរៀបចំឡើង និងដំណើរការសម្រាប់គោលដៅសុទ្ធសាធខាងសាសនា សប្បុរសធម៌ វិទ្យាសាស្ត្រ អក្សរសាស្ត្រ ឬអប់រំ។
- គ្មានចំណែកណាមួយនៃទ្រព្យ ឬ ប្រាក់ចំណូលត្រូវបានប្រើប្រាស់ជាផលប្រយោជន៍ឯកជន។
- ប្រាក់ចំណូលរបស់អង្គការពលករ ឬ សភាពាណិជ្ជកម្ម ឧស្សាហកម្ម ឬ កសិកម្ម ក្នុងករណីដែលប្រាក់ចំណូល របស់អង្គការទាំងនោះមិនត្រូវបានប្រើប្រាស់ជាផលប្រយោជន៍ឯកជនរបស់អ្នកចូលហ៊ុន ឬ រូបវន្តបុគ្គល។
- ភាគលាភ ដែលបានទទួលមកពីសហគ្រាសនិវាសនជន ក្នុងករណីដែលប្រាក់ពន្ធត្រូវបង់តាមមាត្រា២០ថ្មី មាត្រា២៣ថ្មី និង មាត្រា២៦ថ្មី នៃច្បាប់នេះត្រូវបានបង់រួចរាល់។

**ឃ.ចំណាយដែលអាចកាត់កងបាន**

- ចំណាយដែលអាចកាត់កងបាន ត្រូវបំពេញលក្ខខណ្ឌ៣ ដូចខាងក្រោមៈ
  - ហេតុការណ៍ដែលបញ្ជាក់នូវបន្ទុកឬ ចំណាយរបស់អ្នកជាប់ពន្ធបានកើតឡើង
  - លទ្ធផលនៃសកម្មភាពសេដ្ឋកិច្ចដែលជាប់ទាក់ទងដល់ខ្ទង់ចំណាយនោះបានកើតឡើង
  - បន្ទុករបស់អ្នកជាប់ពន្ធត្រូវបានកំណត់ច្បាស់លាស់

ចំណាយដែលអាចកាត់កងបានលុះត្រាតែជាចំណាយដែលបានទូទាត់ឬ សងនៅក្នុងឆ្នាំជាប់ពន្ធដែលអ្នកជាប់ពន្ធបានធ្វើឡើងដើម្បីប្រកបរបរអាជីវកម្ម។

- ចំណាយដែលអាចកាត់កងបានមានដូចជាៈ
  - សោហ៊ុយបង្កើតសហគ្រាស
  - ការទិញ
  - បន្ទុកសេវាខាងក្រៅ ៖
    - ការជួល
    - ការងារថែទាំនិងជួសជុល
    - ចំណាយធានារ៉ាប់រង
    - កម្រៃជើងសារ
    - លាភការខាងក្រៅពន្ធ និងអាករ
  - បៀវត្ស និងបន្ទុកប្រហាក់ប្រហែល
  - វិភាគទានសប្បុរសធម៌ៈ
    - បរិច្ចាគអោយដល់ស្ថាប័នរដ្ឋាភិបាល និងអង្គការនានាដែលមិនស្វែងរកប្រាក់ចំណេញ
    - មិនត្រូវអោយលើសពី៥%នៃប្រាក់ចំណេញជាប់ពន្ធមុនពេលកាត់កងវិភាគទានសប្បុរសធម៌
    - មិនអាចយោងជាចំណាយសម្រាប់ឆ្នាំបន្តបន្ទាប់ទៀតបាន។
  - ការប្រាក់ៈ អាចយោងជាចំណាយការប្រាក់សម្រាប់ឆ្នាំបន្តបន្ទាប់ទៀតនូវចំណាយការប្រាក់ណាដែលមិនត្រូវបានអនុញ្ញាតអោយយកមកកាត់កងនៅក្នុងឆ្នាំចរន្ត នៅកំហិតដូចគ្នារហូតដល់សមតុល្យនៃចំណាយការប្រាក់មិនទាន់អនុញ្ញាតអោយកាត់កងនេះត្រូវបានប្រើប្រាស់អស់។កំហិតលើការកាត់កងការប្រាក់សម្រាប់ឆ្នាំជាប់ពន្ធណាមួយ គឺជាចំនួនទឹកប្រាក់ ការប្រាក់អតិបរិមា ដែលត្រូវបានអនុញ្ញាតអោយកាត់កងនៅក្នុងឆ្នាំជាប់ពន្ធនោះ និងត្រូវគណនាតាមរូបមន្ត។ រូបមន្ត កំហិតលើកាត់កងការប្រាក់ = ក + ខ
    - ក = ៥0%នៃប្រាក់ចំណេញសុទ្ធដែលគ្មានចំណូល ចំណាយការប្រាក់
    - ខ = ចំណូលការប្រាក់ដែលបានទទួល ឬ ត្រូវបានទទួល

**ខ. ចំណាយមិនអាចកាត់កងបាន**

ចំណាយដែលមិនអាចកាត់កងបានមានដូចជា៖

- ចំណាយរំលស់គណនេយ្យ
- ចំណាយលើការដើរកំសាន្តសប្បាយ ការលំហែកំសាន្ត និង ទទួលភ្ញៀវ
- ការកើនឡើងនូវសំវិធានធន
- អំណោយ និង ឧបត្ថម្ភផ្សេងៗ
- ខាតពីការលក់ទ្រព្យសកម្មរយៈពេលវែង
- ចំណាយមានលក្ខណៈស្តុកស្តម្ភហួសហេតុមិនអនុញ្ញាត
- ចំណាយមិនបម្រើអោយសកម្មភាពអាជីវកម្ម
- ខាតលើប្រតិបត្តិការជាមួយបុគ្គលជាប់ទាក់ទិន
- ចំណាយលើការផាកពិន័យ និង ទោសទណ្ឌផ្សេងៗ
- ចំណាយនៃការិយបរិច្ឆេទមុន
- ចំណាយពន្ធ និង អាករផ្សេងៗមិនអាចកាត់កងបាន
- លាភការជីវករ និង គ្រួសារ
- ចំណាយបៀវត្សដែលមិនទាន់បានបើរយៈពេល៦០ថ្ងៃនៃឆ្នាំបន្ទាប់
- ចំណាយផ្សេងៗមិនអាចអោយកាត់កងបាន

**ច. ចំណូលជាប់ពន្ធតែមិនបានកត់ត្រាក្នុងបញ្ជីគណនេយ្យ**

- ការផ្គត់ផ្គង់ទំនិញ និង សេវាដោយឥតគិតថ្លៃ
- ការដាក់ទ្រព្យសកម្មរយៈពេលវែងដាក់អោយប្រើប្រាស់ដោយឥតគិតថ្លៃ
- ការកែលម្អទ្រព្យសកម្មរយៈពេលវែងដោយអ្នកជួលជុលមិនគិតយកពីម្ចាស់
- អំណោយ និង ឧបត្ថម្ភធនផ្សេងៗមិនទទួលស្គាល់ក្នុងគណនេយ្យ
- ផលចំណេញ តម្លៃលើសពីការលក់ទ្រព្យសកម្មរយៈពេលវែងតាមច្បាប់ពន្ធដារ
- ចំណូលផ្សេងៗទៀតដែលមិនបានកត់ត្រាក្នុងបញ្ជីគណនេយ្យ

**ឆ. ចំណាយមិនបានកត់ត្រាក្នុងបញ្ជីគណនេយ្យតែជាចំណាយកាត់កងបានក្នុងឆ្នាំ**

- វិលស់អនុញ្ញាតតាមច្បាប់សារពើពន្ធ
- វិលស់ពិសេសអនុញ្ញាតតាមច្បាប់សារពើពន្ធ
- ការចុះនូវសំវិធានធន
- ខាតពីការលក់ទ្រព្យសកម្មរយៈពេលវែងតាមច្បាប់ពន្ធដារ
- ចំណាយផ្សេងៗដែលអនុញ្ញាតអោយកាត់កងតាមច្បាប់ស្តីពីសារពើពន្ធ តែមិនបានកត់ត្រាក្នុងបញ្ជីគណនេយ្យ

**ជ. ចំណូលបានកត់ត្រាក្នុងបញ្ជីគណនេយ្យតែជាចំណូលមិនត្រូវជាប់ពន្ធក្នុងឆ្នាំ**

- ចំណូលលើភាគលាភទទួលបានពីអ្នកជាប់ពន្ធនិវាសជន
- ចំណូលពីការលក់ទ្រព្យសកម្មរយៈពេលវែង (ចំណេញតាមបញ្ជីគណនេយ្យ)
- ចំណូលផ្សេងៗបានកត់ត្រាក្នុងបញ្ជីគណនេយ្យតែជាចំណូលមិនត្រូវជាប់ពន្ធក្នុងឆ្នាំ

**ឈ. វិធានស្តីពីការយោងការខាតបង់**

អាចយោងទៅឆ្នាំជាប់ពន្ធបន្តបន្ទាប់រហូតដល់ ឆ្នាំជាប់ពន្ធទី៥។ ចំពោះលក្ខខណ្ឌនៃការយោងការខាតបង់មកកាត់ចេញ មាន៖

- **ភស្តុតាងនៃការយោងការខាត៖**
  - ការខាតបង់ត្រូវមានចុះក្នុងលិខិតប្រកាស
  - មានការបញ្ជាក់អះអាងដោយបញ្ជីឯកសារគណនេយ្យដែលត្រូវបានកាន់កាប់ថែរក្សាយ៉ាងល្អ។
- **អត្តសញ្ញាណសហគ្រាស៖**
  - គ្មានការផ្លាស់ប្តូរម្ចាស់សហគ្រាស
  - គ្មានការផ្លាស់ប្តូរសកម្មភាពអាជីវកម្ម
- **រយៈពេលត្រូវយោងមកកាត់ចេញ៖**
  - ការខាតបង់ត្រូវយោងមកកាត់ចេញជាដាច់ខាតពីលទ្ធផលនៃការិយបរិច្ឆេទ(ក្រោយ)ទី១ដែលមានចំណេញ។
- **មិនត្រូវបាន អនុញ្ញាតអោយយោងមកកាត់ចេញពីប្រាក់ចំណេញ៖**
  - ក្នុងករណីនៃការផ្លាស់ប្តូរម្ចាស់សហគ្រាស
  - ក្នុងករណីនៃការផ្លាស់ប្តូរសកម្មភាពអាជីវកម្ម

- អ្នកជាប់ពន្ធដែលត្រូវទទួលរងការកំណត់ពន្ធជាឯកតោភាគី

**៣. ឥណទានពន្ធបរទេស**

ឥណទានពន្ធបរទេស គឺចំនួនដែលទាបជាងគេចំណោម :

- ប្រាក់ពន្ធដែលបានបង់ជាក់ស្តែងនៅប្រទេសក្រៅណាមួយនោះ
- ប្រាក់ពន្ធលើប្រាក់ចំណូលសរុបពីគ្រប់ប្រភព x (ប្រាក់ចំណូលនៅប្រទេសក្រៅនោះ/ប្រាក់ចំណូលសរុបពីគ្រប់ប្រភព)

ក្នុងករណីឥណទានពន្ធមានចំនួនលើសពីបំណុលពន្ធ អាចយោងទៅប្រើនៅឆ្នាំបន្តបន្ទាប់រហូតដល់ឆ្នាំទី៥។

**៤. ឥណទានពន្ធបន្ថែមលើការបែងចែកភាគលាភក្នុងឆ្នាំ**

- ១០០%នៃប្រាក់ពន្ធបានបង់ បើជាប់ពន្ធលើប្រាក់ចំណូលតាមអត្រា២០% ឬ ៣០%
- ០%នៃប្រាក់ពន្ធបានបង់ បើជាប់ពន្ធលើប្រាក់ចំណូលតាមអត្រា០%

**៥. រយៈពេលលើកលែងពន្ធលើប្រាក់ចំណូល**

យោងតាមច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគកម្ពុជា លេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០០៣៖

- រាជរដ្ឋាភិបាលបានលើកទឹកចិត្ត ចំពោះគម្រោងដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការ វិនិយោគនៅកម្ពុជា ដោយបានលើកលែងពន្ធលើប្រាក់ចំណូលក្នុងរយៈពេលអនុគ្រោះពន្ធ។
- រយៈពេលលើកលែងពន្ធលើប្រាក់ចំណូល = រយៈពេលគន្លឹះ+ រយៈពេល៣ឆ្នាំ+ រយៈពេលអាទិភាព
  - រយៈពេលគន្លឹះ គឺចាប់ផ្តើមចេញពីថ្ងៃចេញវិញ្ញាបនបត្រចុះបញ្ជីស្ថាពរ និង នៅថ្ងៃចុងក្រោយនៃឆ្នាំសារពើពន្ធណាមួយដែលឆាប់ជាង រវាងមានប្រាក់ចំណេញដំបូង និង មានប្រាក់ចំណូល (ផលរបរ) ៣ឆ្នាំ គិតចាប់ពីមានប្រាក់ចំណូលដំបូង។
  - រយៈពេល៣ឆ្នាំ គឺគិតចាប់ពីឆ្នាំគន្លឹះ និង ២ឆ្នាំបន្តបន្ទាប់។
  - រយៈពេលអទិភាព គឺគិតបន្តចាប់ពីរយៈពេល៣ឆ្នាំ។

## ឌ. ការគណនាពន្ធលើប្រាក់ចំណូល

- **ប្រាក់ចំណូលជាប់ពន្ធ**

១. ការបញ្ចូលមកវិញ និងការកាត់ចេញផ្សេងៗ៖ អាស្រ័យដោយបទប្បញ្ញត្តិស្តីពីពន្ធដារមិនស្របគ្នាទាំងស្រុងទៅនឹងវិធានគណនេយ្យ នាំឱ្យប្រាក់ចំណូលជាប់ពន្ធអាចមិនស្មើគ្នានឹងប្រាក់ចំណេញគណនេយ្យទេ។ ដូច្នេះដើម្បីគណនាប្រាក់ចំណូលជាប់ពន្ធនៃឆ្នាំជាប់ពន្ធណាមួយ សហគ្រាសត្រូវយកលទ្ធផលគណនេយ្យមុនបង់ពន្ធនៃឆ្នាំជាប់ពន្ធនោះ មកធ្វើការកែតម្រូវដោយ៖

បូកបញ្ចូលនូវចំណាយមិនអនុញ្ញាតឱ្យកាត់កង

បូកបញ្ចូលមកវិញនូវចំណូលជាប់ពន្ធដែលមិនត្រូវបានកត់ត្រាជាចំណូលក្នុងបញ្ជីគណនេយ្យ

ដកចេញវិញនូវចំណាយមិនកត់ត្រាក្នុងបញ្ជីគណនេយ្យ តែជាចំណាយកាត់កងបានក្នុងឆ្នាំ

ដកចេញវីញនូវចំណូលបានកត់ត្រាក្នុងបញ្ជីគណនេយ្យ តែជាចំណូលមិនត្រូវជាប់ពនញធក្នុងឆ្នាំ

២. ក្រោយពីបានធ្វើការកែតម្រូវក្នុងកថាខណ្ឌទី១ហើយ សហគ្រាសត្រូវគណនាវិភាគទានសប្បុរសធម៌ដែលអាចកាត់កងបានតាមបទប្បញ្ញត្តិនៃពន្ធលើប្រាក់ចំណូលសម្រាប់ឆ្នាំជាប់ពន្ធ ដោយត្រូវអនុវត្តដូចខាងក្រោម៖

**ក.** គណនាមូលដ្ឋានសម្រាប់គិតវិភាគទានសប្បុរសធម៌ ដោយត្រូវយកវិភាគទានសប្បុរសធម៌ដែលបានចំណាយនៅក្នុងឆ្នាំជាប់ពន្ធ ទៅបូកនឹងលទ្ធផលក្រោយការកែតម្រូវដែលបានគណនាតាមកថាខណ្ឌ១ ខាងលើនេះ។

**ខ.** គណនាវិភាគទានសប្បុរសធម៌អតិបរមាដែលអាចកាត់កងបានសម្រាប់ឆ្នាំជាប់ពន្ធ ដោយយកលទ្ធផលដែលបានគណនាក្នុងវាក្យខណ្ឌក នៃកថាខណ្ឌនេះ ទៅគុណនឹង ៥ភាគរយ

**គ.** វិភាគទានសប្បុរសធម៌អាចកាត់កងបានសម្រាប់ឆ្នាំជាប់ពន្ធ៖

- ក្នុងករណីទឹកប្រាក់វិភាគទានសប្បុរសធម៌ក្នុងឆ្នាំជាប់ពន្ធតិចជាង ឬស្មើនឹងវិភាគទានសប្បុរសធម៌អតិបរមាអាចកាត់កងបានសម្រាប់ឆ្នាំជាប់ពន្ធ គ្មានការកែតម្រូវចំណាយវិភាគទានសប្បុរសធម៌ទេ។
- ក្នុងករណីទឹកប្រាក់វិភាគទានសប្បុរសធម៌ក្នុងឆ្នាំជាប់ពន្ធច្រើនជាងវិភាគទានសប្បុរសធម៌អតិបរមាដែលអាចកាត់កងបានសម្រាប់ឆ្នាំជាប់ពន្ធ ទឹកប្រាក់លម្អៀងត្រូវចាត់ទុកជាចំណាយមិនអាចកាត់កងបានសម្រាប់ឆ្នាំជាប់ពន្ធ។ ទឹកប្រាក់លម្អៀងនេះ ត្រូវបូកបញ្ចូលវិញទៅក្នុងលទ្ធផលក្រោយការ

កែតម្រូវដែលបានគណនាតាមកថាខណ្ឌ១ ខាងលើនេះ ដើម្បីរកលទ្ធផលក្រោយការកាត់កងវិភាគទានសប្បុរសធម៌។

៣. បន្ទាប់មកសហគ្រាសត្រូវគណនារកលទ្ធផលក្រោយការកែតម្រូវការប្រាក់ដោយៈ

**ក.** គណនាប្រាក់ចំណូលសុទ្ធក្រៅពីការប្រាក់ ដោយយកលទ្ធផលក្រោយការកាត់កងវិភាគទានសប្បុរធម៌ទៅបូកនឹងចំណាយការប្រាក់ក្នុងឆ្នាំជាប់ពន្ធ រួចដកនឹងចំណូលការប្រាក់ក្នុងឆ្នាំជាប់ពន្ធ

**ខ.** គណនាចំណាយការប្រាក់អតិបរមាអាចកាត់កងបានក្នុងឆ្នាំជាប់ពន្ធ ដោយយកចំណូលការប្រាក់ក្នុងឆ្នាំជាប់ទៅបូកនឹង៥០ភាគរយ នៃប្រាក់ចំណូលសុទ្ធក្រៅពីការប្រាក់ដូចបានគណនាក្នុងវាក្យខណ្ឌក នៃកថាខណ្ឌនេះ

**គ.** ក្នុងករណីចំណាយការប្រាក់ក្នុងឆ្នាំជាប់ពន្ធ ច្រើនជាងចំណាយការប្រាក់អតិបរមាដែលអាចកាត់កងបានក្នុងឆ្នាំជាប់ពន្ធ សហគ្រាសត្រូវគណនាចំណាយការប្រាក់ដែលមិនអាចកាត់កងបានក្នុងឆ្នាំជាប់ពន្ធ ដោយយកចំណាយការប្រាក់ក្នុងឆ្នាំជាប់ពន្ធដកចំណាយការប្រាក់អតិបរមាដែលអាចកាត់កងបានក្នុងឆ្នាំជាប់ពន្ធដែលបានគណនាក្នុងវាក្យខណ្ឌខ នៃកថាខណ្ឌនេះ។ ចំណាយការប្រាក់ដែលនៅសល់ពីការកាត់កងនេះ ត្រូវបានចាត់ទុកជាចំណាយការប្រាក់សម្រាប់ឆ្នាំជាប់ពន្ធបន្ទាប់ រហូតដល់ឆ្នាំជាប់ពន្ធទី៥ តាមលំដាប់ឆ្នាំដែលចំណាយការប្រាក់បានកើតឡើងតាមវិធីដូចមានចែងក្នុងកថាខណ្ឌនេះ

**ឃ.** ក្នុងករណីចំណាយការប្រាក់ក្នុងឆ្នាំជាប់ពន្ធ ស្មើនឹងចំណាយការប្រាក់អតិបរមាដែលអាចកាត់កងបានក្នុងឆ្នាំជាប់ពន្ធ ចំណាយការប្រាក់ត្រូវបានអនុញ្ញាតទាំងស្រុងដោយមិនមានការកែតម្រូវទេ

**ង.** ក្នុងករណីចំណាយការប្រាក់ក្នុងឆ្នាំជាប់ពន្ធ តិចជាងចំណាយការប្រាក់អតិបរមាដែលអាចកាត់កងបានក្នុងឆ្នាំជាប់ពន្ធ ចំណាយការប្រាក់ក្នុងឆ្នាំជាប់ពន្ធអាចកាត់កងបានទាំងអស់សម្រាប់ឆ្នាំជាប់ពន្ធ។ ប្រសិនបើសហគ្រាសមានចំណាយការប្រាក់ដែលនៅសល់យោងពីឆ្នាំមុន សហគ្រាសអាចយកមកកាត់កងបាន ប៉ុន្តែចំនួនដែលត្រូវបានអនុញ្ញាតឱ្យកាត់កងសរុប មិនត្រូវឱ្យលើសពីចំណាយការប្រាក់អតិបរមាដែលអាចកាត់កងបានក្នុងឆ្នាំជាប់ពន្ធទេ។ ក្នុងករណីនេះ ការប្រាក់យោងពីឆ្នាំមុនដែលអនុញ្ញាតឱ្យកាត់កងត្រូវដកចេញពីចំណូលជាប់ពន្ធ

**ច.** គណនាលទ្ធផលក្រោយការកែតម្រូវការប្រាក់ក្នុងឆ្នាំជាប់ពន្ធ ដោយយកលទ្ធផលក្រោយការកាត់កងវិភាគទានសប្បុរសធម៌ បូកចំណាយការប្រាក់ដែលមិនអាចកាត់កងបានក្នុងឆ្នាំជាប់ពន្ធតាមវាក្យខណ្ឌគ ឬដកចំណាយការប្រាក់យោងពីឆ្នាំមុន តាមវាក្យខណ្ឌ ង។

៤. គណនាប្រាក់ចំណូលជាប់ពន្ធសម្រាប់ឆ្នាំជាប់ពន្ធ ដោយយកលទ្ធផលក្រោយការកែតម្រូវការប្រាក់ក្នុងឆ្នាំជាប់ពន្ធតាមវាក្យខណ្ឌ ច នៃកថាខណ្ឌ៣ ខាងលើនេះ ដកការខាតបង់ពីឆ្នាំមុនៗដែលបានអនុញ្ញាតតាមច្បាប់ស្តីពីសារពើពន្ធប្រសិនបើមាន។

- **ការគណនាពន្ធលើប្រាក់ចំណូល**

៥. ពន្ធលើប្រាក់ចំណូល ត្រូវបានគណនាដូចតទៅៈ

**ក.** គណនាពន្ធលើប្រាក់ចំណូលដោយយកប្រាក់ចំណូលជាប់ពន្ធ ដូចបានគណនាក្នុងកថាខណ្ឌទី៤ ចំណុចខាងលើទៅគុណនឹងអត្រាពន្ធដូចមានចែងក្នុងមាត្រា ២០ ថ្មី (មួយ) នៃច្បាប់សារពើពន្ធ

**ខ.** ដកឥណទានពន្ធបរទេសតាមមាត្រា ៣៦ នៃច្បាប់ស្តីពីសារពើពន្ធ។ ចំពោះសហគ្រាសនិវាសជនដែលមានប្រាក់ចំណូលប្រភពបរទេស ប៉ុន្តែមិនត្រូវឱ្យលើសពីពន្ធលើប្រាក់ចំណូលក្នុងវាក្យខណ្ឌ ក នៃចំណុចនេះទេ។

**គ.** ដកប្រាក់ពន្ធបង់មុនលើការបែងចែកភាគលាភដែលបានបង់ដោយសហគ្រាសតាមមាត្រា២៣ថ្មី (ពីរ) នៃច្បាប់ស្តីពីសារពើពន្ធ ប៉ុន្តែមិនត្រូវឱ្យលើសពីពន្ធលើប្រាក់ចំណូលបន្ទាប់ពីកាត់កងឥណទានពន្ធបរទេស ក្នុងវាក្យខណ្ឌ ខ នៃកថាខណ្ឌនេះទេ។ ការដកពន្ធបង់មុនលើការបែងចែកភាគកលាភក្នុងវាក្យខណ្ឌនេះកម្រិតត្រឹមតែពន្ធបង់មុនលើការបែងចែកភាគលាភណាមួយចេញពីប្រាក់ចំណូលដែលកើតឡើងក្នុងឆ្នាំជាប់ពន្ធប៉ុណ្ណោះ។

- **ការគណនាពន្ធលើប្រាក់ចំណូលត្រូវបង់ ឬឥណទានពន្ធសម្រាប់ឆ្នាំជាប់ពន្ធ**

៦. ពន្ធលើប្រាក់ចំណូលត្រូវបង់ ឬឥណទានពន្ធសម្រាប់ឆ្នាំជាប់ពន្ធត្រូវបានកំណត់ដូចតទៅៈ

**ក.** ក្នុងករណីដែលលទ្ធផលគណនាតាមកថាខណ្ឌទី៥ចំណុចខាងលើនេះ មានចំនួនច្រើនជាងផលបូកនៃឥណទានពន្ធកាត់ទុកតាមបទប្បញ្ញត្តិ និងចំនួនប្រាក់រំដោះពន្ធលើប្រាក់ចំណូល ដែលអ្នកជាប់ពន្ធបានបង់សម្រាប់ឆ្នាំជាប់ពន្ធតាមមាត្រា ២៨ ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ សហគ្រាសត្រូវបង់បន្ថែមនូវចំនួនលម្អៀងនោះជូនរដ្ឋបាលសារពើពន្ធ។

**ខ.** ប្រសិនបើលទ្ធផលគណនាតាមកថាខណ្ឌទី៥នេះ មានចំនួនតិចជាងផលបូកនៃឥណទានពន្ធកាត់ទុកតាមបទប្បញ្ញត្តិ និងចំនួនប្រាក់រំដោះពន្ធលើប្រាក់ចំណូលដែលអ្នកជាប់ពន្ធបានបង់សម្រាប់ឆ្នាំជាប់ពន្ធតាមមាត្រា ២៨ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ សហគ្រាសអាចប្រើប្រាស់ចំនួនលម្អៀងជាឥណទានសម្រាប់កាត់កងទៅនឹងការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូលនៅក្នុងខែបន្ទាប់ពីខែដែលបានដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ឬពន្ធលើប្រាក់ចំណូលសម្រាប់ឆ្នាំបន្ទាប់។

**គ.** មុននឹងធ្វើការទូទាត់ប្រាក់ពន្ធតាមវាក្យខណ្ឌ ក ក្នុងកថាខណ្ឌនេះ ឬយោងទៅប្រើជាប្រាក់រំដោះពន្ធលើប្រាក់ចំណូលតាម វាក្យខណ្ឌ ខ ក្នុងកថាខណ្ឌនេះ សហគ្រាសត្រូវតែកំណត់ជាមុននូវបំណុលពន្ធអប្បបរមាក្នុងករណីដែលសហគ្រាសមិនបានទទួលលិខិតបញ្ជាក់ពីការកាន់បញ្ជិកាគណនេយ្យត្រឹមត្រូវពីអគ្គនាយកដ្ឋានពន្ធដារ។

- **ការគណនាប្រាក់ពន្ធអប្បបរមា ប្រាក់ពន្ធត្រូវបង់ ឬឥណទានពន្ធសម្រាប់ឆ្នាំជាប់ពន្ធ**

ប្រាក់ពន្ធអប្បបរមា ប្រាក់ពន្ធត្រូវបង់ ឬឥណទានពន្ធសម្រាប់ឆ្នាំជាប់ពន្ធ ត្រូវបានកំណត់ដូចតទៅ៖

**ក.** ពន្ធអប្បបរមាដូចមានចែងក្នុងមាត្រា ២៤ ថ្មី (ពីរ) នៃច្បាប់ស្តីពីសារពើពន្ធ ត្រូវបង់នៅពេលធ្វើការទូទាត់ប្រាក់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ។ ពន្ធអប្បបរមាត្រូវបង់សម្រាប់ឆ្នាំជាប់ពន្ធណាមួយ អាចត្រូវបានកាត់បន្ថយដោយពន្ធលើប្រាក់ចំណូលដែលបានបង់ជាក់ស្តែងក្នុងឆ្នាំជាប់ពន្ធនោះ។

**ខ.** ក្នុងករណីដែលពន្ធលើប្រាក់ចំណូលដែលបានគណនាក្នុងកថាខណ្ឌទី៥ចំណុចខាងលើនេះ លើសពីពន្ធអប្បបរមា សហគ្រាសគ្មានទឹកប្រាក់ពន្ធអប្បបរមាត្រូវបង់ទេ ហើយសហគ្រាសត្រូវអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងវាក្យខណ្ឌ ក និងខ នៃកថាខណ្ឌទី៦ ចំណុចខាងលើនេះ នៅពេលដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ។

**គ.** ក្នុងករណីដែលពន្ធអប្បបរមាលើសពីពន្ធលើប្រាក់ចំណូល ពន្ធអប្បបរមា ត្រូវបានកាត់បន្ថយដោយឥណទានពន្ធរបស់សហគ្រាសតាមវាក្យខណ្ឌ ក ក្នុងកថាខណ្ឌទី៦ ចំណុចខាងលើនេះ (គឺផលបូកនៃចំនួនប្រាក់រំដោះពន្ធលើប្រាក់ចំណូលដែលសហគ្រាសបានបង់សម្រាប់ឆ្នាំជាប់ពន្ធតាមមាត្រា ២៨ ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ និងប្រាក់ពន្ធដែលសហគ្រាសដទៃបានកាត់ទុកតាមបទប្បញ្ញត្តិ និងឥណទានពន្ធលើប្រាក់ចំណូលយោងពីឆ្នាំមុន ប្រសិនបើមាន) ក្នុងនោះ៖

- ប្រសិនបើពន្ធអប្បបរមាច្រើនជាងឥណទានពន្ធតាមកថាខណ្ឌទី៣ នៃប្រការនេះ សហគ្រាសត្រូវបង់បន្ថែមនូវចំនួនលម្អៀង
- ប្រសិនបើឥណទានពន្ធតាមកថាខណ្ឌ៣ នៃប្រការនេះ ច្រើនជាងពន្ធអប្បបរមា ចំនួនលម្អៀងត្រូវបានអនុញ្ញាតឱ្យយោងទៅប្រើប្រាស់ជាឥណទានពន្ធលើប្រាក់ចំណូលសម្រាប់ឆ្នាំជាប់ពន្ធបន្ទាប់ (ប្រាក់រំដោះពន្ធលើប្រាក់ចំណូល ឬពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ)។

# ជំពូកទី២

# ការរីករាលដាលនៃវិស័យសេវាកម្ម

វិស័យសេវាកម្ម កកើតឡើងជាយូរលង់ណាស់មកហើយ ប៉ុន្តែនៅចុងស.វទី២០នេះ ឃើញថា កំណើននៃវិស័យប្រភេទនេះស្ទុះឡើងយ៉ាងគួរអោយកត់សំគាល់។

ក្នុងជំពូកនេះនឹងធ្វើការសិក្សាអំពីវិស័យប្រភេទនេះ។

## ២.១. ប្រវត្តិត្រួសៗនៃបដិវត្តសង្គមមនុស្ស

គេអាចចែកសង្គមមនុស្ស ជា៣ដំណាក់កាលបាន គឺសង្គមក្នុងសម័យមុនបដិវត្តឧស្សាហកម្ម សង្គមបដិវត្តឧស្សាហកម្ម និងសង្គមក្រោយបដិវត្តឧស្សាហកម្ម។

គិតមកត្រឹមស.វទី១៨ ដែលជាសម័យកាលមុនបដិវត្តឧស្សាហកម្ម ការប្រកបរបររកស៊ីចិញ្ចឹមជីវិត គឺមានលក្ខណៈតូចតាច ហើយដំណើរការនៃសង្គម គឺមិនសូវជាមានលក្ខណៈស្មុគស្មាញប៉ុន្មានទេ។ មនុស្សភាគច្រើនធ្វើការបរបាញ់និងចិញ្ចឹមសត្វ ដាំដុះបន្លែ ធ្វើកសិកម្មតាមបែបពនេរចរ។ សកម្មភាពទាំងអស់ គឺប្រើប្រាស់កម្លាំងមនុស្ស និង សត្វជាមូលដ្ឋាន។ ពួកគេ បរិភោគចំណីអាហារ និង ស្លៀកសម្លៀកបំពាក់ ធ្វើដោយដៃខ្លួនឯង ហើយចំណែកឯសកម្មភាពទិញ-ដូរ ពុំសូវជាមានឡើយ។ ការវិវត្ត កើតមានឡើងជាបន្តបន្ទាប់ ហើយការផ្លាស់ប្តូរយ៉ាងធំធេងនៃប្រវត្តិសាស្ត្ររបស់មនុស្សជាតិ បានកើតមានឡើងនៅក្នុងអំឡុងស.វទី ១៨ និងពាក់កណ្តាលស.វទី១៩ ដែលគេគ្រប់គ្នាស្គាល់ថាជា **បដិវត្តឧស្សាហកម្ម**។ ចំណុចចាប់ផ្តើម គឺនៅក្នុងចក្រភពអង់គ្លេស មុនពេលរីកសាយទៅកាន់បណ្តាប្រទេសផ្សេងៗនៅទូទាំងសកលលោក។ របបគំហើញនៃម៉ាស៊ីនដើរដោយចំហាយទឹក គឺជាចំណុចរបត់មួយយ៉ាងសំខាន់ និងត្រូវបានប្រើប្រាស់នៅក្នុងឧស្សាហកម្មកប្បាសដំបូងគេ ដែលធ្វើអោយមានការចាប់ផ្តើមរីកសាយភាយនូវឧស្សាហកម្មកែច្នៃធំៗ ហើយកំណើននៃរោងចក្រនិងតម្រូវការនៃកម្លាំងពលកម្មយ៉ាងច្រើន កើតមានឡើងយ៉ាងសន្ធឹកសន្ធាប់។[24] ចាប់ពីពេលនោះមក រហូតទល់បច្ចុប្បន្ននេះ គឺជាសង្គមក្រោយសម័យបដិវត្តឧស្សាហកម្ម ដែលមានការផ្លាស់ប្តូរពីការផលិតទំនិញ ទៅជាការផ្តត់ផ្គង់សេវាវិញ។ គ្រូពេទ្យ គ្រូបង្រៀន មេធាវី គឺសុទ្ធតែជាអ្នកដែលធ្វើការងារក្នុងវិស័យសេវាកម្ម ហើយក្នុងសង្គមនេះផងដែរ បច្ចេកវិទ្យា ព័ត៌មាន និង សេវាកម្ម ត្រូវបានគេអោយតម្លៃជាងការផលិតទំនិញ។[25]

[24] Jim Chappelow, "*Industrialization*," Investopedia, https://www.investopedia.com/terms/i/industrialization.asp (ចូលទស្សនាថ្ងៃទី១៩ មិថុនា ២០២០)។

[25] Ashley Crossman, "*Post-Industrial Society in Sociology*," ThoughtCo., https://www.thoughtco.com/post-industrial-society-3026457 (ចូលទស្សនាថ្ងៃទី១៩ មិថុនា ២០២០)។

## ២.២. មូលហេតុនៃការរីករាលដាលនៃវិស័យសេវាកម្ម

វិស័យសេវាកម្មចាប់ផ្តើម រីកសាយ និង ក្លាយទៅជាផ្នែកសំខាន់នៃសេដ្ឋកិច្ច របស់បណ្តាប្រទេសជាច្រើន នៅទូទាំងសកលលោក ហើយហេតុផលមួយចំនួនដែលលើកយកមកពន្យល់ថាអំពីមូលហេតុនេះគឺមានដូចខាងក្រោម៖

- **ការកើនឡើងនៃតម្រូវការសេវាកម្ម**

កំណើននៃសេវាកម្ម កើតឡើងស្របពេលជាមួយនឹងកំណើននៃវណ្ណៈកណ្តាល និង ប្រាក់ចំណូលរបស់គ្រួសារអ្នកមាន ដូចនេះហើយ សេវាកម្មដូចជា សុខភាព ការអប់រំ និងការកំសាន្តដូចជាវិស័យទេសចរណ៍ជាដើម គឺទទួលបាននូវចំណាប់អារម្មណ៍ និងក្លាយជាតម្រូវការ។ ក្នុងពិភពអាជីវកម្មវិញ ភាពចាំបាច់នៃសេវាកម្មត្រូវបានគេទទួលស្គាល់។ ដំណើរការរបស់អាជីវកម្ម នឹងមានភាពងាយស្រួលនិងប្រព្រឹត្តិទៅបានល្អ ប្រសិនបើសេវាកម្មចូលរួមចំណែក។ សេវាទាំងនោះរួមមានដូចជាគណនេយ្យ, បច្ចេកវិទ្យា, ប្រព័ន្ធដឹកជញ្ជូននូវទំនិញ, ការគ្រប់គ្រង, ធនធានមនុស្ស និង ការសិក្សាស្រាវជ្រាវអំពីផលិតផល ឬ ផ្សេងៗ។

- **ការជួយសម្រួលភាពស្មុគស្មាញនៃដំណើរការអាជីវកម្ម**

ក្រុមហ៊ុនផ្តល់សេវាកម្មប្រឹក្សា ជួយអាជីវកម្មដើម្បីដោះស្រាយជាមួយនឹងអ្វីៗដែលអាជីវកម្មនោះកំពុងប្រឈម ដូចជាបញ្ហាច្បាប់ បច្ចេកវិទ្យា ឬបញ្ហាប្រឈមនឹងទីផ្សារផ្សេងៗ ដោយយកជំនាញ និង ចំណេះដឹងរបស់ពួកគេមកធ្វើការផ្តត់ផ្គង់ ជួយសម្រួលភាពស្មុគស្មាញ។[26]

- **ជួយធ្វើអោយកំណើនមានការងារធ្វើរបស់ប្រជាជនកើនឡើង**

វិស័យសេវាកម្ម បានបង្កើតការងារជាច្រើនដល់ប្រជាជន ដែលធ្វើអោយអត្រានៃភាពគ្មានការងារធ្វើធ្លាក់ចុះ និងមានការកើនឡើងនៃអត្រាផ.ស.សក្នុងមនុស្សម្នាក់។ គេអាចនិយាយបានថាប្រទេសជាតិកាន់តែរីកចម្រើន ឧស្សាហកម្មសេវាកម្មកាន់តែរីកចម្រើន។ ជាក់ស្តែង បណ្តាប្រទេសនៅអឺរ៉ុប និងនៅសហរដ្ឋអាមេរិច ភាគរយដែលចូលរួមក្នុងGDP ភាគច្រើនគឺមានប្រភពមកពីឧស្សាហកម្មនេះ។ វិស័យនេះ រួមចំណែកយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍប្រទេសជាតិ តួយ៉ាងដូចជានៅក្នុងចក្រភពអង់គ្លេស ភាគរយដែលវិស័យសេវាកម្ម គឺមានចំនួន៨០%នៃGDP និង ៧០%នៃសន្ទុះកំលាំងការងារ នៅសហរដ្ឋអាមេរិច។[27] បើសិនជាយើងងាក

[26] Zach Lazzari, "*What are the causes of rapid growth in the service insutry?*", Chron, https://smallbusiness.chron.com/causes-rapid-growth-service-industry-16007.html (ចូលទស្សនាថ្ងៃទី១៩ មិថុនា ២០២០)។

[27] Tejvan Pettinger, "*Tertiary- Service sector of the economy,*" Economics Help, https://www.economicshelp.org/tertiary-service-sector/ (ចូលទស្សនាថ្ងៃទី ១៩ មិថុនា ២០២០)។

ក្រឡេកមកមើលក្នុងប្រទេសកម្ពុជាវិញ ឃើញថា កំណើនGDPផលពិតដែលបានមកពីវិស័យសេវាកម្មពីឆ្នាំ ២០១០ ទៅ ២០១៩មានដូចរូបភាពខាងក្រោម[28]៖




រូបភាពទី១៖ សូចនាករម៉ាក្រូសេដ្ឋកិច្ច

ក្នុងឆ្នាំ ២០១៧ ទិន្នផលមកពីឧស្សាហកម្មសេវាកម្មនៅក្នុងGDP គឺមានចំនួន ៤១.៩%។ ចំនួននេះគឺអាចអោយយើងនិយាយបានថា វិស័យសេវាកម្ម គឺមានសារៈសំខាន់ខ្លាំងណាស់ចំពោះសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។[29]

## ២.៣. វិស័យសេវាកម្ម

ដូចដែរបានធ្វើការរៀបរាប់ត្រួសៗមកខាងលើអំពីវិស័យសេវាកម្មហើយ វិស័យនេះ ជាវិស័យដែលផលិតនូវទំនិញអរូបិយ និងលក់ទៅអោយអតិថិជន។ សេវាកម្មនេះផងដែរ ក៏អាចប្រើប្រាស់ទំនិញដែរ ប៉ុន្តែគ្រាន់តែជាសមាសធាតុបន្ថែមនៃការផ្តល់សេវាកម្មទៅអោយអតិថិជនតែប៉ុណ្ណោះ។ វិស័យនេះ ផ្តោតសំខាន់ទៅលើការធ្វើទំនាក់ទំនងរវាងមនុស្សនឹងមនុស្ស និងផ្តត់ផ្គង់សេវាដល់អតិថិជនដែលជាអ្នកប្រើប្រាស់ចុងក្រោយ ជៀសជាងការផ្គត់ផ្គង់ទំនិញរូបិយដែលមើលឃើញផ្ទាល់នឹងភ្នែក[30]។ ខាងក្រោមនេះ គឺជាឧទាហរណ៍មួយចំនួននៃវិស័យសេវាកម្ម៖

- ក្រុមហ៊ុនលក់រាយ

[28] https://www.mef.gov.kh/assets/images/home_GDP_20191024.png(ចូលទស្សនាថ្ងៃទី ១៩ មិថុនា ២០២០)

[29] "The World Factbook". CIA.gov. Central Intelligence Agency. (ចូលទស្សនាថ្ងៃទី១៩ មិថុនា ២០២០)

[30] Tertiary sector of the economy. (ចូលទស្សនាថ្ងៃទី១៩ មិថុនា ២០២០). In *Wikipedia*. ដកស្រង់ចេញពី https://en.m.wikipedia.org/wiki/Tertiary_sector_of_the_economy

- សេវាកម្មខាងកុំព្យូទ័រ និង I.T
- សេវាកម្មខាងកន្លែងស្នាក់នៅ (ផ្ទះសំណាក់) និងទេសចរណ៍
- ភោជនីយ៍ដ្ឋាន និងហាងកាហ្វេ
- ប្រព័ន្ធដឹកជញ្ជូន...។

# ជំពូកទី៣

# ការប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំរបស់ក្រុមហ៊ុនសេវាកម្ម

មុននឹងធ្វើការប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំរបស់ក្រុមហ៊ុនសេវាកម្មបានត្រឹមត្រូវ ជាដំបូងត្រូវស្វែងយល់អោយបានច្បាស់នូវលិខិតប្រកាសពន្ធជាមុនសិន។

## ៣.១.លិខិតប្រកាសពន្ធ

តាមមាត្រា២៩ថ្មី នៃចសព លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ត្រូវធ្វើនៅក្នុងទម្រង់ពបច ០១ (FORM TOI1) ដែលមានចំនួនសរុប ១៦ ទំព័រ (ឧបសម្ព័ន្ធទី១)។ ដោយសារតែទំហំ និងដែនកំណត់ក្នុងការស្រាវជ្រាវនេះ គឺផ្តោតតែទៅលើក្រុមហ៊ុនសេវាកម្ម នោះចំណុច Cនិង D ដែលពាក់ព័ន្ធនឹងសហគ្រាសផលិតកម្ម និងសហគ្រាសក្រៅផលិតកម្ម មិនត្រូវបានយកមកធ្វើការបរិយាយឡើយ។

- **ទំព័រទី១** បង្ហាញអំពីព័ត៌មានទូទៅរបស់សហគ្រាស រួមមានៈ លេខអត្តសញ្ញាណកម្មសារពើពន្ធ ឈ្មោះសហគ្រាស ចំនួនសាខាសហគ្រាស កាលបរិច្ឆេទចុះបញ្ជីពន្ធដារ ឈ្មោះអភិបាល/បណ្ណាធិការ/កម្មសិទ្ធិករ សកម្មភាពអាជីវកម្មចម្បង ឈ្មោះគណនេយ្យករ/ភ្នាក់ងារសេវាកម្មពន្ធដារ អាសយដ្ឋានទីស្នាក់ការសហគ្រាស គ្រឹះស្ថានជាគោលដើម និងឃ្លាំងបច្ចុប្បន្ន ការកត់ត្រាបញ្ជីកាគណនេយ្យ កម្រិតអនុលោមភាពសារពើពន្ធ សវនកម្មឯករាជ្យដែលតម្រូវដោយច្បាប់ ទ្រង់ទ្រាយគតិយុត្តិ/ទម្រង់នៃប្រតិបត្តិការអាជីវកម្ម ការលើកលែងពន្ធលើប្រាក់ចំណូល អត្រាពន្ធលើប្រាក់ចំណូល ពន្ធលើប្រាក់ចំណូលដែលត្រូវបង់ និងឥណទានពន្ធ ដោយមានហត្ថលេខាទទួលខុសត្រូវរបស់អភិបាល បណ្ណាធិការ ឬកម្មសិទ្ធករសហគ្រាស។
- **ទំព័រទី២** ទំព័រនេះមានពីរផ្នែក។ ពាក់កណ្តាលផ្នែកខាងលើ បង្ហាញអំពីការចូលរួមមូលធនរបស់ម្ចាស់ភាគហ៊ុន ដូចជា ឈ្មោះអ្នកចូលហ៊ុន អាសយដ្ឋានបច្ចុប្បន្នរបស់ម្ចាស់ភាគហ៊ុន មុខងារក្នុងសហគ្រាស និងភាគហ៊ុន ឬចំណែកដែលមាន។ ចំណែកឯពាក់កណ្តាលផ្នែកខាងក្រោម បង្ហាញអំពីព័ត៌មានអំពីនិយោជិតសហគ្រាសនៅក្នុងការិយបរិច្ឆេទ ដូចជាអ្នកគ្រប់គ្រងជាអ្នកចូលហ៊ុន អ្នកគ្រប់គ្រងមិនមែនជាអ្នកចូលហ៊ុន ចំនួនប្រាក់ខែដែលពួកគាត់ត្រូវបើក បុគ្គលិក-កម្មករជាប់ពន្ធលើប្រាក់បៀវត្ស តួនាទីនៅក្នុងក្រុមហ៊ុន ប្រាក់បៀវត្សក្រៅពីអត្ថប្រយោជន៍បន្ថែម និងអត្ថប្រយោជន៍បន្ថែមដែលទទួលបានក្នុងការិយបរិច្ឆេទ។

❖ **ទំព័រទី៣ និងទំព័រទី៤** បង្ហាញពីតារាងតុល្យការគិតត្រឹមការិយបរិច្ឆេទណាមួយ។

នៅក្នុងតារាងតុល្យការនេះ គេចែកវាចេញជា២ផ្នែក។ **ផ្នែកទី១ (I)** និយាយអំពីទ្រព្យសកម្ម មាន២ចំណុចធំៗ គឺទ្រព្យសកម្មរយៈពេលវែង (A1) និងទ្រព្យសកម្មរយៈពេលខ្លី (A13) និង**ផ្នែកទី២ (I)** ជាមូលនិធិ/ទុនម្ចាស់ទ្រព្យ និងបំណុល (A27) មាន៣ចំណុចធំៗ គឺមូលនិធិ/ទុនម្ចាស់ទ្រព្យ (A28) បំណុលរយៈពេលវែង (A36) និងបំណុលរយៈពេលខ្លី(A41)។

- **A0** (ទ្រព្យសកម្មសរុប) = **A1** (ទ្រព្យសកម្មរយៈពេលវែង)+ **A13** (ទ្រព្យសកម្មរយៈពេលខ្លី)
  - ចាប់ពី A2 ដល់ A12 ជាធាតុរបស់ទ្រព្យសកម្មរយៈពេលវែង ហើយយកធាតុទាំងនោះមកបូកសរុបក្នុង **A1 (ទ្រព្យសកម្មរយៈពេលវែង)**
  - ចាប់ពី A14 ដល់ A26 ជាធាតុរបស់ទ្រព្យសកម្មរយៈពេលខ្លី ហើយយកធាតុទាំងនោះមកបូកសរុបក្នុង **A13 (ទ្រព្យសកម្មរយៈពេលខ្លី)**

**តារាងទី៥៖ ទ្រព្យសកម្មក្នុងតារាងតុល្យការ (I)**

| **បរិយាយ** | **យោង** | N | N-1 |
|---|---|---|---|
| I.**ទ្រព្យសកម្ម** (A0=A1+A13) | **A0** | | |
| **ទ្រព្យសកម្មរយៈពេលវែង** [A1=សរុប(A2:A12)] | **A1** | | |
| ដីធ្លីរបស់សហគ្រាស | A2 | | |
| ការរៀបចំតុបតែងលំអដីធ្លីរបស់សហគ្រាស | A3 | | |
| សំណង់អាគាររបស់សហគ្រាស | A4 | | |
| សំណង់អាគារលើដីធ្លីក្រោមភតិសន្យា | A5 | | |
| ទ្រព្យសកម្មរយៈពេលវែងកំពុងដំណើរការ | A6 | | |
| រោងចក្រ (ក្រៅពីអាគារ) និងបរិក្ខារ | A7 | | |
| កេរ្តិ៍ឈ្មោះ/មូលនិធិពាណិជ្ជកម្ម | A8 | | |
| ចំណាយបង្កើតសហគ្រាសដំបូង | A9 | | |
| ទ្រព្យសកម្មក្រោមភតិសន្យា និងបុព្វលាភនៃការប្រើប្រាស់ | A10 | | |
| វិនិយោគក្នុងសហគ្រាសដទៃ | A11 | | |
| ទ្រព្យសកម្មរយៈពេលវែងផ្សេងៗ | A12 | | |
| **ទ្រព្យសកម្មរយៈពេលខ្លី** [A13=សរុប(A14:A26)] | **A13** | | |

| បរិយាយ | យោង | N | N-1 |
|---|---|---|---|
| ស្តុកវត្ថុធាតុដើម និងសំភារៈផ្គត់ផ្គង់ | A14 | | |
| ស្តុកទំនិញ | A15 | | |
| ស្តុកផលិតផលសម្រេច | A16 | | |
| ផលិតផលកំពុងផលិត | A17 | | |
| គណនីត្រូវទទួល/អតិថិជន | A18 | | |
| គណនីត្រូវទទួលផ្សេងៗ | A19 | | |
| ចំណាយបានកត់ត្រាមុន | A20 | | |
| សាច់ប្រាក់នៅក្នុងបេឡា និងនៅធនាគារ | A21 | | |
| ឥណទានប្រាក់រំដោះពន្ធលើប្រាក់ចំណូល | A22 | | |
| ឥណទានអាករលើតម្លៃបន្ថែម | A23 | | |
| ឥណទានពន្ធ-អាករដទៃទៀត | A24 | | |
| ទ្រព្យសកម្មរយៈពេលខ្លីផ្សេងៗ | A25 | | |
| លំអៀងពីការប្តូរប្រាក់នៃទ្រព្យសកម្ម | A26 | | |

- **A27**(មូលនិធិ/ទុនម្ចាស់ទ្រព្យ និងបំណុល)= **A28**(មូលនិធិ/ទុនម្ចាស់ទ្រព្យ)+**A36** (បំណុលរយៈពេលវែង)+**A41** (បំណុលរយៈពេលខ្លី)
  - ចាប់ពី A29 ដល់ A35 ជាធាតុរបស់មូលនិធិ/ទុនម្ចាស់ទ្រព្យ ហើយយកធាតុទាំងនោះមកបូកសរុបនៅក្នុង **A28 (មូលនិធិ/ទុនម្ចាស់ទ្រព្យ)**
  - ចាប់ពី A37 ដល់ A40 ជាធាតុរបស់បំណុលរយៈពេលវែង ហើយយកធាតុទាំងនោះមកបូកសរុបនៅក្នុង **A36 (បំណុលរយៈពេលវែង)**
  - ចាប់ពី A42 ដល់ A50 ជាធាតុរបស់បំណុលរយៈពេលខ្លី ហើយយកធាតុទាំងនោះមកបូកសរុបនៅក្នុង **A41 (បំណុលរយៈពេលខ្លី)**

(តារាងនៅទំព័របន្ទាប់)

## តារាងទី៦៖ មូលនិធិ/ទុនម្ចាស់ទ្រព្យ និងបំណុលនៃតារាងតុល្យការ (II)

| **បរិយាយ** | **យោង** | N | N-1 |
|---|---|---|---|
| **មូលនិធិ/ទុនម្ចាស់ទ្រព្យ** [A28=សរុប( A29:A35 )] | **A28** | | |
| មូលធន/មូលធនភាគហ៊ុន | A29 | | |
| តម្លៃលើសនៃការលក់ប័ណ្ណភាគហ៊ុន | A30 | | |
| មូលធនបំរុងតាមច្បាប់ | A31 | | |
| លំអៀងលើសនៃការវាយតំលៃឡើងវិញនូវទ្រព្យសកម្ម | A32 | | |
| មូលធនបំរុងផ្សេងៗ | A33 | | |
| លទ្ធផលចំណេញ/(ខាត) យោងពីមុន | A34 | | |
| លទ្ធផលចំណេញ/(ខាត) នៃការិយបរិច្ឆេទនេះ | A35 | | |
| **បំណុលរយៈពេលវែង** [A36=សរុប( A37:A40 )] | **A36** | | |
| បំណុលភាគីជាប់ទាក់ទិន | A37 | | |
| បំណុលធនាគារ និងបំណុលភាគីមិនជាប់ទាក់ទិនផ្សេងៗ | A38 | | |
| សំវិធានធន | A39 | | |
| បំណុលរយៈពេលវែងផ្សេងៗ | A40 | | |
| **បំណុលរយៈពេលខ្លី** [A41=សរុប( A42:A50 )] | **A41** | | |
| សាច់ប្រាក់ដកពីធនាគារលើសប្រាក់បញ្ញើ | A42 | | |
| ចំណែកចរន្តនៃបំណុលមានការប្រាក់ | A43 | | |
| គណនីត្រូវសងបុគ្គលជាប់ទាក់ទិន | A44 | | |
| គណនីត្រូវសងផ្សេងៗ | A45 | | |
| ចំណូលកត់មុន ចំណាយបង្ករ និងបំណុលរយៈពេលខ្លីផ្សេងៗ | A46 | | |
| សំវិធានធន | A47 | | |
| ពន្ធលើប្រាក់ចំណូលត្រូវបង់ | A48 | | |
| ពន្ធ-អាករផ្សេងៗត្រូវបង់ | A49 | | |
| លំអៀងពីការប្តូរប្រាក់នៃទ្រព្យអកម្ម | A50 | | |

- **ទំព័រទី៥និងទី៦** បង្ហាញពីរបាយការណ៍លទ្ធផលសម្រាប់ការិយបរិច្ឆេទណាមួយហើយBជាអក្សរតំណាង។
  - **B0**(ចំណូលប្រតិបត្តិការសរុប) = **B1**(ចំណូលពីការលក់ផលិតផល)+ **B2**(ចំណូលពីការលក់ទំនិញ)+**B3**(ចំណូលពីការផ្គត់ផ្គង់សេវា)
  - **B6** (ចំណេញដុល) = **B0**(ចំណូលប្រតិបត្តិការសរុប)- **B4**(ថ្លៃដើមផលិតផលបានលក់របស់សហគ្រាសផលិតកម្ម)- **B5**(ថ្លៃដើមទំនិញបានលក់របស់សហគ្រាសក្រៅពីផលិតកម្ម)- **B5.1**(ថ្លៃដើមសេវាបានផ្គត់ផ្គង់)

**តារាងទី៧៖ ចំណូលប្រតិបត្តិការនិងថ្លៃដើមនៃប្រតិបត្តិការ**

| **បរិយាយ** | **យោង** | N | N-1 |
|---|---|---|---|
| **ចំណូលប្រតិបត្តិការ** [B0=សរុប( B1:B3 )] | **B0** | | |
| ការលក់ផលិតផល | B1 | | |
| ការលក់ទំនិញ | B2 | | |
| ការផ្គត់ផ្គង់សេវា | B3 | | |
| ថ្លៃដើមផលិតផលបានលក់របស់សហគ្រាសផលិតកម្ម | B4 | | |
| ថ្លៃដើមទំនិញបានលក់របស់សហគ្រាសក្រៅពីផលិតកម្ម | B5 | | |
| ថ្លៃដើមសេវាបានផ្គត់ផ្គង់ | B5.1 | | |
| **ចំណេញដុល** ( B6=B0-B4-B5-B5.1 ) | **B6** | | |

- **B7** (ចំណូលផ្សេងៗ) = **(B8:B18)**
  - ចាប់ពី B8 ដល់ B18 ជាធាតុដែលទាក់ទងនឹងចំណូលផ្សេងៗក្រៅពីសកម្មភាពអាជីវកម្មសំខាន់ ហើយយកធាតុទាំងនោះបូកបញ្ចូលគ្នា រួចដាក់ចូលនៅក្នុង**B7(ចំណូលផ្សេងៗ)**

(តារាងនៅទំព័របន្ទាប់)

## តារាងទី៨៖ចំណូលផ្សេងៗ

| បរិយាយ | យោង | N | N-1 |
|---|---|---|---|
| **ចំណូលផ្សេងៗ** [B7=សរុប( B8:B18 )] | B7 | | |
| ឧបត្ថម្ភធន | B8 | | |
| ចំណូលពីភាគលាភបានទទួល ឬត្រូវទទួល | B9 | | |
| ចំណូលពីការប្រាក់បានទទួល ឬត្រូវទទួល | B10 | | |
| ចំណូលពីសួយសារបានទទួល ឬត្រូវទទួល | B11 | | |
| ចំណូលពីការជួលបានទទួល ឬត្រូវទទួល | B12 | | |
| ផលចំណេញ/តំលៃលើសពីការលក់ទ្រព្យសកម្មរយៈពេលវែង | B13 | | |
| ផលចំណេញពីការលក់មូលបត្រ/សញ្ញាប័ណ្ណ | B14 | | |
| ភាគចំណេញពីប្រតិបត្តិការរួមគ្នា | B15 | | |
| ផលចំណេញពីការប្តូរប្រាក់សម្រេចបាន | B16 | | |
| ផលចំណេញពីការប្តូរប្រាក់មិនទាន់សម្រេចបាន | B17 | | |
| ចំណូលដទៃទៀត | B18 | | |

- **B19** (ចំណាយប្រតិបត្តិការ) = **(B20:B38)**
    - ចាប់ពី B20 ដល់ B38 គឺជាធាតុដែលទាក់ទងនឹងចំណាយប្រតិបត្តិការ ហើយយកមកបូកសរុបបញ្ចូលគ្នា រួចដាក់ចូលនៅក្នុង**B19(ចំណាយប្រតិបត្តិការ)**

**តារាងទី៩៖ ចំណាយប្រតិបត្តិការ**

| **បរិយាយ** | **យោង** | N | N-1 |
|---|---|---|---|
| **ចំណាយប្រតិបត្តិការ** [B19=សរុប( B20:B38 )] | B19 | | |
| ចំណាយបៀវត្ស | B20 | | |
| ចំណាយប្រេង ឧស្ម័ន អគ្គិសនី និងទឹក | B21 | | |
| ចំណាយធ្វើដំណើរ និងចំណាយស្នាក់នៅ | B22 | | |
| ចំណាយដឹកជញ្ជូន | B23 | | |
| ចំណាយលើការជួល | B24 | | |
| ចំណាយលើការថែទាំ និងជួសជុល | B25 | | |
| ចំណាយលើការកំសាន្តសប្បាយ | B26 | | |
| ចំណាយកំរៃជើងសារ ផ្សាយពាណិជ្ជកម្មនិងចំណាយការលក់ | B27 | | |
| ចំណាយបង់ពន្ធ និងអាករផ្សេងៗ | B28 | | |
| ចំណាយលើអំណោយ | B29 | | |
| ចំណាយសេវាគ្រប់គ្រង ពិគ្រោះយោបល់ បច្ចេកទេស និងសេវាប្រហាក់ប្រហែល | B30 | | |
| ចំណាយលើសួយសារ | B31 | | |
| ចំណាយលើបំណុលទារមិនបាន | B32 | | |
| ចំណាយរំលស់ | B33 | | |
| ការកើនឡើង/ថយចុះ នូវសំវិធានធន | B34 | | |
| ខាតពីការលក់ទ្រព្យសកម្មរយៈពេលវែង | B35 | | |
| ខាតពីការប្តូរប្រាក់សម្រេចបាន | B36 | | |
| ខាតពីការប្តូរប្រាក់មិនទាន់សម្រេចបាន | B37 | | |
| ចំណាយផ្សេងៗ | B38 | | |

- **B39**(ប្រាក់ចំណេញ/(ខាត)ពីប្រតិបត្តិការ)= **B6**(ចំណេញដុល)+ **B7**(ចំណូលផ្សេងៗ)– **B19**(ចំណាយប្រតិបត្តិការ)
- **B40** ជា(ប្រាក់ចំណេញ/(ខាត) ពីប្រតិបត្តិការ)
- **B41** ជាចំណាយការប្រាក់បង់អោយអនិវាសនជន
- **B42** (ប្រាក់ចំណេញ/(ខាត) មុនបង់ពន្ធ) = **B39**(ប្រាក់ចំណេញ/(ខាត) ពីប្រតិបត្តិការ) – **B40** (ប្រាក់ចំណេញ/(ខាត) ពីប្រតិបត្តិការ) – **B41** (ចំណាយការប្រាក់បង់អោយអនិវាសនជន)
- **B43** ជាពន្ធលើប្រាក់ចំណូល
- **B44** (ប្រាក់ចំណេញក្រោយបង់ពន្ធ) = **B42** (ប្រាក់ចំណេញ/(ខាត) មុនបង់ពន្ធ) – **B43** (ពន្ធលើប្រាក់ចំណូល)

**តារាងទី១០៖ គណនាប្រាក់ចំណេញក្រោយបង់ពន្ធ**

| **បរិយាយ** | **យោង** | N | N-1 |
|---|---|---|---|
| **ប្រាក់ចំណេញ/(ខាត)ពីប្រតិបត្តិការ**(B39=B6+B7-B19) | B39 | | |
| ចំណាយការប្រាក់បង់អោយនិវាសនជន | B40 | | |
| ចំណាយការប្រាក់បង់អោយអនិវាសនជន | B41 | | |
| **ប្រាក់ចំណេញ/(ខាត)មុនបង់ពន្ធ**[B42=(B39-B40-B41)] | B42 | | |
| **ពន្ធលើប្រាក់ចំណូល** | B43 | | |
| **ប្រាក់ចំណេញក្រោយបង់ពន្ធ** (B44=B42-B43) | B44 | | |

❖ **ទំព័រទី៩ និងទី១០** បង្ហាញពីតារាងគណនាពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ហើយមានអក្សរ E ជាតំណាង។

ដើម្បីកំណត់លទ្ធផលសារពើពន្ធ និងប្រាក់ពន្ធលើប្រាក់ចំណូលឆ្នាំ ត្រូវធ្វើការគណនាដូចខាងក្រោម ៖

**ត្រូវយកលទ្ធផលគណនេយ្យនៃឆ្នាំជាប់ពន្ធមកធ្វើការកែតម្រូវដូចខាងក្រោម**

**បូក** ចំណាយមិនអាចកាត់កងបាន

**បូក** ចំណូលជាប់ពន្ធតែមិនបានកត់ត្រាក្នុងបញ្ជីគណនេយ្យ

**ដក** ចំណាយមិនបានកត់ត្រាក្នុងបញ្ជីគណនេយ្យ តែជាចំណាយកាត់កងបានក្នុងឆ្នាំ

**ដក** ចំណូលបានកត់ត្រាក្នុងបញ្ជីគណនេយ្យ តែជាចំណូលមិនត្រូវជាប់ពន្ធក្នុងឆ្នាំ

**ប្រាក់ចំណេញ (ខាត) ក្រោយនិយ័តកម្ម**

**បូក** ចំណាយសប្បុរសធម៌ដែលមិនអោយកាត់កង

**ប្រាក់ចំណេញ(ខាត)មុននិយ័តកម្មលើការប្រាក់**

**បូក(ដក)** និយ័តកម្មលើការប្រាក់

**ប្រាក់ចំណេញឬ(ខាត) ក្នុងការិយបរិច្ឆេទ**

**(ដក)** ខាតយោងពីឆ្នាំមុនអនុញ្ញាត

**ប្រាក់ចំណូលជាប់ពន្ធ** ***សម្រាប់គណនាពន្ធលើប្រាក់ចំណូល***

**ពន្ធលើប្រាក់ចំណូល (ប្រាក់ចំណូលជាប់ពន្ធ x អត្រាពន្ធ)**

**(ដក)** ឥណទានពន្ធបរទេស

**(ដក)** ឥណទានពន្ធបន្ថែមលើការបែងចែកភាគលាភក្នុងឆ្នាំ

**បំណុលពន្ធលើប្រាក់ចំណូល /ពន្ធអប្បបរមា (មួយណាខ្ពស់ជាង)**

**(ដក)** ឥណទានពន្ធកាត់ទុក

**(ដក)** ប្រាក់រំដោះពន្ធលើប្រាក់ចំណូល

**(ដក)** ឥណទានពន្ធលើប្រាក់ចំណូលយោងពីឆ្នាំមុន

➢ **ប្រាក់ពន្ធត្រូវបង់ ឬយោងទៅឆ្នាំបន្ទាប់**

## តារាងទី១១៖គណនាពន្ធលើប្រាក់ចំណូល

| **បរិយាយ** | | **យោង** | **ទឹកប្រាក់** | |
|---|---|---|---|---|
| ប្រាក់ចំណេញ/(ខាត) មុនបង់ពន្ធ | | E1 | | |
| **បូក** | **ចំណាយមិនអាចកាត់កងបាន** | | | |
| | ចំណាយរំលស់គណនេយ្យ | E2 | | |
| | ចំណាយលើការកំសាន្ត ការលំហែកំសាន្ត និងការទទួលភ្ញៀវ | E3 | | |
| | ការកើនឡើងនូវសំវិធានធន | E4 | | |
| | អំណោយ និងឧបត្ថម្ភធន | E5 | | |
| | ខាតពីការលក់ទ្រព្យសកម្មរយៈពេលវែង(តាមបញ្ជីគណនេយ្យ) | E6 | | |
| | ចំណាយមានលក្ខណៈស្តុកស្តម្ភហួសហេតុមិនអនុញ្ញាត | E7 | | |
| | ចំណាយមិនបម្រើឱ្យសកម្មភាពអាជីវកម្ម | E8 | | |
| | ខាតលើប្រតិបត្តិកាជាមួយបុគ្គលជាប់ទាក់ទិន | E9 | | |
| | ចំណាយលើការផាកពិន័យ និងទោសទណ្ឌផ្សេងៗ | E10 | | |
| | ចំណាយនៃការិយបរិច្ឆេទមុន | E11 | | |
| | ចំណាយពន្ធ និងអាករផ្សេងៗមិនអាចកាត់កងបាន | E12 | | |
| | លាភការរបស់អាជីវករ និងគ្រួសារ | E13 | | |
| | ផលប្រយោជន៍របស់អាជីវករ និងគ្រួសារ | E14 | | |
| | ចំណាយបៀវត្សពីការបម្រើការងារដែលមិនទាន់បានបើកក្នុង រយៈពេល៦០ថ្ងៃនៃឆ្នាំបន្ទាប់ | E15 | | |
| | ចំណាយផ្សេងៗមិនអនុញ្ញាតអោយកាត់កងបាន | E16 | | |
| | **សរុប[E17=សរុប(E2:E16)]** | **E17** | | |
| **បូក** | ចំណូលជាប់ពន្ធតែមិនត្រូវបានកត់ត្រាក្នុងបញ្ជីគណនេយ្យ | | | |
| | ការផ្គត់ផ្គង់ទំនិញ និងសេវាដោយឥតគិតថ្លៃ | E18 | | |
| | ការដាក់ទ្រព្យសកម្មរយៈពេលវែងអោយប្រើប្រាស់ដោយឥតគិតថ្លៃ | E19 | | |
| | ការកែលំអទ្រព្យសកម្មរយៈពេលវែងដោយអ្នកជួលមិនគិតថ្លៃពីម្ចាស់ | E20 | | |

| | បរិយាយ | យោង | ទឹកប្រាក់ | |
|---|---|---|---|---|
| | អំណោយនិងឧបត្ថម្ភកធនផ្សេងៗមិនទទួលស្គាល់ក្នុងគណនេយ្យ | E21 | | |
| | ផលចំណេញពីការលក់ទ្រព្យសកម្មរយៈពេលវែងតាមពន្ធ | E22 | | |
| | ចំណូលផ្សេងៗទៀតដែលមិនបានកត់ត្រាក្នុងបញ្ជី គណនេយ្យ | E23 | | |
| | **សរុប[E24=សរុប(E18:E23)]** | **E24** | | |
| | **ចំណាយមិនកត់ត្រាក្នុងបញ្ជីគណនេយ្យតែជាចំណាយកាត់កងបានក្នុងឆ្នាំ** | | | |
| | រំលស់អនុញ្ញាតតាមច្បាប់សារពើពន្ធ | E25 | | |
| | រំលស់ពិសេសអនុញ្ញាតតាមច្បាប់សារពើពន្ធ | E26 | | |
| | ការថយចុះនូវសំវិធានធន | E27 | | |
| | ខាតពីការលក់ទ្រព្យសកម្មរយៈពេលវែងតាមច្បាប់សារពើពន្ធ | E28 | | |
| | ចំណាយផ្សេងៗទៀតអនុញ្ញាតអោយកាត់កងបាន | E29 | | |
| | **សរុប[E30=សរុប(E25:E29)]** | **E30** | | |
| | **ចំណូលបានកត់ត្រាក្នុងបញ្ជីគណនេយ្យ តែជាចំណូលមិនត្រូវជាប់ពន្ធក្នុងឆ្នាំ** | | | |
| | ចំណូលលើភាគលាភទទួលបានពីអ្នកជាប់ពន្ធនិវាសនជន | E31 | | |
| | ចំណេញពីការលក់ទ្រព្យសកម្មរយៈពេលវែងតាមបញ្ជី គណនេយ្យ | E32 | | |
| | ចំណូលផ្សេងៗបានកត់ត្រាក្នុងបញ្ជីតែជាចំណូលមិនត្រូវជាប់ពន្ធក្នុងឆ្នាំ | E33 | | |
| | **សរុប[E34=សរុប(E31:E33)]** | **E34** | | |
| | **ប្រាក់ចំណេញ/(ខាត)ក្រោយនិយ័តកម្ម**<br>**E35 =E1+E17+E24–E30–E34** | **E35** | | |
| | ចំណាយសប្បុរសធម៌ដែលមិនអាចកាត់កង | E36 | | |
| | **ប្រាក់ចំណេញ/(ខាត)មុននិយ័តកម្មលើការប្រាក់**<br>**E37 =E35+ E36** | **E37** | | |
| | និយ័តកម្មលើការប្រាក់ | E38 | | |

| បរិយាយ | | យោង | ទឹកប្រាក់ | |
|---|---|---|---|---|
| | **ប្រាក់ចំណេញ/(ខាត)ក្នុងការិយបរិច្ឆេទ E39=E37+/-E38** | **E39** | | |
| **ដក** | ខាតយោងពីឆ្នាំមុនអនុញ្ញាត | E40 | | |
| | **ប្រាក់ចំណូល/(ខាត)ជាប់ពន្ធសំរាប់គណនាពន្ធលើប្រាក់ចំណូល E41=E39-E40** | E41 | | |
| | ពន្ធលើប្រាក់ចំណូលតាមអត្រា **(E42=E41 x អត្រាពន្ធ)** | E42 | | |
| **ដក** | ឥណទានពន្ធបរទេស | E43 | | |
| | បំណុលពន្ធលើប្រាក់ចំណូលក្រោយដកឥណទានពន្ធបរទេស **E44= E42-E43** | E44 | | |
| | ឥណទានពន្ធបរទេស | E45 | | |
| **ដក** | **បំណុលពន្ធលើប្រាក់ចំណូលក្រោយដកឥណទានពន្ធបរទេស E46= E44-E45** | **E46** | | |
| | ឥណទានពន្ធលើប្រាក់ចំណូលបន្ថែមលើការបែងចែកភាគលាភក្នុងឆ្នាំ | E47 | | |
| | **បំណុលពន្ធលើប្រាក់ចំណូលត្រូវបង់** | **E48** | | |
| | សម្រាប់សហគ្រាសដែលកាន់បញ្ជីគណនេយ្យត្រឹមត្រូវ E49=E46 | E49 | | |
| | សម្រាប់សហគ្រាសដែលកាន់បញ្ជីគណនេយ្យមិនត្រឹមត្រូវ E50=E46 or E47 (មួយណាខ្ពស់ជាង) | E50 | | |
| **ដក** | **ឥណទានពន្ធកាត់ទុកបានបង់ក្នុងឆ្នាំ** | **E51** | | |
| | ប្រាក់រំដោះពន្ធលើប្រាក់ចំណូលបានបង់ក្នុងឆ្នាំ | E52 | | |
| | ឥណទានពន្ធលើប្រាក់ចំណូលយោងពីឆ្នាំមុន | E52.1 | | |
| | ពន្ធលើប្រាក់ចំណូលត្រូវបង់/ត្រូវយោងទៅឆ្នាំបន្ទាប់<br>• សម្រាប់សហគ្រាសដែលកាន់បញ្ជីគណនេយ្យត្រឹមត្រូវ **E53=E49-E51-E52-E52.1**<br>• សម្រាប់សហគ្រាសដែលកាន់បញ្ជីគណនេយ្យមិនត្រឹមត្រូវ **E53= E50-E51-E52-E52.1** | E53 | | |

- **ទំព័រទី ១១ និងទី១២** បង្ហាញពីតារាងគណនាវិភាគទានសប្បុរសធម៌ ការប្រាក់អាចកាត់កងបាន និងឥណទានខាតយោងទៅមុខ។ វាចែកចេញជា២ផ្នែក ដែលផ្នែកខាងលើជា ការគណនាវិភាគទានសប្បុរសធម៌ និងផ្នែកខាងក្រោមជាការគណនាចំណាយការប្រាក់។

  - **ក. ការគណនាវិភាគទានសប្បុរសធម៌**

**តារាងទី១២៖ ការគណនាវិភាគទានសប្បុរសធម៌**

| បរិយាយ | យោង | ចំនួនទឹកប្រាក់ |
|---|---|---|
| ប្រាក់ចំណេញ/(ខាត)ក្រោយនិយ័តកម្ម **(F1=E35)** | F1 | |
| ចំណាយសប្បុរសធម៌ | F2 | |
| ប្រាក់ចំណូលសម្រាប់គណនាចំណាយសប្បុរសធម៌អតិបរមាអាចកាត់កងបាន **(F3=F1+F2)** | F3 | |
| ចំណាយសប្បុរសធម៌អតិបរមាអាចកាត់កងបាន **(F4=F3*៥%)** | F4 | |
| ចំណាយសប្បុរសធម៌អាចកាត់កងបានក្នុងឆ្នាំ**(F5=F4 or F2)** | F5 | |
| ចំណាយសប្បុរសធម៌មិនអាចកាត់កងបានត្រូវបូកបញ្ចូលប្រាក់ចំណូល/(ខាត)ជាប់ពន្ធ **(F6=F2-F5)** | F6 | |

➢ **ខ. ការគណនាចំណាយការប្រាក់**

**តារាងទី១៣៖ គណនាចំណាយការប្រាក់**

| **គណនាចំណាយការប្រាក់អនុញ្ញាតឱ្យកាត់កងក្នុងការិយបរិច្ឆេទ** | យោង | ចំនួនទឹកប្រាក់ | |
|---|---|---|---|
| ប្រាក់ចំណេញ/(ខាត) មុននិយ័តកម្មលើការប្រាក់ **(G1=E37)** | G1 | | |
| **បូក**: ចំណាយការប្រាក់ក្នុងការិយបរិច្ឆេទ | G2 | | |
| **ដក**: ចំណូលការប្រាក់ក្នុងការិយបរិច្ឆេទ | G3 | | |
| ប្រាក់ចំណេញសុទ្ធមុនការប្រាក់ **(G4=G1+G2-G3)** | G4 | | |
| ៥០%នៃប្រាក់ចំណេញគ្មានការប្រាក់ **(G5=G4*៥0%)** | G5 | | |
| ចំណូលការប្រាក់ក្នុងការិយបរិច្ឆេទ **(G6=G3)** | G6 | | |
| ចំណាយការប្រាក់អតិបរមាអនុញ្ញាតអោយកាត់កងបានក្នុងការិយបរិច្ឆេទ **(G7=G5+G6)** | G7 | | |
| ចំណាយការប្រាក់យោងពីឆ្នាំមុន | G8 | | |
| សរុបចំណាយការប្រាក់ក្នុងការិយបរិច្ឆេទ និងយោងពីឆ្នាំមុន **(G9=G2+G8)** | G9 | | |
| សរុបចំណាយការប្រាក់អាចកាត់កង **(G10=G7 ឬG9 ចំនួនមួយណាដែលតិចជាង)** | G10 | | |
| ចំនួនទឹកប្រាក់ដែលត្រូវបូកក្នុង/ដកពីប្រាក់ចំណូលជាប់ពន្ធ **(G11=G10-G2)** | G11 | | |
| បើG7តូចជាងG9,ចំណាយការប្រាក់យោងទៅមុខ **(G12=G9-G7)** | G12 | | |

➢ **គ. តារាងតាមដានលទ្ធផលសារពើពន្ធខាតយោងទៅមុខ**

ក្នុងករណីដែលមានការខាតបង់នៅក្នុងឆ្នាំជាប់ពន្ធណាមួយ ការខាតបង់នោះត្រូវចាត់ជាបន្ទុកសម្រាប់ឆ្នាំជាប់ពន្ធបន្ទាប់ ហើយត្រូវកាត់ចេញពីប្រាក់ចំណេញសម្រេចបាននៅក្នុងឆ្នាំជាប់ពន្ធបន្ទាប់នោះ។ បើប្រាក់ចំណេញនោះ មិនគ្រប់គ្រាន់សម្រាប់ទូទាត់ជាស្ថាពរទេ ចំណែកនៃការខាតបង់ដែលនៅសេសសល់ត្រូវយោងទៅឆ្នាំជាប់ពន្ធបន្តបន្ទាប់ រហូតដល់ឆ្នាំជាប់ពន្ធទី៥។ នៅពេលណាដែលការខាតបង់ មានលើសពីមួយឆ្នាំ ត្រូវអនុវត្តចំពោះការខាតបង់ទាំងឡាយតាមលំដាប់ដែលការខាតបង់បានកើតឡើង។

(តារាងនៅទំព័របន្ទាប់)

**តារាងទី១៤៖ តារាងតាមដានលទ្ធផលសារពើពន្ធខាតយោងទៅមុខ**

| ការិយបរិច្ឆេទ | លទ្ធផលចំណេញសារពើពន្ធក្នុងការិយបរិច្ឆេទ | លទ្ធផលខាតសារពើពន្ធក្នុងការិយបរិច្ឆេទ | ខាតអនុញ្ញាតប្រើប្រាស់កាត់កងក្នុងការិយបរិច្ឆេទ | ខាតអនុញ្ញាតប្រើប្រាស់កាត់កងបូកបន្ត | ខាតនៅសល់អនុញ្ញាតប្រើប្រាស់យោងទៅមុខ |
|---|---|---|---|---|---|
| N-5 | | | | | |
| N-4 | | | | | |
| N-3 | | | | | |
| N-2 | | | | | |
| N-1 | | | | | |
| N | | | | | |

- **ទំព័រទី១៣** បង្ហាញអំពីតារាងគណនារំលស់តាមច្បាប់សារពើពន្ធ ដែលទំព័រនេះបានសម្រាយទៅលើ ការគណនារំលស់ទៅលើប្រភេទទ្រព្យសកម្មរយៈពេលវែង ដែលត្រូវបានបែងចែកជាពីរ គឺ ទ្រព្យសកម្មអរូបី និងទ្រព្យសកម្មរូបី តាមច្បាប់សារពើពន្ធ(ឧបសម្ព័ន្ធទី១)។

➢ **រំលស់តាមច្បាប់ពន្ធ៖** រំលស់តាមច្បាប់ពន្ធមាន២ប្រភេទ គឺ

**១. រំលស់ថេរ** (ទ្រព្យអរូបី និង ទ្រព្យក្នុងថ្នាក់ទី១): ត្រូវកត់ត្រាតាមថ្នាក់មួយៗ និងគិតចំណេញ ខាត។ ទ្រព្យ ២ប្រភេទនេះ គឺរំលស់តាមវិធីរំលស់ថេរតាមអាយុកាលរបស់វា ហើយបើសិនជាករណីមិនស្គាល់នូវអាយុកាលរបស់ទ្រព្យអរូបីនោះទេ ត្រូវគុណជាមួយនឹងអត្រារំលស់ស្មើភាគ១០%។

**២. រំលស់ថយចុះជាលំដាប់** (ទ្រព្យថ្នាក់ទី២ ៣ និង៤): ត្រូវកត់ត្រារួមគ្នាតាមថ្នាក់ ពេលលក់ទ្រព្យមួយៗ មិនត្រូវគិតចំណេញខាតនោះទេ។គិតចំណេញខាតតែក្នុងករណីដូចខាងក្រោម៖

- លក់ចោលទ្រព្យទាំងអស់នៅក្នុងថ្នាក់
- មូលដ្ឋានគិតរំលស់អវិជ្ជមាន (ទទួលស្គាល់លក់ចំណេញ)

➢ **អត្រារំលស់របស់ទ្រព្យសកម្មរូបីទាំងអស់ចែកជា៤ថ្នាក់៖**

- ទ្រព្យថ្នាក់ទី១ មានអាគារ រចនាសម្ព័ន្ធរបស់អាគារ និងសំណង់ដែលជាសមាសភាគរបស់អាគារនោះ ហើយ ត្រូវធ្វើរំលស់តាមអត្រា៥% តាមវិធីរំលស់ស្មើភាគ។

- ទ្រព្យថ្នាក់ទី២ មានកុំព្យូទ័រ ប្រព័ន្ធពត៌មានអេឡិចត្រូនិច សូហ្វវែរ និង បរិក្ខារផ្ទុកទិន្នន័យ ធ្វើរំលស់អត្រា ៥០% នៃមូលដ្ឋានរំលស់ តាមវិធីសាស្ត្រថយចុះជាលំដាប់។
- ទ្រព្យថ្នាក់ទី៣ មាន រថយន្ត រថយន្តដឹកទំនិញ គ្រឿងសង្ហារឹម និងបរិក្ខារការិយាល័យ ធ្វើរំលស់អត្រា ២៥%នៃមូលដ្ឋានរំលស់ តាមវិធីសាស្ត្រថយចុះជាលំដាប់។
- ទ្រព្យថ្នាក់ទី៤ រាល់គ្រប់ប្រភេទនៃទ្រព្យសកម្មរូបីផ្សេងៗទៀត ធ្វើរំលស់អត្រា២០%នៃមូលដ្ឋានរំលស់ តាមវិធីសាស្ត្រថយចុះជាលំដាប់។

➢ **មូលដ្ឋានរំលស់**

មូលដ្ឋានរំលស់=ទឹកប្រាក់មិនទាន់រំលស់ដើមឆ្នាំ + ទឹកប្រាក់បន្ថែមក្នុងឆ្នាំ-ទឹកប្រាក់បានដកចេញក្នុងឆ្នាំ)

❖ **ទំព័រលេខ១៥៖** បង្ហាញអំពីតារាងលើស ឬខ្វះពីការលក់ ឬការដកចេញនូវទ្រព្យសកម្មរយៈពេលវែងតាមច្បាប់សារពើពន្ធ ដែលតារាងនេះធ្វើការសម្រាយទៅលើ (ឧបសម្ព័ន្ធទី១)៖

- ថ្ងៃ ខែ ឆ្នាំ ទិញ
- ថ្ងៃ ខែ ឆ្នាំ លក់
- ប្រភេទនៃទ្រព្យសកម្មរយៈពេលវែង
- ឈ្មោះនៃទ្រព្យសកម្មរយៈពេលវែង
- ថ្លៃដើមប្រវត្តិសាស្ត្រ (1)
- រំលស់បូកយោង (2)
- តម្លៃនៅសល់ (3)
- ផលពីការលក់ (4)
- តម្លៃលើស ឬខ្វះ (5) = (4)-(3)

## ៣.២ ដំណើរការនៃការប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំសម្រាប់ក្រុមហ៊ុនសេវាកម្ម

- **ជំហានទី១**

ត្រូវប្រមូលឯកសារដែលពាក់ពន្ធ័ទាំងអស់មានដូចជា៖ ឯកសារចំណូល-ចំណាយទាំង១២ខែ ពោលគឺចាប់ពីខែមករា ដល់ខែធ្នូ នៅក្នុងឆ្នាំដែលត្រូវធ្វើការប្រកាស និងឯកសារដែលពាក់ព័ន្ធដូចជា ពន្ធរំដោះលើប្រាក់ចំណូល ពន្ធលើប្រាក់បៀវត្ស ពន្ធកាត់ទុក និង ពន្ធអាករលើតម្លៃបន្ថែម ទាំង១២ខែ ដើម្បីយកមកតំលើងរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់ប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ។

- **ជំហានទី២**

បន្ទាប់ពីមានឯកសារគ្រប់គ្រាន់ហើយ ត្រូវរៀបចំប្លង់គណនេយ្យ (Chart of Account) ហើយយកចំណូល និងចំណាយ ទាំងអស់មកបញ្ចូលទៅក្នុងតារាង ដោយដាក់ចំណូល និងចំណាយ ដាច់ដោយឡែកដើម្បីងាយស្រួលក្នុងការគណនា។ ជំហានបន្ទាប់ ត្រូវបង្កើតតារាងថ្មីមួយផ្សេងទៀត សម្រាប់ចំណូល និងមួយទៀតសម្រាប់ចំណាយ ទុកធ្វើការបញ្ចូលទិន្នន័យសរុបរបស់ចំណូល និង ចំណាយ ទៅតាមប្រភេទរបស់វា។ ឧទាហរណ៍ ចំណាយជួសជុល បានធ្វើឡើង៣ដង ក្នុងខែមករា នោះត្រូវសរុបចំណាយទាំង៣ដងនោះបញ្ចូលគ្នា និងចងកូដB25។

ការធ្វើបែបនេះ ជាការសម្រួលដល់ការចាប់កូដ សម្រាប់យកទៅបំពេញនៅក្នុងលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ។ កូដ ដែលលើកយកមកនិយាយនៅទីនេះ គឺជាអក្សរតំណាងនីមួយៗដែលបានធ្វើការបកស្រាយនៅក្នុងចំណុច៣.១ ខាងលើ។

- **ជំហានទី៣**

មកដល់ចំណុចនេះ យើងគួរតែមានតារាង ដែលបានធ្វើការបូកបញ្ចូលនូវចំណូល និង ចំណាយ ទៅតាមប្រភេទ ទាំង១២ខែ ដែលបានបង្កើត និងគណនា និង បានធ្វើការចាប់កូដទៅតាមប្រភេទនៃចំណូល និងចំណាយនោះរួចរាល់ហើយនៅក្នុងជំហានទី២។ តទៅនេះ ត្រូវបង្កើតតារាង ថ្មីមួយទៀត ដែលតារាងនេះ ធ្វើការសរសេរកូដពីAដល់D ដូចមានក្នុងលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ និង បូកសរុបទាំង១២ខែតាមកូដនីមួយៗដូចក្នុងតារាងទី២០ខាងក្រោម៖

**តារាងទី១៥៖ បូកសរុបកូដនីមួយៗទាំង១២ខែ**

| Code | JAN | FEB | MAR. | APR | MAY | … | DEC | TOTAL |
|---|---|---|---|---|---|---|---|---|
| A1 | | | | | | | | ៛ |
| A2 | | | | | | | | ៛ |
| A3 | | | | | | | | ៛ |
| A4 | | | | | | | | ៛ |
| … | | | | | | | | ៛ |
| D6 | | | | | | | | ៛ |
| D7 | | | | | | | | ៛ |
| D9 | | | | | | | | ៛ |

ទិន្នន័យដែលយកមកបំពេញតាមកូដ និងតាមខែនីមួយៗនៅក្នុងតារាងលើនេះ ត្រូវយកចេញពីតារាងដែលបានបូកបញ្ចូល ចំណូល និង ចំណាយទៅតាមប្រភេទរបស់វា នឹងដាក់កូដតំណាង ដូចនឹងឧទាហរណ៍នៅជំហានទី២ខាងលើនោះ។ ចំណាយជួសជុលដែលបានសរុបក្នុងខែមករានោះ ត្រូវយកមកបញ្ចូលក្នុងB25 របស់ខែមករា។

- **ជំហានទី៤**

បន្ទាប់ពីបំពេញ និង គណនាក្នុងតារាងទី៤ រួចរាល់ហើយ យកទិន្នន័យដែលគណនាឃើញក្នុងទឹកប្រាក់សរុបនោះ (TOTAL ) ទៅបំពេញចូលក្នុងទម្រង់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ។

## ៣.៣. របៀបគណនាពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ

**ករណីសិក្សា១៖** ABC Tourism Company គឺជាក្រុមហ៊ុនសេវាកម្មខាងផ្នែកទេសចរណ៍ នៅក្នុងប្រទេសកម្ពុជា ដែលបានចុះបញ្ជី ជាអ្នកជាប់ពន្ធមធ្យមក្នុងរបបស្វ័យប្រកាស។ ខាងក្រោមនេះ គឺជារបាយការណ៍លទ្ធផលនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩៖

ABC Tourism Campany

**របាយការណ៍ហិរញ្ញវត្ថុ**

**ថ្ងៃទី៣១ ធ្នូ ២០១៩**

| | | |
|---|---|---|
| **ចំណូល** | | |
| | ការផ្គត់ផ្គង់សេវា | $១៥០,៥០០ |
| | ចំណូលលើការប្រាក់ | $៧០០ |
| **ចំណាយ** | | |
| | ថ្លៃដើមសេវាបានផ្គត់ផ្គង់ | $៤០,០០០ |
| | ប្រេង ឧស្ម័ន អគ្គិសនី និងទឹក | $៩០០ |
| | ការជួលរថយន្ត | $២,៨០០ |
| | ការផ្សាយពាណិជ្ជកម្ម | $៦,៥០០ |
| | ប្រាក់បៀវត្សត្រូវទូទាត់អោយបុគ្គលិក ( សំគាល់១) | $២២,០០០ |
| | ខាតពីការលក់ទ្រព្យសកម្មរយៈពេលវែង | $១៥,០០០ |
| | អំណោយ (សំគាល់២) | $២,២០០ |
| | ចំណាយព្យាបាលជំងឺអោយបុគ្គលិក (សំគាល់៣) | $១,៥៥០ |
| | វិលស់គណនេយ្យ | ២២,៦២៥ |
| | ចំណាយលើការប្រាក់ | $៩០០ |
| | ចំណាយទោសទណ្ឌ និងពិន័យផ្សេងៗ | $៤៥០ |
| | ចំណាយផ្សេងៗ | $១,០០០ |
| | **ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល** | **$៣៥,២៧៥** |

**កំណត់សំគាល់៖**

- សំគាល់១- ប្រាក់បៀវត្សនេះនឹងទូទាត់អោយបុគ្គលិកនៅពាក់កណ្តាលខែមីនា ឆ្នាំ២០២០។
- សំគាល់២- ក្រុមហ៊ុនបានផ្តល់អំណោយទៅកាកបាទក្រហមកម្ពុជាចំនួន $១,៧០០ ឯទឹកប្រាក់នៅសល់ប៉ុន្មាន ក្រុមហ៊ុនបានផ្តល់ទៅកាន់មជ្ឈមណ្ឌលកុមារកំព្រាមួយកន្លែង
- សំគាល់៣-នៅក្នុងឆ្នាំ២០១៩នេះ បុគ្គលិកម្នាក់របស់ក្រុមហ៊ុននេះជួបគ្រោះថ្នាក់ចរាចរណ៍ ដែលក្រុមហ៊ុនបានចេញនូវថ្លៃព្យាបាលជំងឺ ប៉ុន្តែក្រុមហ៊ុនមិនបានបង់ពន្ធលើអត្ថប្រយោជន៍បន្ថែមឡើយ ដោយសារតែក្នុងការចេញថ្លៃជំងឺនេះ គ្មានក្នុងគោលការណ៍ច្បាប់ការងាររបស់ក្រុមហ៊ុនឡើយ
- នៅក្នុងឆ្នាំ២០១៧ និង ២០១៨ ABC Tourism Company មានការខាតសារពើពន្ធ ចំនួន $១០,000 នៅក្នុងឆ្នាំនីមួយៗ នោះក្រុមហ៊ុនបានការយោងខាតទាំងពីរឆ្នាំនោះមកកាត់កងក្នុងឆ្នាំ ២០១៩នេះ
- ក្រុមហ៊ុនបានទទួលអំណោយពីរដ្ឋចំនួន $១,៥០០ ហើយមិនបានទទួលស្គាល់ក្នុងបញ្ជីគណនេយ្យនោះទេ
- ខាតពីការលក់ទ្រព្យសកម្មរយៈពេលវែងតាមច្បាប់ពន្ធ $១២,000
- មានប្រាក់រំដោះពន្ធលើប្រាក់ចំណូល ចំនួន $២,៩៥០ និងគ្មានឥណទានពន្ធលើប្រាក់ចំណូលយោងពីឆ្នាំមុនឡើយ។ ចំនួន$២.៩៥០ នេះ ត្រូវបានបូកបញ្ចូលចំនួន$១,៤៤៥ ទៀត ដោយសារតែក្រុមហ៊ុនបានយោងពីឆ្នាំមុនៗ និងបានធ្វើការបង់ពន្ធលើស។
- តារាងខាងក្រោមនោះគឺជាព័ត៌មានអំពីទ្រព្យសកម្មដែលបានធ្វើរំលស់៖

| **ទ្រព្យសកម្ម** | **បរិយាទានប្រវត្តិសាស្ត្រ** |
|---|---|
| អាគារ | $៣00,000 |
| កុំព្យូទ័រ | $៥,000 |
| រថយន្ត និង គ្រឿងបរិក្ខារការិយាល័យផ្សេងទៀត | $៧0,000 |

- នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ក្រុមហ៊ុននេះបានទទួលនូវលិខិតបញ្ជាក់ពីរដ្ឋបាលសារពើពន្ធ ថាបានកាន់បញ្ជីគណនេយ្យត្រឹមត្រូវ

**ចូរគណនាពន្ធលើប្រាក់ចំណូលដែលក្រុមហ៊ុននោះត្រូវបង់។**

## ដំណោះស្រាយករណីសិក្សា១៖ គណនាពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ២០១៩

នៅក្នុងគោលដៅពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ចំណូល និងចំណាយដែលយកមកធ្វើការគណនាលទ្ធផលគណនេយ្យមុនបង់ពន្ធ គឺជាតម្លៃដែលគិតរួមបញ្ចូលលើអាករទាំងអស់ លើកលែងតែអាករលើតម្លៃបន្ថែម។ យោងតាមប្រកាស លេខ០៩៨ សហវ.ប្រក ដែលចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ ស្តីពីពន្ធលើប្រាក់ចំណូល ប្រការ១៣ វិធានគណនេយ្យ ប្រាក់ចំណូលសុទ្ធ ឬខាត គឺជាសមតុល្យនៃគណនីលទ្ធផលនៃការិយបរិច្ឆេទ ប៉ុន្តែដោយសារបទប្បញ្ញត្តិស្តីពីពន្ធដារបានកំណត់ដោយឡែក ដូចនេះត្រូវមានការកែតម្រូវក្រៅគណនេយ្យដោយមានការបញ្ចូលមកវិញ ឬកាត់ចេញនូវចំណូលនិងចំណាយ ស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងប្រការ៥១នៃប្រកាសនេះ។ នៅក្នុងករណីសិក្សាទី១ លទ្ធផលគណនេយ្យមុនបង់ពន្ធ ត្រូវយកមកធ្វើការកែតម្រូវ ដោយបញ្ចូល និងដកនូវចំណូល/ចំណាយផ្សេងៗ ដោយផ្អែកលើចំណុចដូចខាងក្រោម៖

យោងតាមប្រកាសស្តីពីពន្ធលើប្រាក់ចំណូល លេខ០៩៨ សហវ.ប្រក. ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ ២០២០៖

- ប្រការ២៣ នៃជំពូកទី៤ កថាខណ្ឌទី៤ បានចែងថា អំណោយផ្សេងៗនិងឧបត្ថម្ភកធនទោះបានមកពីប្រភពណាក៏ដោយ ត្រូវគិតបញ្ចូលក្នុងចំណូលជាប់ពន្ធនៃការិយបរិច្ឆេទដែលបានទទួល។
- ប្រការ៣០ នៃជំពូកទី៦ កថាខណ្ឌ៣ ចែងថា សហគ្រាសមិនអាចកាត់កងបានទេនូវប្រាក់រំដោះពន្ធលើប្រាក់ចំណូល ពន្ធលើប្រាក់ចំណូល និងពន្ធអប្បបរមា និងពន្ធអាករនានាដែលមិនមែនជាបន្ទុករបស់សហគ្រាស ប៉ុន្តែគឺជាបន្ទុករបស់អ្នកទទួលចំណូលដែលត្រូវជាប់ពន្ធ។
- ប្រការ៣២ នៃជំពូកទី៦ កថាខណ្ឌទី៣ កំហិតលើការកាត់កងការប្រាក់សម្រាប់ឆ្នាំជាប់ពន្ធណាមួយគឺជាចំនួនទឹកប្រាក់ការប្រាក់អតិបរមាដែលត្រូវបានអនុញ្ញាតឱ្យកាត់កងនៅក្នុងឆ្នាំជាប់ពន្ធនោះ និងត្រូវគណនាតាមរូបមន្ត ក+ខ ដែល កជាចំណូលការប្រាក់ដែលទទួល ឬត្រូវទទួលនៅក្នុងឆ្នាំជាប់ពន្ធ និង ខ ជា៥០%នៃប្រាក់ចំណូលសុទ្ធដោយមិនគិតពីចំណូលការប្រាក់ និងចំណាយការប្រាក់។ ចំណាយការប្រាក់ដែលមិនត្រូវបានអនុញ្ញាតឱ្យកាត់កងក្នុងឆ្នាំជាប់ពន្ធចរន្ត អាចយោងជាចំណាយការប្រាក់សម្រាប់ឆ្នាំជាប់ពន្ធបន្តបន្ទាប់ទៀតនៅក្នុងកំហិតដូចគ្នារហូតដល់ឆ្នាំជាប់ពន្ធទី៥ ដោយគិតតាមលំដាប់ឆ្នាំដែលការប្រាក់បានកើតឡើង។
- ប្រការ៣៣ នៃជំពូកទី៦ កថាខណ្ឌទី៣ បានចែងថា អំណាយដែលសហគ្រាសបានធ្វើឡើង ជាចំណាយមិនអាចកាត់កងបាន។ ក្នុងកថាខណ្ឌទី១ បានចែងថា ទោសទណ្ឌនានា ដែលសហគ្រាសទទួលរង មិនត្រូវបានអនុញ្ញាតឱ្យកាត់កងទេ។

- ប្រការ៣៤នៃជំពូក៧ កថាខណ្ឌទី៣ បានចែងថាសម្រាប់គោលដៅនៃពបច រំលស់ដែលអាចកាត់កង បានត្រូវបំពេញលក្ខខណ្ឌទាំង ៥ ហើយក្នុងវាក្យខណ្ឌ ឃ រំលស់ត្រូវគណនាតាមវិធីដូចមានចែងក្នុង ប្រការ៣៥ ដល់ ៣៩នៃប្រកាសនេះ។ រំលស់គណនេយ្យ មិនត្រូវជាមួយនឹងវាក្យខណ្ឌនេះទេ ដូច្នេះ ហើយរំលស់គណនេយ្យមិនអាចកត់កងបានឡើយ។
- ប្រការ៥១ ស្តីអំពី ការបញ្ចូលមកវិញ និងការកាត់កងចេញផ្សេងៗ ទៅលើចំណាយរំលស់គណនេយ្យ ខាតពីការលក់ទ្រព្យសកម្មរយៈពេលវែងតាមបញ្ជីគណនេយ្យ អំណោយនិង ឧបត្ថម្ភកធនផ្សេងៗ រំលស់អនុញ្ញាតតាមច្បាប់សារពើពន្ធ។វិភាគទានសប្បុរសធម៌ សំដៅដល់វិភាគទាន ឱ្យដល់ សកម្មភាពមិនស្វែងរកប្រាក់ចំណេញដូចមានចែងក្នុងកថាខណ្ឌទិ២ នៃប្រការ៨ នៃប្រកាសនេះ ហើយមិនអោយលើសពី៥%នៃប្រាក់ចំណូលមិនពេលកាត់កងវិភាគទានសប្បុរសធម៌។
- ប្រការ៥៥ នៃជំពូក១០ កថាខណ្ឌទី១ វាក្យខណ្ឌ ក បានចែងថា ការកើតបង់កើតឡើងក្នុងឆ្នាំជាប់ពន្ធ ណាមួយ ត្រូវបានចាត់ជាបន្ទុក និងត្រូវបានអនុញ្ញាតឱ្យកាត់ចេញពីប្រាក់ចំណូលសម្រេចបាននៅ ក្នុងឆ្នាំជាប់ពន្ធបន្ទាប់ (ឆ្នាំជាប់ពន្ធទី១ នៃការយោងការខាតបង់)។ ប្រសិនបើប្រាក់ចំណូលនេះមិន គ្រប់គ្រាន់សម្រាប់ការទូទាត់ជាស្ថាពរទេ ចំណែកនៃការខាតបង់ដែលនៅសេសសល់ត្រូវយោងទៅឆ្នាំ ជាប់ពន្ធបន្តបន្ទាប់រហូតដល់ឆ្នាំជាប់ពន្ធទី៥។

យោងតាមប្រកាសស្តីពីពន្ធលើប្រាក់ចំណេញដែល សម្រេចដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ ១០៥៩ សហវ.ប្រក.ពជ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៣៖

- ផ្នែកទី១.៦ នៃជំពូកទី១ ក្នុងកថាខណ្ឌទី១ បានចែងថា ប្រាក់ចំណូលដែលជាប់ពន្ធលើប្រាក់បៀវត្ស ឬជាប់ពន្ធលើអត្ថប្រយោជន៍បន្ថែម មិនត្រូវជាប់ពន្ធលើប្រាក់ចំណេញទេ(ឧបសម្ព័ន្ធ៣)
- ផ្នែកទី៥.២ នៃជំពូកទី៥ ក្នុងកថាខណ្ឌទី២ វាក្យខណ្ឌ គ១ សហគ្រាសអាចកាត់កងនូវចំណាយដែល មិនទាន់បានទូទាត់នៅដំណាច់ឆ្នាំសារពើពន្ធ វៀរលែងតែប្រាក់បៀវត្សពីការបំពើការងារដែលមិនទាន់ បានបើក ប៉ុន្តែមិនបានបើកក្នុងអំឡុងពេល៦០ថ្ងៃនៃឆ្នាំសារពើពន្ធបន្ទាប់។

(របៀបគណនានៅទំព័របន្ទាប់)

| | | | |
|---|---|---|---|
| **លទ្ធផលគណនេយ្យមុនបង់ពន្ធ** | | | **$៣៥,២៧៥** |
| បូក | វិលស់គណនេយ្យ | $២២,៦២៥ | |
| | ប្រាក់បៀវត្សត្រូវទូទាត់ | $២២,០០០ | |
| | អំណោយ | $៥០០ | |
| | ខាតពីការលក់ទ្រព្យសកម្មរយៈពេលវែងតាមគណនេយ្យ | $១៥,០០០ | |
| | ចំណាយលើទោសទណ្ឌ | $៤៥០ | |
| | ទទួលអំណោយ | $១,៥០០ | |
| | ចំណាយព្យាបាលជំងឺ | $១,៥៥០ | |
| | **សរុប** | | **$៦៣,៦២៥** |
| ដក | រំលស់តាមច្បាប់ពន្ធ (របៀបគណនា១) | ($៣៥,០០០) | |
| | ខាតពីការលក់ទ្រព្យសកម្មតាមច្បាប់ពន្ធ | ($១២,០០០) | |
| | **សរុប** | | **($៤៧,០០០)** |
| | **ប្រាក់ចំណេញក្រោយនិយ័តកម្ម** | | **$៥១,៩០០** |
| បូក | ចំណាយវិភាគទានសប្បុរសធម៌ (របៀបគណនា២) | $0 | |
| | **ប្រាក់ចំណេញមុននិយ័តកម្មការប្រាក់** | | **$៥១,៩០០** |
| បូក/ដក | និយ័តកម្មការប្រាក់ (របៀបគណនា៣) | $0 | |
| | **ប្រាក់ចំណេញក្នុងការិយបរិច្ឆេទ** | | **$៥១,៩០០** |
| ដក | ខាតយោងពីឆ្នាំមុនអនុញ្ញាត | ($២០,០០០) | |
| | **ប្រាក់ចំណូលជាប់ពន្ធសម្រាប់គណនាពន្ធលើប្រាក់ចំណូល** | | **$៣១,៩០០** |
| | ពន្ធលើប្រាក់ចំណូល ២០% | $៦,៣៨០ | |
| | **បំណុលពន្ធលើប្រាក់ចំណូល** | | **$៦,៣៨០** |
| ដក | ប្រាក់រំដោះពន្ធលើប្រាក់ចំណូល | ($២,៩៥០) | |
| | **ពន្ធលើប្រាក់ចំណូលត្រូវបង់** | | **$៣,៤៣០** |

## របៀបគណនា១៖ រំលស់សារពើពន្ធ

| ល.រ | ប្រភេទទ្រព្យសកម្ម | ថ្លៃដើមប្រវត្តិសាស្ត្រនៅដើមគ្រា | លទ្ធកម្មបង្វែរចូលឬដាក់បន្ថែមក្នុងការិយ. | ថ្លៃដើមទ្រព្យដកចេញ ឬលក់ក្នុងការិយ. | តម្លៃមូលដ្ឋានគិតរំលស់ក្នុងការិយ. | អត្រារំលស់ | រំលស់សម្រាប់ការិយ. | តម្លៃរំលស់បូកយោងពីការិយ.មុន | រំលស់បូកយោងទ្រព្យដែលបានលក់- | តម្លៃរំលស់បូកយោងនៅចុងការិយ. | តម្លៃនៅសល់មិនទាន់រំលស់នៅចុងការិយ. |
|---|---|---|---|---|---|---|---|---|---|---|---|
| | | 1 | 2 | 3 | 4=1+2-3 | 5 | 6=4*5 | 7 | 8 | 9=6+7-8 | 10=4-9 |
| II | រំលស់ទ្រព្យរូបីថ្នាក់ទី១ (រំលស់តាមវិធីសាស្ត្រស្មើភាគ) | | | | | | | | | | |
| | សំណង់ និងរចនាសម្ព័ន្ធ | $៣00,000 | | | $៣00,000 | ៥% | $១៥,000 | | | $១៥,000 | $២៨៥,000 |

| III | រំលស់ទ្រព្យរូបីថ្នាក់២ ដល់ថ្នាក់៤ (រំលស់តាមវិធីសាស្ត្រថយជាលំដាប់) | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ល.រ | ប្រភេទទ្រព្យសកម្មរយៈពេលវែង | ថ្លៃដើមប្រវត្តិសាស្ត្រ | តម្លៃនៅសល់មិនទាន់រំលស់នៅដើមការិយ. | លទ្ធកម្មបង្វែរចូល បង្កើត ឬ ដាក់បន្ថែមក្នុងការិយ. | ការដកចេញ-លក់ក្នុងការិយ. | តម្លៃមូលដ្ឋានគិតរំលស់ក្នុងការិយ. | អត្រារំលស់ | ទឹកប្រាក់រំលស់សម្រាប់ការិយ. | តម្លៃនៅសល់មិនទាន់រំលស់នៅចុងការិយ. |
| | | 1 | 2 | 3 | 4 | 5 | 6 | 7=5*6 | 8=5-7 |
| | ទ្រព្យសកម្មថ្នាក់២ | $៥,000 | $៥,000 | | | $៥,000 | ៥0% | $២,៥00 | $២,៥00 |
| | ទ្រព្យសកម្មថ្នាក់៣ | $៧0,000 | $៧0,000 | | | $៧0,000 | ២៥% | $១៧,៥00 | $៥២,៥00 |
| | ទ្រព្យសកម្មថ្នាក់៤ | | | | | | | | |
| សរុបថ្នាក់២ ដល់៤ | | $៧៥,000 | $៧៥,000 | | | $៧៥,000 | | $២0,000 | $៥៥,000 |
| សរុបរួម | | $៣៧៥,000 | $៣៧៥,000 | | | $៣៧៥,000 | | $៣៥,000 | $៣៤0,000 |

## របៀបគណនា២៖ ការគណនាវិភាគទានសប្បុរសធម៌

| បរិយាយ | យោង | ចំនួនទឹកប្រាក់ |
|---|---|---|
| **ប្រាក់ចំណេញក្រោយនិយ័តកម្ម F1** | **F1** | **$៥១,៩០០** |
| ចំណាយសប្បុរសធម៌ F2 | F2 | $១,៧០០ |
| ប្រាក់ចំណូលសម្រាប់គណនាចំណាយសប្បុរសធម៌អតិបរមាអាចកាត់កងបាន F3=F1+F2 | F3 | $៥៣,៦០០ |
| ចំណាយសប្បុរសធម៌អតិបរមាអាចកាត់កងបាន F4 = F3 * ៥% | F4 | $២,៦៨០ |
| ចំណាយសប្បុរសធម៌អាចកាត់កងបានក្នុងឆ្នាំ F5 (F4 ឬF2មួយណាតិចជាង) | F5 | $១,៧០០ |
| **ចំណាយសប្បុរសធម៌មិនអាចកាត់កងបាន F6=F2-F5** | **F6** | **$0** |

## របៀបគណនា៣៖ ការគណនាចំណាយការប្រាក់

| | | |
|---|---|---|
| **ប្រាក់ចំណេញមុននិយ័តកម្មការប្រាក់ G1** | | $៥១,៩០០ |
| បូក | ចំណាយការប្រាក់ក្នុងការិយបរិច្ឆេទ G2 | $៩០០ |
| ដក | ចំណូលការប្រាក់ក្នុងការិយបរិច្ឆេទ G3 | ($៧០០) |
| | ប្រាក់ចំណេញសុទ្ធមុនការប្រាក់ G4 = G1+ G2 – G3 | $៥២,១០០ |
| | ៥០% នៃប្រាក់ចំណេញគ្មានការប្រាក់ G5 = G4 * ៥០% | $២៦,០៥០ |
| បូក | ចំណូលការប្រាក់ក្នុងការិយបរិច្ឆេទ G6 = G3 | $៧០០ |
| | ចំណាយការប្រាក់អតិបរមាអនុញ្ញាតឲ្យកាត់កងក្នុងការិយបរិច្ឆេទ G7=G5+G6 | $២៦,៧៥០ |
| | ចំណាយការប្រាក់យោងពីឆ្នាំមុន G8 | $0 |
| | សរុបចំណាយការប្រាក់ក្នុងការិយបរិច្ឆេទនិងយោងពីឆ្នាំមុនG9 =G2+G8 | $៩០០ |
| | សរុបចំណាយការប្រាក់អាចកាត់កងបាន G10 = G7 ឬ G9 (មួយណាតិចជាង) | $៩០០ |
| | **ចំនួនទឹកប្រាក់ត្រូវបូក/ដកពីប្រាក់ចំណូលជាប់ពន្ធG11=G10–G2** | **$0** |

**ករណីសិក្សា២៖** Penguin Food Delivery ជាសហគ្រាសនីតិបុគ្គលនៅកម្ពុជា ដែលបានចុះបញ្ជី ជាអ្នកប្រកាសពន្ធតាមរបបស្វ័យប្រកាស ចំណាត់ថ្នាក់អ្នកជាប់ពន្ធមធ្យម ហើយ_មានទទួលបម្រើសេវាដឹកជញ្ជូនម្ហូបអាហារដែលអតិថិជនកម្ម៉ង់ពីហាងផ្សេងៗទៅដល់ទីតាំងដែលអតិថិជនចង់បាន។ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៩ លទ្ធផលគណនេយ្យមានចំនួន $៤៥,៥០០ (លទ្ធផលមុនដកប្រាក់រំដោះពន្ធលើប្រាក់ចំណេញ)។ លទ្ធផលដែលទទួលបាននេះ គឺបន្ទាប់ពីធ្វើការគណនានូវចំណុចខាងក្រោម៖

| | |
|---|---|
| ចំណាយការប្រាក់ | $៩៥០ |
| ចំណាយព្យាបាលរបួសបុគ្គលិក | $៣,៩៩០ |
| រំលស់គណនេយ្យ | $១៥,៥០៥ |
| ការកំសាន្តសប្បាយ | $១,២០០ |
| សេវាដឹកជញ្ជូនឥតគិតថ្លៃដល់អតិថិជន | $៣៥០ |
| ប្រាក់លើកទឹកចិត្តបង្គរដល់បុគ្គលិកដែលនឹងត្រូវបើកនៅចុងខែមីនា | $២,៦៥០ |
| ធ្វើអំណោយទៅកាន់សាលានៅតំបន់ដាច់ស្រយាលមួយកន្លែង | $១,០០០ |
| ចំណាយពិន័យផ្សេងៗ | $១៥០ |
| អាករលើធាតុចូលមិនអាចសុំជាឥណទានបាន | $៤៣០ |
| ចំណូលការប្រាក់ | $៦៩៥ |

**សម្គាល់៖**

- ក្រុមហ៊ុនបានយោងចំណាយការប្រាក់ពីការិយបរិច្ឆេទឆ្នាំ២០១៧ មានចំនួន$១,០៩០ និង បានយោងការខាតពីឆ្នាំ២០១៨ ចំនួន $២,០០០
- នៅក្នុងឆ្នាំ ២០១៨ សំវិធានធនរបស់ក្រុមហ៊ុនមានចំនួន $៩៩០ ប៉ុន្តែមកដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៩ នេះ សំវិធានធនបានធ្លាក់ចុះដល់ $៤៦៥
- ក្រុមហ៊ុនមានចំណាយការប្រាក់យោងពីឆ្នាំមុនចំនួន $៥៥០
- ក្រុមហ៊ុនបានទទួលអំណោយពីលោកឧកញ៉ា A ចំនួន $២,៥០០ ដែលជាចំនួនមិនបានទទួលស្គាល់ក្នុងគណនេយ្យ
- ពន្ធអប្បបរមា មានចំនួន $៤៥៥ និងប្រាក់រំដោះពន្ធលើប្រាក់ចំណូលចំនួន $១,៥០០ និងមានឥណទានពន្ធកាត់ទុក ចំនួន $២០០

- នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ អតិថិជនមួយចំនួនបានធ្វើការកក់លុយនៅ ក្រុមហ៊ុន Penguin Food Delivery នេះចំនួន ៥០% នៃ ថ្លៃដឹកជញ្ជូន ស្មើនឹងទឹកប្រាក់ $៣០០ សម្រាប់ធ្វើការដឹកជញ្ជូនម្ហូបពីហាងមួយកន្លែង ដែលការកម្ម៉ង់នេះ នឹងត្រូវបានដឹកជញ្ជូននៅថ្ងៃបន្ទាប់ដែលត្រូវជាថ្ងៃទី០១ ខែមករា ឆ្នាំ២០២០ និងធ្វើការទូទាត់នូវ៥០%ទៀតនៃថ្ងៃទទួលម្ហូបកម្ម៉ង់នោះ
- នៅក្នុងឆ្នាំ២០១៩នេះ មានបុគ្គលិកម្នាក់ជួបគ្រោះថ្នាក់ចរាចរណ៍ដែលបណ្តាលអោយរងរបួសធ្ងន់ និងមានការខូចខាតនូវរថយន្តមួយគ្រឿង។ ក្រុមហ៊ុនបានចេញនូវថ្លៃព្យាបាលរបួសនោះអស់ $៣,៩៩០ ដែលចំនួននោះត្រូវបានយកពន្ធលើអត្ថប្រយោជន៍បន្ថែម។ ចំណែកឯរថយន្តវិញ ក្រុមហ៊ុនបានខាតពីការលក់ចំណែកនោះអស់ចំនួន $៣០០។
- ព័ត៌មានអំពីទ្រព្យសកម្មដែលត្រូវធ្វើរំលស់៖

| ទ្រព្យសកម្ម | បរិយាទានប្រវត្តសាស្ត្រ |
|---|---|
| អាគារ | $២៥០,៥០០ |
| កុំព្យូទ័រនិងបរិក្ខារទុកដាក់ទិន្នន័យ | $៤,០០០ |
| រថយន្ត និងបរិក្ខារការិយាល័យ | $២០,០០០ |
| ទ្រព្យសកម្មផ្សេងៗ | $៣,០០០ |

**ចូរគណនាពន្ធលើប្រាក់ចំណូលរបស់ក្រុមហ៊ុន Penguin Food Delivery ត្រូវបង់ក្នុងឆ្នាំ២០១៩នេះ។**

**ដំណោះស្រាយករណីសិក្សាទី២៖ គណនាពន្ធលើប្រាក់ចំណូលឆ្នាំ២០១៩**

នៅក្នុងគោលដៅពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ចំណូល និងចំណាយដែលយកមកធ្វើការគណនាលទ្ធផលគណនេយ្យមុនបង់ពន្ធ គឺជាតម្លៃដែលគិតរួមបញ្ចូលលើអាករទាំងអស់ លើកលែងតែអាករលើតម្លៃបន្ថែម។ យោងតាមប្រកាស លេខ០៩៨ សហវ.ប្រក ដែលចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ ស្តីពីពន្ធលើប្រាក់ចំណូល ប្រការ១៣ វិធានគណនេយ្យ ប្រាក់ចំណូលសុទ្ធ ឬខាត គឺជាសមតុល្យនៃគណនីលទ្ធផលនៃការិយបរិច្ឆេទ ប៉ុន្តែដោយសារបទប្បញ្ញត្តិស្តីពីពន្ធដារបានកំណត់ដោយឡែក ដូចនេះត្រូវមានការកែតម្រូវក្រៅគណនេយ្យដោយមានការបញ្ចូលមកវិញ ឬកាត់ចេញនូវចំណូលនិងចំណាយ ស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងប្រការ៥១នៃប្រកាសនេះ។ នៅក្នុងករណីសិក្សាទី២ លទ្ធផលគណនេយ្យមុនបង់ពន្ធ ត្រូវយកមកធ្វើការកែតម្រូវ ដោយបញ្ចូល និងដកនូវចំណូល/ចំណាយផ្សេងៗ ដោយផ្អែកលើចំណុចដូចខាងក្រោម៖

យោងតាមប្រកាសស្តីពីពន្ធលើប្រាក់ចំណូល លេខ០៩៨ សហវ.ប្រក. ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ ២០២០៖

- ប្រការ២០ នៃជំពូកទី៤ វាក្យខណ្ឌ ឃ បានចែងថា ប្រាក់កក់ដែលអ្នកទិញបានបង់ជាមុន នាពេលបញ្ជាទិញទំនិញ ឬសេវា ដែលជាចំណែកមួយនៃថ្លៃទិញទំនិញ ឬសេវា ហើយអ្នកផ្គត់ផ្គង់ត្រូវកត់ត្រាប្រាក់កក់នេះជាចំណូលនាថ្ងៃទទួលប្រាក់។
- ប្រការ២៣ នៃជំពូកទី៤ កថាខណ្ឌទី៤ បានចែងថា អំណោយផ្សេងៗនិងឧបត្ថម្ភកធនទោះបានមកពីប្រភពណាក៏ដោយ ត្រូវគិតបញ្ចូលក្នុងចំណូលជាប់ពន្ធនៃការិយបរិច្ឆេទដែលបានទទួល។
- ប្រការ៣០ នៃជំពូកទី៦ កថាខណ្ឌ៣ ចែងថា សហគ្រាសមិនអាចកាត់កងបានទេនូវប្រាក់រំដោះពន្ធលើប្រាក់ចំណូល ពន្ធលើប្រាក់ចំណូល និងពន្ធអប្បបរមា និងពន្ធអាករនានាដែលមិនមែនជាបន្ទុករបស់សហគ្រាស ប៉ុន្តែគឺជាបន្ទុករបស់អ្នកទទួលចំណូលដែលត្រូវជាប់ពន្ធ។
- ប្រការ៣២ នៃជំពូកទី៦ កថាខណ្ឌទី៣ កំហិតលើការកាត់កងការប្រាក់សម្រាប់ឆ្នាំជាប់ពន្ធណាមួយ គឺជាចំនួនទឹកប្រាក់ការប្រាក់អតិបរមាដែលត្រូវបានអនុញ្ញាតឱ្យកាត់កងនៅក្នុងឆ្នាំជាប់ពន្ធនោះ និងត្រូវគណនាតាមរូបមន្ត ក+ខ ដែល ក ជាចំណូលការប្រាក់ដែលទទួល ឬត្រូវទទួលនៅក្នុងឆ្នាំជាប់ពន្ធ និងខ ជា៥០%នៃប្រាក់ចំណូលសុទ្ធដោយមិនគិតពីចំណូលការប្រាក់ និងចំណាយការប្រាក់។ ចំណាយការប្រាក់ដែលមិនត្រូវបានអនុញ្ញាតឱ្យកាត់កងក្នុងឆ្នាំជាប់ពន្ធចរន្ត អាចយោងជាចំណាយការប្រាក់សម្រាប់ឆ្នាំជាប់ពន្ធបន្តបន្ទាប់ទៀតនៅក្នុងកំហិតដូចគ្នារហូតដល់ឆ្នាំជាប់ពន្ធទី៥ ដោយគិតតាមលំដាប់ឆ្នាំដែលការប្រាក់បានកើតឡើង។

- ប្រការ៣៣ នៃជំពូកទី៦ កថាខណ្ឌទី៣ បានចែងថា អំណោយដែលសហគ្រាសបានធ្វើឡើង ជាចំណាយមិនអាចកាត់កងបាន។ ក្នុងកថាខណ្ឌទី១ បានចែងថា ទោសទណ្ឌនានា ដែលសហគ្រាសទទួលរង មិនត្រូវបានអនុញ្ញាតឱ្យកាត់កងទេ។
- ប្រការ៣៤នៃជំពូក៧ កថាខណ្ឌទី៣ បានចែងថាសម្រាប់គោលដៅនៃពបច វិលស់ដែលអាចកាត់កងបានត្រូវបំពេញលក្ខខណ្ឌទាំង ៥ ហើយក្នុងវាក្យខណ្ឌ ឃ រំលស់ត្រូវគណនាតាមវិធីដូចមានចែងក្នុងប្រការ៣៥ ដល់ ៣៩នៃប្រកាសនេះ។ រំលស់គណនេយ្យ មិនត្រូវជាមួយនឹងវាក្យខណ្ឌនេះទេ ដូច្នេះហើយរំលស់គណនេយ្យមិនអាចកត់កងបានឡើយ។
- ប្រការ៥១ ស្តីអំពី ការបញ្ចូលមកវិញ និងការកាត់កងចេញផ្សេងៗ ទៅលើចំណាយរំលស់គណនេយ្យ ខាតពីការលក់ទ្រព្យសកម្មរយៈពេលវែងតាមបញ្ជីគណនេយ្យ អំណោយនិង ឧបត្ថម្ភកធនផ្សេងៗ រំលស់អនុញ្ញាតតាមច្បាប់សារពើពន្ធ។
- ប្រការ៥៥ នៃជំពូក១០ កថាខណ្ឌទី១ វាក្យខណ្ឌ ក និង គ បានចែងថា ការកើតបង់កើតឡើងក្នុងឆ្នាំជាប់ពន្ធណាមួយ ត្រូវបានចាត់ជាបន្ទុក និងត្រូវបានអនុញ្ញាតឱ្យកាត់ចេញពីប្រាក់ចំណូលសម្រេចបាននៅក្នុងឆ្នាំជាប់ពន្ធបន្ទាប់ (ឆ្នាំជាប់ពន្ធទី១ នៃការយោងការខាតបង់)។ ប្រសិនបើប្រាក់ចំណូលនេះមិនគ្រប់គ្រាន់សម្រាប់ការទូទាត់ជាស្ថាពរទេ ចំណែកនៃការខាតបង់ដែលនៅសេសសល់ត្រូវយោងទៅឆ្នាំជាប់ពន្ធបន្តបន្ទាប់រហូតដល់ឆ្នាំជាប់ពន្ធទី៥។ នៅពេលណាដែលការខាតបង់មានលើសពីមួយឆ្នាំ ត្រូវអនុវត្តចំពោះការខាតបង់ទាំងឡាយតាមលំដាប់ថ្នាក់ដែលការខាតបង់បានកើតឡើង។

យោងតាមប្រកាសស្តីពីពន្ធលើប្រាក់ចំណេញដែល សម្រេចដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ ១០៥៩ សហវ.ប្រក.ពដ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៣៖

- ផ្នែកទី១.៦ នៃជំពូកទី១ ក្នុងកថាខណ្ឌទី១ បានចែងថា ប្រាក់ចំណូលដែលជាប់ពន្ធលើប្រាក់បៀវត្សឬជាប់ពន្ធលើអត្ថប្រយោជន៍បន្ថែម មិនត្រូវជាប់ពន្ធលើប្រាក់ចំណេញទេ(ឧបសម្ព័ន្ធ៣)
- ផ្នែកទី៥.២ នៃជំពូកទី៥ ក្នុងកថាខណ្ឌទី២ វាក្យខណ្ឌ គ១ សហគ្រាសអាចកាត់កងនូវចំណាយដែលមិនទាន់បានទូទាត់នៅដំណាច់ឆ្នាំសារពើពន្ធ វៀរលែងតែប្រាក់បៀវត្សពីការបំពេីការងារដែលមិនទាន់បានបើក ប៉ុន្តែមិនបានបើកក្នុងអំឡុងពេល៦០ថ្ងៃនៃឆ្នាំសារពើពន្ធបន្ទាប់។

| | | | |
|---|---|---|---|
| **លទ្ធផលគណនេយ្យមុនបង់ពន្ធ** | | | **$៨៥,៥០០** |
| **បូក** | វិលស់គណនេយ្យ | $១៥,៥០៥ | |
| | ការកំសាន្តសប្បាយ | $១,២០០ | |
| | សេវាដឹកជញ្ជូនឥតគិតថ្លៃសម្រាប់អតិថិជន | $៣៥០ | |
| | ចំណូលបានទទួលមុន | $៣០០ | |
| | ប្រាក់លើកទឹកចិត្តបង្គរដល់បុគ្គលិកត្រូវបើកនៅចុងខែមីនា | $២,៦៥០ | |
| | អំណោយ | $១,០០០ | |
| | ចំណាយពិន័យ និងទោសទណ្ឌផ្សេងៗ | $១៥០ | |
| | អំណោយដែលទទួលបាន | $២,៥០០ | |
| | **សរុប** | | **$២៣,៦៥៥** |
| **ដក** | វិលស់តាមច្បាប់ពន្ធ (របៀបគណនា១) | ($២០,០៥០) | |
| | ការថយចុះនៃសំវិធានធន | ($៥២៥) | |
| | **សរុប** | | **($២០,៥៧៥)** |
| | **ប្រាក់ចំណេញក្រោយនិយ័តកម្ម** | | $៨៨,៥៨០ |
| **ដក** | និយ័តកម្មការប្រាក់ (របៀបគណនា២) | ($៥៥០) | |
| | **ប្រាក់ចំណេញក្នុងការិយបរិច្ឆេទ** | | **$៨៨,០៣០** |
| **ដក** | ខាតយោងពីឆ្នាំមុន | ($៣,០៩០) | |
| | **ប្រាក់ចំណូលជាប់ពន្ធសម្រាប់គណនាពន្ធលើប្រាក់ចំណូល** | | **$៨៤,៩៤០** |
| | ពន្ធលើប្រាក់ចំណូល ២០% | $៨,៩៨៨ | |
| | ពន្ធអប្បបរមា | $៨៥៥ | |
| | **បំណុលពន្ធលើប្រាក់ចំណូលត្រូវបង់** | | **$៨,៩៨៨** |
| **ដក** | ឥណទានពន្ធកាត់ទុក | $២០០ | |
| | ប្រាក់រំដោះពន្ធលើប្រាក់ចំណូល | $១,៥០០ | |
| | **ពន្ធលើប្រាក់ចំណូលត្រូវបង់** | | **$៧,២៨៨** |

## របៀបគណនា១៖ រំលស់សារពើពន្ធ

| ល.រ | ប្រភេទទ្រព្យសកម្ម | ថ្លៃដើមប្រវត្តិសាស្ត្រនៅដើមគ្រា | លទ្ធកម្មបង្វែរចូល ឬដាក់បន្ថែមក្នុងការិយ. | ថ្លៃដើមទ្រព្យដកចេញ ឬលក់ក្នុងការិយ. | តម្លៃមូលដ្ឋានគិតរំលស់ក្នុងការិយ. | អត្រារំលស់ | រំលស់សម្រាប់ការិយ. | តម្លៃរំលស់បូកយោងពីការិយ.មុន | រំលស់បូកយោងទ្រព្យដែលបានលក់-ដកចេញ | តម្លៃរំលស់បូកយោងនៅចុងការិយ. | តម្លៃនៅសល់មិនទាន់រំលស់នៅចុងការិយ. |
|---|---|---|---|---|---|---|---|---|---|---|---|
| | | 1 | 2 | 3 | 4=1+2-3 | 5 | 6=4*5 | 7 | 8 | 9=6+7-8 | 10=4-9 |
| II | រំលស់ទ្រព្យរូបីថ្នាក់ទី១ (រំលស់តាមវិធីសាស្ត្រស្មើភាគ) | | | | | | | | | | |
| | សំណង់ និងរចនាសម្ព័ន្ធ | $២៥០,៥០០ | | | $២៥០,៥០០ | ៥% | $១២,៥២៥ | | | $១២,៥២៥ | $២៣៧,៩៧៥ |

| III | រំលស់ទ្រព្យរូបីថ្នាក់២ ដល់ថ្នាក់៤ (រំលស់តាមវិធីសាស្ត្រថយជាលំដាប់) | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ល.រ | ប្រភេទទ្រព្យសកម្មរយៈពេលវែង | ថ្លៃដើមប្រវត្តិសាស្ត្រ | តម្លៃនៅសល់មិនទាន់រំលស់នៅដើមការិយ. | លទ្ធកម្ម បង្វែរចូល បង្កើត ឬ ដាក់បន្លែំក្នុងការិយ | ការដកចេញ-លក់ក្នុងការិយ. | តម្លៃមូលដ្ឋានគិតរំលស់ក្នុងការិយ. | អត្រារំលស់ | ទឹកប្រាក់រំលស់សម្រាប់ការិយ. | តម្លៃនៅសល់មិនទាន់រំលស់នៅចុងការិយ. |
| | | 1 | 2 | 3 | 4 | 5 | 6 | 7=5*6 | 8=5-7 |
| | ទ្រព្យសកម្មថ្នាក់២ | $៤,000 | $៤,000 | | | $៤,000 | ៥0% | $២,000 | $២,000 |
| | ទ្រព្យសកម្មថ្នាក់៣ | $២0,000 | $២0,000 | | $៣00 | $១៩,៧00 | ២៥% | $៤,៩២៥ | $១៤,៧៧៥ |
| | ទ្រព្យសកម្មថ្នាក់៤ | $៣,000 | $៣,000 | | | $៣,000 | ២0% | $៦00 | $២,៤00 |
| សរុបថ្នាក់២ ដល់ ៤ | | $២៧,000 | $២៧,000 | | $៣00 | $២៦,៧00 | | $៧,៥២៥ | $១៩,១៧៥ |
| សរុបរួម | | $២៧៧,៥00 | $២៧៧,៥00 | | $៣00 | $២៧៧,២00 | | $២0,0៥0 | $២៥៧,១៥0 |

**<u>របៀបគណនាទី២៖ ការគណនាចំណាយការប្រាក់</u>**

| | | |
|---|---|---|
| **ប្រាក់ចំណេញមុននិយ័តកម្មការប្រាក់ G1** | | **$៤៨,៥៨០** |
| **បូក** | ចំណាយការប្រាក់ក្នុងការិយបរិច្ឆេទ G2 | $៩៥០ |
| **ដក** | ចំណូលការប្រាក់ក្នុងការិយបរិច្ឆេទ G3 | ($៦៩៥) |
| | ប្រាក់ចំណេញសុទ្ធមុនការប្រាក់ G4 = G1+ G2 – G3 | $៤៨,៨៣៥ |
| | ៥0% នៃប្រាក់ចំណេញគ្មានការប្រាក់ G5 = G4 * ៥0% | $២៤,៤១៧.៥ |
| **បូក** | ចំណូលការប្រាក់ក្នុងការិយបរិច្ឆេទ G6 = G3 | $៦៩៥ |
| | ចំណាយការប្រាក់អតិបរមាអនុញ្ញាតឲ្យកាត់កងក្នុងការិយបរិច្ឆេទG7 = G5 + G6 | $២៥,១១២.៥ |
| | ចំណាយការប្រាក់យោងពីឆ្នាំមុន G8 | $៥៥០ |
| | សរុបចំណាយការប្រាក់ក្នុងការិយបរិច្ឆេទនិងយោងពីឆ្នាំមុនG9 = G2 + G8 | $១,៥០០ |
| | សរុបចំណាយការប្រាក់អាចកាត់កងបាន G10 = G7 ឬ G9 (មួយណាតិចជាង) | $១,៥០០ |
| | **ចំនួនទឹកប្រាក់ត្រូវដកពីប្រាក់ចំណូលជាប់ពន្ធ G11 = G10 – G2** | **$៥៥០** |

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសសន៍

## ១ សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទ "**ការប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំរបស់ក្រុមហ៊ុនសេវាកម្ម**" អ្វីដែលសង្កេតឃើញនោះមាន៥ចំណុច គឺៈ

- នៅក្នុងការធ្វើការប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ មិនត្រឹមតែទាមទារនូវចំណេះដឹងខាងពន្ធតែប៉ុណ្ណោះទេ ចំណេះដឹងខាងគណនេយ្យ ក៏តម្រូវអោយមានការយល់ដឹងច្បាស់ផងដែរ ដើម្បីបែងចែកពីលក្ខណៈខុសគ្នាមួយចំនួន។ ឧទាហរណ៍ នៅក្នុងគោលដៅពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ជាទូទៅប្រាក់ចំណូលជាប់ពន្ធតាមគណនេយ្យ មិនស្មើនឹងប្រាក់ចំណូលជាប់ពន្ធតាមពន្ធដារឡើយ ដូច្នេះហើយ លទ្ធផលពិតគណនេយ្យត្រូវតែជាកម្មវត្ថុនៃការកែតម្រូវក្រៅគណនេយ្យដែលមានការបញ្ចូលមកវិញ និងការកាត់ចេញផ្សេងៗ និង ត្រូវយល់ដឹងអំពីប្រភេទនៃចំណូល និងចំណាយដែលត្រូវរួមបញ្ចូល ឬកាត់បន្ថយនៅក្នុងការគណនាពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំនេះ។
- ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ គឺជាប្រភេទពន្ធមួយដែលតម្រូវអោយមានការស្គាល់ និងយល់ដឹងអំពីប្រភេទពន្ធដទៃទៀតឱ្យបានច្បាស់លាស់ ព្រោះនៅក្នុងការគណនាពន្ធនេះ ប្រភេទពន្ធផ្សេងៗបានចូលរួមជាធាតុផ្សំដើម្បីសម្រេចបានលទ្ធផលត្រឹមត្រូវ។ ឧទាហរណ៍ ពន្ធអប្បបរមា ប្រាក់រំដោះពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ឥណទានពន្ធកាត់ទុកបានបង់ក្នុងឆ្នាំ ឥណទានពន្ធលើប្រាក់ចំណូលបន្ថែមលើការបែងចែកភាគលាភក្នុងឆ្នាំ ឥណទានពន្ធបរទេស និង ពន្ធអាករមួយចំនួនផ្សេងៗទៀតដើម្បីធ្វើអោយលទ្ធផលដែលគណនាចេញមកនោះត្រឹមត្រូវ។
- ការគណនាប្រភេទពន្ធនេះ គឺមានលក្ខណៈស្មុគស្មាញ និងច្រើនជាងពន្ធដទៃផ្សេងៗទៀត ដែលពន្ធផ្សេងៗទៀតគ្រាន់តែយកមូលដ្ឋានគិតពន្ធមកគុណជាមួយនឹងអត្រាឲ្យបានត្រឹមត្រូវតែប៉ុណ្ណោះ ក្រៅពីការយល់ដឹងអំពីលក្ខខណ្ឌលើកលែង និងលក្ខខណ្ឌផ្សេងៗទៀត ប៉ុន្តែចំពោះពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំវិញ ទាមទារអោយអ្នកធ្វើការប្រកាស មានចំណេះដឹងច្រើន និងគ្រប់ផ្នែកទាំងអស់រាល់ប្រតិបត្តិការដែលបានកើតឡើងនៅក្នុងឆ្នាំ ពោលគឺទាំង១២ខែនេះ ដើម្បីយកមកធ្វើជាមូលដ្ឋានក្នុងការគណនា និងបានចេញជាលទ្ធផលសម្រាប់ប្រកាស មានន័យថា បើសិនជាពន្ធលើប្រាក់បៀវត្ស អ្វីដែលអ្នកធ្វើការប្រកាសពន្ធត្រូវដឹងជាសំខាន់ គឺតែអំពីព័ត៌មានរបស់បុគ្គលិកក្នុងក្រុមហ៊ុនតែប៉ុណ្ណោះ រីឯអាករពិសេសលើតម្លៃបន្ថែមវិញ អ្វីដែលអ្នកប្រកាសពន្ធត្រូវដឹងសំខាន់ជាងគេ គឺអំពីពត៌មាននៃប្រតិបត្តិការធ្វើការជាវទំនិញ ឬ សេវា ឬមួយក៏ការជាវនូវទំនិញ ឬសេវាដែលជាសកម្មភាពអាជីវកម្ម

របស់ក្រុមហ៊ុនសម្រាប់ធ្វើការផ្គត់ផ្គង់ទៅអោយអតិថិជនវិញ ឯពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ត្រូវដឹង និងស្គាល់ពីព័ត៌មានទាំងអស់ដែលបានកើតឡើងក្នុងការិយបរិច្ឆេទនោះ ដើម្បីធ្វើការប្រកាសអោយបានត្រឹមត្រូវ។

- កត្តាមួយទៀតដូចទៅនឹងឈ្មោះរបស់ពន្ធនេះដែរ គឺ**ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ** ទិន្នន័យដែលយកមកធ្វើការគណនារកលទ្ធផលនេះ គឺចេញមកពីខែទាំង១២ ដែលជាខែក្នុងការិយបរិច្ឆេទជាប់ពន្ធ ដូចនេះទាមទារអោយមានភាពហ្មត់ចត់ ជៀសវាងការបូកបញ្ចូលច្រលំនូវទិន្នន័យខែណាមួយ។ ទន្ទឹមនឹងនេះផងដែរ ក៏តម្រូវអោយមានភាពច្បាស់លាស់អំពីធាតុនីមួយៗទាំងក្នុងគណនេយ្យ និងទម្រង់លិខិតប្រកាសពន្ធលើប្រាក់ចំណូល ដើម្បីយកមកចាប់កូដទាំង១២ខែបញ្ចូលគ្នាឱ្យបានត្រឹមត្រូវ ក្នុងដំណើរការគណនា និងប្រកាសពន្ធលើប្រាក់ចំណូលនេះ។
- បច្ចេកវិទ្យាបច្ចុប្បន្នក៏មានភាពរីកចម្រើនផងដែរ ហេតុដូចនេះចំណេះដឹងខាងផ្នែកបច្ចេកវិទ្យានេះ អាចជួយសម្រួលក្នុងការគណនា។

សរុបសេចក្តីមក ចំណេះដឹងតម្រូវអោយមានក្នុងការគណនាពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ គឺមានវិសាលភាពធំទូលាយជាងពន្ធដទៃទៀត។

## ២ ការផ្តល់អនុសាសន៍

តាមរយៈការសិក្សាស្រាវជ្រាវ និងសេចក្តីសន្និដ្ឋានខាងលើអំពី "**ការប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំសម្រាប់ក្រុមហ៊ុនសេវាកម្ម**" មានមតិយោបល់មួយចំនួនដែលទាក់ទងនឹងប្រធានបទនេះជូនចំពោះសហគ្រាស ដែលមតិយោបល់នោះគឺ៖

- ត្រូវកាន់ កត់ត្រាបញ្ជីគណនេយ្យ តាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា
- ត្រូវកាន់ កត់ត្រា ឬរក្សាទុកបញ្ជីឯកសារនានា ឬទិនានុប្បវត្តិ ដែលបានកំណត់ដោយបទប្បញ្ញត្តិស្តីពីពន្ធដារ អោយបានច្បាស់លាស់ និងត្រឹមត្រូវអោយបាន១០ឆ្នាំ គិតពីដំណាច់ឆ្នាំជាប់ពន្ធដែលបញ្ជី ឬឯកសារទាំងនេះបានកត់ត្រានូវព័ត៌មានផ្សេងៗលើប្រតិបត្តិការរបស់សហគ្រាសដើម្បីជៀសវាងនូវបញ្ហាផ្សេងៗធ្វើអោយខាតបង់ច្រើន។ ការរក្សាទុកនេះទៀត ក៏ជួយសម្រួលនូវដំណើរការក្នុងការគណនា និងការប្រកាសពន្ធ មិនត្រឹមតែពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំនោះទេតែក៏សំដៅលើប្រភេទពន្ធផ្សេងៗទាំងអស់ផងដែរ។
- ដោយសារច្បាប់ពន្ធមានការកែប្រែច្រើន ដើម្បីតាមអោយទាន់ទៅនឹងបរិបទសង្គមនិងក្នុងគោលដៅណាមួយ ហេតុដូច្នេះហើយតម្រូវអោយភ្នាក់ងារប្រកាសពន្ធ ត្រូវធ្វើយ៉ាងណាសិក្សាស្វែងយល់អោយបានច្បាស់អំពីច្បាប់ថ្មី និងច្បាប់ដែលបានធ្វើវិសោធនកម្ម តាមរយៈធ្វើការតាមដាននូវពត៌មានដែលរដ្ឋបាលសារពើពន្ធ ប្រកាស
- ដោយសារតែសម័យនេះ ជាយុគសម័យឌីជីថល ដូចនេះហើយពន្ធដារបានជួយសម្រួលដល់អ្នកជាប់ពន្ធទាំងអស់ ដោយធ្វើការប្រើនូវបច្ចេកវិទ្យាទំនើប ដូចជាការប្រកាសពន្ធតាមប្រព័ន្ធអនឡាញ(E-FILING)និងការដាក់លិខិតប្រកាសពន្ធតាមប្រព័ន្ធអនឡាញ (E-Taxservice)ដែលអ្នកជាប់ពន្ធទាំងអស់មិនចាំបាច់ទៅដាក់លិខិតប្រកាសពន្ធដោយផ្ទាល់នៅតាមសាខានានារបស់ពន្ធដារឡើយ ហេតុដូច្នេះហើយ អ្នកជាប់ពន្ធទាំងអស់ ត្រូវធ្វើបច្ចុប្បន្នភាពជាមួយនឹងខាងពន្ធដារ ពាក់ពន្ធ័ទៅនឹងច្បាប់ថ្មីៗ ដូចជា E-FILING, E-Tax Service និង E-VAT Refund ជាដើម
- ត្រូវបញ្ជូនគណនេយ្យករ និងភ្នាក់ងារប្រកាសពន្ធ ទៅចូលរួមក្នុងសិក្ខាសាលារបស់ពន្ធដារ ព្រមទាំងរៀបចំការផ្សព្វផ្សាយនឹងបង្រៀនដល់បុគ្គលិក ពាក់ពន្ធ័នឹងច្បាប់ថ្មីៗ។

## ឯកសារយោង

- ច្បាប់ស្តីពីសារពើពន្ធឆ្នាំ១៩៩៧, មាត្រា១២៨
- ប្រកាសស្តីពីពន្ធលើប្រាក់ចំណូល, លេខ០៩៨ សហវ ប្រ.ក, ២៩ មករា ២០២០
- ប្រកាសស្តីពីការកែសម្រួលការណែនាំអនុវត្តពន្ធកាត់ទុកលើការបែងចែកភាគលាភ,លេខ៣៧២ សហវ. ប្រ.ក, ០៥ មេសា ២០១៩
- ប្រកាសលេខ២៧០ សហវ.ប្រក ចុះថ្ងៃទី១៣ ខែមិនា ឆ្នាំ២០១៩ស្តីពីនីតិវិធីនៃការធ្វើសវនកម្មពន្ធដារ ក្នុងគោលបំណងធ្វើឲ្យប្រសើរឡើង និងកំណត់នូវនីតិវិធីនៃការធ្វើសវនកម្មពន្ធដារ
- ប្រកាសស្តីពីការព្យួរទុកការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូលរបស់សហគ្រាសប្រកបអាជីវកម្មក្នុងវិស័យកសិកម្ម, លេខ១០០/ សហវ/ ប្រក, ២៩ មករា ២០១៩
- ប្រកាសស្តីពីការកែសម្រួលចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស, លេខ០២៥សហវ.ប្រក. អពដ,២៤ មករា ២០១៨
- ប្រកាសស្តីពីការកំណត់មូលដ្ឋានគិតអាករសម្រាប់បំភ្លឺសាធារណៈ, លេខ៩៧៦សហវ/ប្រក, ០៩ តុលា ២០១៧
- ប្រកាសស្តីពីការណែនាំអនុវត្តអាករលើតម្លៃបន្ថែមចំពោះការផ្គត់ផ្គង់មិនជាប់អាករ,លេខ៥៥៩ សហវ/ ប្រក, ២៥ ឧសភា ២០១៧
- ប្រកាសស្តីពីការកែសម្រួលកាលបរិច្ឆេទដាក់លិខិតប្រកាសពន្ធប្រចាំខែ, លេខ១៥៣៩សហវ/ប្រ.ក, ២៣ ធ្នូ ២០១៦
- ប្រកាសស្តីពីវិធាន និង នីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់, លេខ ១៨២១ សហវ. ប្រក, ២៥ ធ្នូ ២០១៥
- ប្រកាសស្តីពីការអនុវត្តអាករលើការស្នាក់នៅ, លេខ៣៨០សហវ/ពដ, ១៤ កក្កដា ២០០៥
- ប្រកាសស្តីពីពន្ធលើប្រាក់បៀវត្ស, លេខ ១១៧៣ សហវ/ ពដ/ប្រក, ៣១ ធ្នូ ២០០៣
- ប្រកាសស្តីពីការប្រើប្រាស់ទម្រង់លិខិតប្រកាសបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ, លេខ៥០៦, សហវ ពដ, ២៤ កក្កដា ២០០២
- ប្រកាសស្តីពីពន្ធលើប្រាក់ចំណេញដែលសម្រេចដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ ១០៥៩ សហវ.ប្រក.ពដ ចុះថ្ងៃទិ១២ ខែធ្នូ ឆ្នាំ២០០៣

- អនុក្រឹត្យស្តីពី តារាងភាគនៃប្រាក់បៀវត្សជាប់ពន្ធប្រចាំខែថ្មី, លេខ ០៩ អនក្រ.បក, ១៣ កុម្ភៈ ២០២០
- អនុក្រឹត្យស្តីពីអាករលើតម្លៃបន្ថែម,លេខ ១១៤ អនក្រ.បក, ២៤ ធ្នូ ១៩៩៩
- អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, "សៀវភៅណែនាំស្តីពីពន្ធកាត់ទុកលើនិវាសន ជននិងអនិវាសនជន", ២០១៣
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ https://www.mef.gov.kh/assets/images/home_GDP_20191024.png(ចូលទស្សនាថ្ងៃទី ១៩ មិថុនា ២០២០)
- នាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, "សិទ្ធនិងកាតព្វកិច្ចអ្នកជាប់ពន្ធ", ២០១០
- សេចក្តីជូនដំណឹងស្តីពីការដាក់លិខិតប្រកាស និង បង់ពន្ធប៉ាតង់ ប្រចាំឆ្នាំ២០១៨, លេខ ៣៦២១ អពដ, ១៦ មីនា ២០១៨
- សេចក្តីជូនដំណឹងស្តីពីការកែសម្រួលមូលដ្ឋានគិតអាករពិសេសលើមុខទំនិញមួយចំនួន ដែលផលិតក្នុងស្រុកក្រៅពីបារីនិងស្រា, លេខ០០៥សហវ, ១៩ មករា ២០១៥
- ដកស្រង់ចេញពីឯកសារបង្រៀនរបស់សាស្ត្រាចារ្យ ឆាយ ជាហេង (ចូលទស្សនាថ្ងៃទី២០ សីហា ២០២០)
- Ashley Crossman, "*Post-Industrial Society in Sociology*," ThoughtCo., https://www.thoughtco.com/post-industrial-society-3026457 (ចូលទស្សនាថ្ងៃទី១៩ មិថុនា ២០២០)។
- Charles E. McLure, "*Taxation,*" *Britannica*, https://www.britannica.com/topic/taxation (ចូលទស្សនាថ្ងៃទី២៤ សីហា ២០២០)
- Jim Chappelow, "*Industrialization*," Investopedia, https://www.investopedia.com/terms/i/industrialization.asp (ចូលទស្សនាថ្ងៃទី១៩ មិថុនា ២០២០)។

- Tejvan Pettinger, "*Tertiary- Service sector of the economy,*" Economics Help, https://www.economicshelp.org/tertiary-service-sector/(ចូលទស្សនាថ្ងៃទី ១៩ មិថុនា ២០២០។
- Tertiary sector of the economy. (ចូលទស្សនាថ្ងៃទី១៩ មិថុនា ២០២០). In Wikipedia. ដកស្រង់ចេញពី https://en.m.wikipedia.org/wiki/Tertiary_sector_of_the_economy
- "*The World Factbook*". CIA.gov.Central Intelligence Agency.(ចូលទស្សនាថ្ងៃទី១៩ មិថុនា ២០២០)
- Zach Lazzari, "*What are the causes of rapid growth in the service insutry?*", Chron, https://smallbusiness.chron.com/causes-rapid-growth-service-industry-16007.html (ចូលទស្សនាថ្ងៃទី១៩ មិថុនា ២០២០)។

# ឧបសម្ព័ន្ធ